ធនាគារ ARDB
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# របាយការណ៍ប្រចាំឆ្នាំ




## ២០២២



# មាតិកា


អារម្ភកថាប្រធានក្រុមប្រឹក្សាភិបាល......................................................................៣
អារម្ភកថាអគ្គនាយក........................................................................................៤
ក្រុមប្រឹក្សាភិបាល...........................................................................................៥
គណៈគ្រប់គ្រង.................................................................................................៩
អំពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម.......................................................................១១
ចក្ខុវិស័យ........................................................................................................១១
បេសកកម្ម.......................................................................................................១១
គុណតម្លៃ.........................................................................................................១២

## ផ្នែកទី១ អភិបាលកិច្ចសាជីវកម្ម

១.១.-រចនាសម្ព័ន្ធ..................................................................................................១៣
១.២.- គណៈកម្មការសវនកម្ម......................................................................................១៤
១.៣.- គណៈកម្មការគ្រប់គ្រងហានិភ័យ.............................................................................១៤
១.៤.- គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ.......................................................១៤
១.៥.- ក្រុមប្រឹក្សាវិន័យ..............................................................................................១៥
១.៦.-គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល.............................................១៥
១.៧.- គណៈកម្មការគ្រប់គ្រង និងចាត់ចែងទ្រព្យសកម្ម និងទ្រព្យអកម្ម...................................១៦
១.៨.- គណៈកម្មាធិការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា.......................................................១៦
១.៩.-គណៈកម្មាធិការតម្រង់ទិសព័ត៌មានវិទ្យា...................................................................១៧
១.១០.- គណៈកម្មាធិការយុទ្ធសាស្ត្រព័ត៌មានវិទ្យា.............................................................១៧

## ផ្នែកទី២ ផលិតផល និងសេវាកម្ម

២.១.- ឥណទាន.........................................................................................................១៨
២.២.-ឥណទានបៃតង..................................................................................................១៩
២.៣.-ប្រាក់បញ្ញើ.........................................................................................................១៩
២.៤.- សេវាធនាគារឌីជីថល...........................................................................................២០
២.៥.-ហិរញ្ញប្បទានពាណិជ្ជកម្ម.......................................................................................២១
២.៦.- ការពង្រឹងបណ្តាញប្រតិបត្តិការ និងដៃគូអភិវឌ្ឍន៍របស់ធនាគារ ARDB..........................២២

## ផ្នែកទី៣ សមិទ្ធផលការងារ ឆ្នាំ២០២២

៣.១.- សំពៀតឥណទានបែងចែកតាមវិស័យ...........................................................................២៣
៣.២.- សំពៀតឥណទានបៃតងបែងចែកតាមវិស័យ...................................................................២៤
៣.៣.- ប្រាក់បញ្ញើ.........................................................................................................២៥
៣.៤.- សមិទ្ធផលនៃការអនុវត្តកម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល............................២៥
៣.៥.- ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងស្ថាប័ន...........................................................២៦

## ផ្នែកទី៤ ការចូលរួមចំណែកលើគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព

## ផ្នែកទី៥ ព្រឹត្តិការណ៍សំខាន់ៗរបស់ ARDB

៥.១.- ការរួមចំណែកនៅក្នុងការងារសង្គម.........................................................................២៨
៥.២.- កិច្ចប្រជុំថ្នាក់តំបន់ និងទស្សនកិច្ចសិក្សា.....................................................................២៨
៥.៣.- ការចូលរួមអន្តរាគមន៍ក្នុងវិស័យស្រូវ-អង្ករ....................................................................៣៤

## ផ្នែកទី៦ របាយការណ៍ហិរញ្ញវត្ថុ

៦.១.- របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២
និងរបាយការណ៍របស់សវនករឯករាជ្យ...........................................................................៣៥

# និន្នន័យហិរញ្ញវត្ថុសង្ខេប

## ប្រាក់ចំណូល និងប្រាក់ចំណេញ ក្នុងឆ្នាំ២០២២



ប្រាក់ចំណូល ( គិតជា ដុល្លារអាមេរិក )
២០,៩៣៥,៤១១



ប្រាក់ចំណេញ ( គិតជា ដុល្លារអាមេរិក )
១៤,៦២៣,៤២៥

## របាយការណ៍ហិរញ្ញវត្ថុសង្ខេប




ទ្រព្យសកម្មសរុប ( គិតជាលានដុល្លារអាមេរិក )




សមតុល្យប្រាក់បញ្ញើសរុប ( គិតជាលានដុល្លារអាមេរិក )




ឥណទាន និងបុរេប្រទានផ្តល់ជូនអតិថិជន-សុទ្ធ ( គិតជា លានដុល្លារអាមេរិក )




ចំនួនគណនីសរុប

# ចំនួនអតិថិជនបែងចែកតាមវិស័យ

## ចំនួនអតិថិជនឥណទានបែងចែកតាមវិស័យ




## ចំនួនអតិថិជនឥណទានបៃតងបែងចែកតាមវិស័យ




ចំនួនគណនីសរុប

## អារម្ភកថាប្រធានក្រុមប្រឹក្សាភិបាល



ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាពនិងបរិយាបន្នតាមរយៈការផ្តល់ហិរញ្ញប្បទានពិសេស របស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ( ធនាគារ ARDB ) គឺជាការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងប្រែក្លាយកសិករលក្ខណៈប្រពៃណីទៅជាកសិករសហគ្រិន សំដៅលើកកម្ពស់ជីវភាពការរស់នៅរបស់កសិករនៅតាមទីជនបទឱ្យកាន់តែមានភាពប្រសើរឡើង។

ស្របតាមក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣, ធនាគារ ARDB នៅតែបន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយយកចិត្តទុកដាក់ និងអនុវត្តតាមផែនការអាជីវកម្ម ៣ ឆ្នាំរំកិល (២០២៣-២០២៥) ដើម្បីសម្រេចបានតាមគោលដៅរបស់ធនាគារដោយដាក់ចេញនូវគោលដៅសម្រេចឱ្យបាននូវការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈការផ្តល់ហិរញ្ញប្បទានពិសេសក្នុងការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីបន្តជំរុញកំណើនផលិតភាពកសិកម្មប្រកបដោយភាពប្រកួត-ប្រជែងខ្ពស់សំដៅដល់រក្សាសុវត្ថិភាពស្បៀងអាហារព្រមទាំងបង្កើនប្រសិទ្ធភាពនៃការដាំដុះ ចិញ្ចឹមសត្វ និងវារីវប្បកម្មប្រកបដោយចីរភាព និងនិរន្តរភាព។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB ខ្ញុំសូមសាទរ និងកោតសរសើរដល់ការលះបង់ និងសម្តែងនូវអំណរគុណដល់ សមាជិកក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃធនាគារ ARDB ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបំពេញបេសកកម្មរបស់ធនាគារដើម្បីឆ្ពោះទៅកាន់គោលដៅរួមគឺដើម្បីកសិករ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជន, ក្រសួង និងស្ថាប័នជាតិ-អន្តរជាតិពាក់ព័ន្ធទាំងអស់ ដែលតែងតែផ្តល់ការគាំទ្រដល់ធនាគារ ARDB ដើម្បីសម្រេចបាននូវសមិទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ និងចូលរួមលើកកម្ពស់សេដ្ឋកិច្ចប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនតទៅមុខ។

**រស់ សីលវ៉ា**
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម**



## អារម្ភកថាអគ្គនាយក



ការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ តាមរយៈការផ្តល់ហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល គឺជាអាទិភាពចម្បងរបស់ធនាគារ ARDB ក្នុងការជំរុញកំណើនកម្រិតជីវភាពប្រជាកសិករ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

### សមិទ្ធផលក្នុងឆ្នាំ២០២២

ភាពតានតឹងនៃវិបត្តិសកល ពិសេសការកើនឡើងខ្លាំងនៃអត្រាអតិផរណាដែលបង្កឡើងដោយសង្គ្រាមនៅតែបន្តជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំង ដល់អាជីវកម្មស្ទើរគ្រប់វិស័យក្នុងឆ្នាំ ២០២២ ប៉ុន្តែការណ៍នេះ ក៏បានផ្តល់ជាឱកាសឱ្យប្រទេសកម្ពុជាក្នុងការពង្រីក និងពង្រឹងវិស័យកសិកម្ម។ នៅក្នុងឆ្នាំ២០២២ ធនាគារ ARDB ក្រោមស្ថានភាពដ៏លំបាកនៃវិបត្តិសកលនេះ នៅតែអាចសម្រេចបាននូវសមិទ្ធផលអាជីវកម្មលើសពីផែនការដែលបានគ្រោងទុកទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកមិនមែនហិរញ្ញវត្ថុ។ ជាក់ស្តែង ធនាគារ ARDB សម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចជា៖ (១) សំពៀតឥណទានសរុបបានកើនឡើងរហូតដល់ ៣៨៤ លានដុល្លារអាមេរិក ដែលមានកំណើន ២៧,២២% ធៀបនឹងឆ្នាំ២០២១។ (២) ចំនួនគណនីប្រាក់បញ្ញើបានកើនឡើងដល់ ៣២១៤ គណនី ដែលមានកំណើនរហូតដល់ ២១,៥៦% និងសមតុល្យប្រាក់បញ្ញើកើនឡើងដល់ ៧,៧៤ លានដុល្លារអាមេរិក ដែលមានកំណើន ៣៤,៦០%។ (៣) បណ្តាញផ្តល់សេវាធនាគារ ត្រូវបានពង្រីកបន្ថែមដោយដាក់ឱ្យដំណើរការនូវការិយាល័យចល័តនៅតាមបណ្តាខេត្តចំនួន ៥ ដែលបច្ចុប្បន្ននេះ ធនាគារ ARDB មានការិយាល័យចល័តចំនួន ១៥ រួមមាន៖ ខេត្តបាត់ដំបង, បន្ទាយមានជ័យ, ឧត្តរមានជ័យ, ពោធិ៍សាត់, កំពង់ធំ, ព្រះវិហារ, ព្រៃវែង, ត្បូងឃ្មុំ, តាកែវ, ស្ទឹងត្រែង, សៀមរាប, កំពង់ចាម, កំពង់ឆ្នាំង, ក្រចេះ, និងខេត្តរតនគិរី។ (៤) បើកដំណើរការនាយកដ្ឋានហិរញ្ញប្បទានបៃតង ក្នុងការផ្តួចផ្តើមលើការផ្តល់ហិរញ្ញប្បទានបៃតងក្នុងប្រទេសកម្ពុជា និងចូលរួមក្នុងការការពារបរិស្ថាន និងការកើនឡើងឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងរក្សាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ និង (៥) បង្កើនប្រសិទ្ធភាពក្នុងដំណើរការវាយតម្លៃ និងបញ្ចេញឥណទានជូនប្រជាកសិករ និងភាគីពាក់ព័ន្ធក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្ម។

### ទស្សនវិស័យសម្រាប់ឆ្នាំ២០២៣ របស់ធនាគារ ARDB

ក្នុងគោលដៅបន្តបេសកកម្មរួមចំណែកលើកកម្ពស់ជីវ-ភាពប្រជាកសិករ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម, ធនាគារ ARDB ក៏បានដាក់ចេញនូវគោលដៅអាទិភាពសម្រាប់ ឆ្នាំ ២០២៣-២០២៥ ចំនួន ៥ ចំណុចចម្បងៗ ដូចខាងក្រោម៖

១. ធ្វើបរិវត្តកម្មទៅជាធនាគារឌីជីថលពេញលេញ
២. ជំរុញចង្កោមសហគ្រាសធុនតូច និងមធ្យម
៣. ជំរុញការផ្តល់ហិរញ្ញប្បទានបៃតងប្រកបដោយចីរភាព
៤. បង្កើនប្រាក់ចំណូលមិនមែនការប្រាក់ និង
៥. ប្រែក្លាយកសិករប្រពៃណីទៅជាកសិករសហគ្រិន។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមសម្តែងនូវការគោរព និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដែលតែងតែគាំទ្រ និងផ្តល់ទំនុកចិត្តមកលើធនាគារ ARDB។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ ដែលតែងតែគាំទ្រ និងផ្តល់អនុសាសន៍ល្អៗដល់ធនាគារ ARDB និងសូមអរគុណដល់ បុគ្គលិកធនាគារទាំងអស់ដែលបានខិតខំបំពេញការងារអស់ពីកម្លាំងកាយចិត្ត ព្រមទាំងអរគុណដល់អតិថិជន និងដៃគូអភិវឌ្ឍន៍នានាដែលបានចូលរួមសហការជាមួយធនាគារ ARDB លើការលើកស្ទួយការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា។

**បណ្ឌិត កៅ ថាច**
**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម**

# ក្រុមប្រឹក្សាភិបាល





ឯកឧត្តម រស់ សីលវ៉ា

**ឯកឧត្តម រស់ សីលវ៉ា** បច្ចុប្បន្នជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រធានក្រុមប្រឹក្សាភិបាល នៃសាជីវកម្ម ធានាឥណទានកម្ពុជា, ប្រធានគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម, សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, អនុប្រធានក្រុមប្រឹក្សាបរធននៃមូលនិធិគន្ធបុប្ផាកម្ពុជា, នាយកប្រតិបត្តិនៃមូលនិធិគន្ធបុប្ផាកម្ពុជា, ទេសាភិបាលតំណាងកម្ពុជាប្រចាំ ERIA, អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុកម្ពុជានៅក្នុងកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន, សមាជិកនៃក្រុមប្រឹក្សាភិបាល នៃកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា, អ្នកសម្របសម្រួលជាតិនៃកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" និងជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB។ ឯកឧត្តមបានចាប់ផ្តើមបម្រើតួនាទីក្នុងជួររដ្ឋាភិបាល ចាប់ពី ឆ្នាំ១៩៨៥ ក្នុងក្រសួងរ៉ែ និងថាមពល។ នៅឆ្នាំ១៩៩៤ ឯកឧត្តមបានបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានតួនាទីជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ ឯកឧត្តម ត្រូវបានតែងតាំងជាអនុប្រធាននាយកដ្ឋានផែនការគោលនយោបាយសេដ្ឋកិច្ចជាតិ និងហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៦ ឯកឧត្តមបានទទួលតួនាទីជាប្រធាននាយកដ្ឋានសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីនេះទៀត ឯកឧត្តមធ្លាប់បានបំពេញការងារជាទីប្រឹក្សានាយកប្រតិបត្តិធនាគារពិភពលោកក្នុងឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨។ ឯកឧត្តមត្រូវបានតែងតាំងជាអគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីឯកឧត្តមវិលត្រឡប់មកពីបំពេញការងារជាទីប្រឹក្សានាយកប្រតិបត្តិធនាគារពិភពលោក ហើយឯកឧត្តមត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ ២០១៣។ នៅឆ្នាំ២០២០ ឯកឧត្តមត្រូវបានតែងតាំងជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ឯកឧត្តមក៏ជាអ្នករួមចំណែកក្នុងការតាក់តែងគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងធ្លាប់បានបំពេញការងារជាសាស្ត្រាចារ្យ នៅវិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញនៃក្រសួងអប់រំ យុវជន និង កីឡា ផងដែរ។

ឯកឧត្តមទទួលបានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសង្គមពី Penzas Institute of Pendagogy អតីតសហភាពសូវៀតនៅឆ្នាំ១៩៩២។នៅឆ្នាំ២០០២ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកកិច្ចការអន្តរជាតិគ្រប់គ្រងនយោបាយសេដ្ឋកិច្ចពីសាកលវិទ្យាល័យកូឡុមប៊ី ទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក។



ឯកឧត្តមបណ្ឌិត កៅ ថាច

**ឯកឧត្តមបណ្ឌិត កៅ ថាច** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB បន្ថែមលើមុខងារបច្ចុប្បន្ន ឯកឧត្តមបណ្ឌិតប្រតិភូជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឋានៈស្មើរដ្ឋលេខាធិការ និងជាមជ្ឈត្តករនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ មុនចូលបំពេញមុខងារនៅ ARDB ឯកឧត្តមបណ្ឌិតប្រតិភូជាអគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា មានឋានៈនិងបុព្វសិទ្ធិស្មើ អនុរដ្ឋលេខាធិការ (ទទួលបន្ទុក នាយកដ្ឋានកិច្ចការគតិយុត្ត និងនាយកដ្ឋានត្រួតពិនិត្យអន្តរការី), ធ្លាប់ជាប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុនៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងជាសមាជិកក្រុមការងារបច្ចេកទេសក្នុងវិស័យហិរញ្ញវត្ថុ ជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រោមក្របខណ្ឌអាស៊ាន លើការងារអភិវឌ្ឍទីផ្សារមូលធនដូចជា ក្រុមការងារ ABMI, ACMF និងសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុ។ ឯកឧត្តមបណ្ឌិតធ្លាប់បានចូលរួមធ្វើសេចក្តីព្រាងច្បាប់ស្តីពី មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ព្រមទាំងជាសមាជិកក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦ ដល់ ២០១៥ និង២០១១ ដល់ ២០២០។ នៅឆ្នាំ១៩៩៩ រហូតមកដល់ឆ្នាំ ២០០៣ ឯកឧត្តមបណ្ឌិតជាមន្ត្រីច្បាប់នៅក្រសួងយុត្តិធម៌ និងក្រឡាបញ្ជីនៅខេត្តកោះកុង។ ចំពោះប្រវត្តិសិក្សា ឯកឧត្តមបណ្ឌិតប្រតិភូ ទទួលបានបណ្ឌិតគោលនយោបាយសាធារណៈ មកពីសាកលវិទ្យាល័យកម្ពុជា (ប្រទេសកម្ពុជា) នៅឆ្នាំ២០២១ ដោយបានបញ្ចប់និក្ខេបបទ "The Role of Securities Regulators in Efficient Supervision and Regulation of the Securities Market in Cambodia" និងបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជសាស្ត្រ (DBA) មកពីសាកលវិទ្យាល័យ EU Business School (ប្រទេសស្វីស) នៅឆ្នាំ២០១៨។ ឯកឧត្តមបណ្ឌិតប្រតិភូទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ មកពី Bond University (ប្រទេសអូស្ត្រាលី) នៅឆ្នាំ ២០០២ លើជំនាញប្រព័ន្ធពាណិជ្ជកម្មច្បាប់អន្តរជាតិក្របខណ្ឌច្បាប់អង្គការពាណិជ្ជកម្មពិភពលោក ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ និងការរៀបចំប្រព័ន្ធដោះស្រាយវិវាទ និងបរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (LLB) នៅឆ្នាំ ១៩៩៨។



ឯកឧត្តម សាន វិសាល

**ឯកឧត្តម សាន វិសាល** បច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារ ARDB។

ឯកឧត្តមបានចូលបម្រើការងារក្នុងវិស័យកសិកម្ម ចាប់តាំងពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០០៣ ដែលក្នុងនោះឯកឧត្តមបានចូលរួមក្នុងសកម្មភាពជាច្រើនក្នុងការអភិវឌ្ឍវិស័យកសិកម្ម។ ឯកឧត្តមជាមន្ត្រីបច្ចេកទេសក្នុងនាយកដ្ឋានគ្រឿងយន្តកសិកម្ម នាយកដ្ឋានក្សេត្រសាស្ត្រ និងនាយកដ្ឋានបមាណីយ និងសម្ភារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៨ ឯកឧត្តមជានាយករដ្ឋបាលសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩ ឯកឧត្តមជាអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងចាប់ពីឆ្នាំ២០១៩ ជារដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ។

ក្រៅពីបំពេញការងាររដ្ឋ ឯកឧត្តមមានបទពិសោធន៍ការងារក្នុងវិស័យឯកជន ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផងដែរ។ ចាប់ពីឆ្នាំ១៩៩៤ មកដល់បច្ចុប្បន្ន ឯកឧត្តមជាអគ្គលេខាធិការ នៃសហព័ន្ធនិស្សិតបញ្ញវ័ន្តប្រជាធិបតេយ្យកម្ពុជា (ក្រុម២២)។ សម្រាប់ការសិក្សា ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យចម្រើនពហុបច្ចេកវិទ្យានៅឆ្នាំ២០០៥ និងកំពុងបន្តថ្នាក់បណ្ឌិតវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យអាស៊ីអឺរ៉ុប ហើយឯកឧត្តមបានបំពេញវគ្គបណ្តុះបណ្តាលសំខាន់ៗផងដែរ។




**ឯកឧត្តម ទាន សុសេរី** ជំនួយការឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារ ARDB។

ឯកឧត្តមបានចូលបម្រើការងារនៅទីស្តីការគណៈរដ្ឋមន្ត្រីចាប់តាំងពីឆ្នាំ២០០៦។ នៅឆ្នាំ២០០៦ ឯកឧត្តមបានបំពេញការងារនៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដោយចាប់ផ្តើមពីតួនាទីជាមន្ត្រីនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ជាប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នៅចន្លោះឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ និងជាប្រធានការិយាល័យអប់រំ និងអភិវឌ្ឍន៍ធនធានមនុស្ស នៃនាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីក្នុងឆ្នាំ២០០៩។ នៅចុងឆ្នាំ២០០៩ ឯកឧត្តមត្រូវបានតែងតាំងជាអនុប្រធាននាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ នៅឆ្នាំ ២០១៣ ឯកឧត្តមត្រូវបានតែងតាំងជាជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបន្ថែម លើមុខងារជាអនុប្រធាននាយកដ្ឋានទប់ស្កាត់បង្ការ និងអប់រំនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិ ដោះស្រាយទំនាស់ដីធ្លី។ នៅឆ្នាំ២០១៨ ឯកឧត្តមត្រូវបានតែងតាំងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង នៃទីស្តីការគណៈរដ្ឋមន្ត្រីបន្ថែមលើមុខងារជាជំនួយការ។ ឯកឧត្តម បានបញ្ចប់ការសិក្សាផ្នែករដ្ឋបាលសាធារណៈមន្ត្រីក្រមការនៃសាលាភូមិន្ទរដ្ឋបាលនៅឆ្នាំ ២០០៦ និងថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រឯកទេសវិទ្យាសាស្ត្រកុំព្យូទ័រនៃសាកលវិទ្យាល័យន័រតុននៅឆ្នាំ២០០៦។ នៅឆ្នាំ ២០២០ ឯកឧត្តម បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែករដ្ឋបាលសាធារណៈពីសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងឆ្នាំ២០២២ ឯកឧត្តម បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ នីតិសាធារណៈ ពីសាកលវិទ្យាល័យឥន្ទ្រវិជ្ជា (UI)។




**ឯកឧត្តម ឃី កុសល** ជាអនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារ ARDB។ ឯកឧត្តមបានចូលបម្រើការងារជាមន្ត្រីរាជការតាំងពីឆ្នាំ២០១២ បន្ទាប់ពីបញ្ចប់ការសិក្សានៅប្រទេសអង់គ្លេស។ ក្នុងនោះ ឯកឧត្តមបានចូលរួមបំពេញ និងបង្កើតស្នាដៃជូននាយកដ្ឋាននៃក្រសួងចំនួនពីររួមមាន៖ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឯកឧត្តមត្រូវបានតែងតាំងតួនាទីជាបន្តបន្ទាប់ ចាប់ពីតួនាទីជាមន្ត្រីរដ្ឋបាល និងធនធានមនុស្ស ដល់អនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឯកឧត្តម ឃី កុសល បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលពាណិជ្ជកម្មពីសាកលវិទ្យាល័យ UWIC ពីទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ឆ្នាំ២០១២ បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនៅក្នុងប្រទេស ជំនាញសំណង់ស៊ីវិល និងរដ្ឋបាលពាណិជ្ជកម្ម។




**លោក ម៉ាក សេរីវឌ្ឍនា** បច្ចុប្បន្នជាអ្នកប្រឹក្សាយោបល់នៃក្រុមហ៊ុន Axis Investment Consulting ដែលបាន និងកំពុងគាំទ្រគម្រោងអភិវឌ្ឍន៍អាជីវកម្មពាក់ព័ន្ធនឹងវិស័យកសិកម្ម និងហិរញ្ញវត្ថុជាច្រើនសម្រាប់ស្ថាប័នអង្គការអន្តរជាតិ និងឯកជនក្នុងស្រុក។ បន្ថែមពីការងារប្រឹក្សាយោបល់ លោកធ្លាប់បានបម្រើការងារក្នុងស្ថាប័នអន្តរជាតិ International Finance Corporation (IFC) និងបំពេញការងារពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុជិត ២០ឆ្នាំ។ ក្នុងនោះលោកបានចូលរួម និងសម្រេចបាននូវគម្រោង និងទិសដៅសំខាន់ៗជូនដល់ស្ថាប័នពាក់ព័ន្ធរួមមាន៖ គម្រោងអភិបាលកិច្ចសាជីវកម្ម (Corporate Governance Project) សម្រាប់ធនាគារជាតិនៃកម្ពុជា, គណៈកម្មការមូលបត្រកម្ពុជា, គម្រោងពិពិធកម្មវិស័យកសិកម្មនៅប្រទេសកម្ពុជា,គម្រោងអភិវឌ្ឍន៍ការិយាល័យឥណទានកម្ពុជា (ស៊ីប៊ីស៊ី) និងគម្រោងពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ និងការអន្តរាគមន៍ផ្សេងៗក្នុងវិស័យហិរញ្ញវត្ថុជាមួយក្រុមការងារ IFC។ លើសពីនេះលោកធ្លាប់បំពេញតួនាទីជាមន្ត្រីបច្ចេកទេសនៅស្ថាប័នរដ្ឋផងដែរ ពោលគឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានបទពិសោធន៍ក្នុងក្រុមហ៊ុនឯកជនផ្សេងៗទៀតផងដែរ។ លោកបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងហិរញ្ញវត្ថុ ពី Central Queensland University ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៩៧។ ក្រោយបញ្ចប់ការសិក្សានេះ លោកបានកសាងជំនាញផ្នែកវិភាគលើការវិនិយោគ និងហិរញ្ញវត្ថុ, វាយតម្លៃលទ្ធភាព និងការអភិវឌ្ឍផែនការអាជីវកម្ម, វាយតម្លៃឥណទាន និងអភិវឌ្ឍគម្រោង និងការគ្រប់គ្រងគម្រោង។




**ឯកឧត្តម ចាន់ សីហា** ជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB តំណាងបុគ្គលិក។ ឯកឧត្តមបានបំពេញការងារនៅធនាគារ ARDB ចាប់ពីខែមករា ឆ្នាំ១៩៩៩ ជាប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវបានតែងតាំងជាអគ្គនាយករង ទទួលបន្ទុកនាយកដ្ឋានប្រតិបត្តិការ នៅខែកក្កដា ឆ្នាំ២០១២។ ចាប់ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៩ ឯកឧត្តមបានបម្រើការងារជាអនុប្រធានការិយាល័យគ្រប់គ្រងគណនី និងជាប្រធានផ្នែកនៃការិយាល័យសភាផាត់ទាត់ នៃនាយកដ្ឋានប្រតិបត្តិការ និងជាបុគ្គលិកគណនេយ្យ នៃនាយកដ្ឋានគណនេយ្យនៃធនាគារជាតិនៃកម្ពុជា។ ឯកឧត្តមបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៤ និងបរិញ្ញាបត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារ ប្រទេសវៀតណាម ក្នុងឆ្នាំ១៩៩១។



ធនាគារ ARDB ត្រូវបានដឹកនាំដោយគណៈគ្រប់គ្រង ដែលមានសមាសភាពចំនួន ០៥ រូប ដូចខាងក្រោម៖

១.- ឯកឧត្តមបណ្ឌិត កៅ ថាច អគ្គនាយក

២.- ឯកឧត្តមបណ្ឌិត សឹង រេត អគ្គនាយករង

៣.- ឯកឧត្តម ចាន់ សីហា អគ្គនាយករង

៤.- ឯកឧត្តម ប៉ិច សានី អគ្គនាយករង

៥.- ឯកឧត្តម បាន លឹម អគ្គនាយករង

**ឯកឧត្តមបណ្ឌិត សឹង រេត** ត្រូវបានតែងតាំងជាអគ្គនាយករងនៃធនាគារ ARDB នៅខែកក្កដា ឆ្នាំ២០១៩។ ឯកឧត្តមជាទីប្រឹក្សាផ្ទាល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើរដ្ឋលេខាធិការ។ ជាមួយគ្នានេះដែរ, ឯកឧត្តម គឺជាសមាជិកនៃមហាវិទ្យាល័យធុរកិច្ច និងវិទ្យាស្ថានសេដ្ឋកិច្ចនៃសាកលវិទ្យាល័យ Antwerp នៃប្រទេសប៊ែកហ្សិក និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច (Research Fellow) នៅ Centre for ASEAN Studies។ ឯកឧត្តមធ្លាប់ជាសាស្ត្រាចារ្យបង្ហាត់លើមុខជំនាញសេដ្ឋកិច្ច នៅរដ្ឋ Massachusetts សហរដ្ឋអាមេរិក ក្រោមកម្មវិធី Fulbright Lecturing Program នៃ U.S Department of State។ ក្នុងអំឡុងកម្មវិធី Fulbright នៅសហរដ្ឋអាមេរិក, ឯកឧត្តមក៏តែងត្រូវបានអញ្ជើញចូលរួមបង្ហាត់នៅ D'Amore-McKim School of Business នៃសាកលវិទ្យាល័យ Northeastern ក្រុង Boston រដ្ឋ Massachusetts សហរដ្ឋអាមេរិក។ ក្នុងអំឡុងពេលបង្ហាត់នៅសហរដ្ឋអាមេរិករយៈពេលមួយឆ្នាំសិក្សា២០១៦-២០១៧,




ឯកឧត្តមបណ្ឌិត សឹង រេត ត្រូវបានអញ្ជើញឱ្យធ្វើបទបង្ហាញជាច្រើនស្តីពីភាពជោគជ័យ នៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា នៅតាមបណ្តាគ្រឹះស្ថានអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ នៅទីនោះ។ បច្ចុប្បន្ន, ឯកឧត្តមគឺជាសាស្ត្រាចារ្យផ្នែកសេដ្ឋកិច្ចនៃសាលាភូមិន្ទរដ្ឋបាល និងនៅរាជ្យបណ្ឌិតសភាកម្ពុជា ហើយនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ត្រូវបានតែងតាំងជាសមាជិកបម្រុងនៃរាជ្យបណ្ឌិតសភាកម្ពុជា។ ឯកឧត្តមបណ្ឌិតធ្លាប់ជាសមាជិកគណៈវិនិច្ឆ័យសម្រាប់ការការពារនិក្ខេបបទបរិញ្ញាបត្រជាន់ខ្ពស់នៅសកលវិទ្យាល័យ Antwerp និងជាសមាជិកពិនិត្យការការពារនិក្ខេបបទបរិញ្ញាបត្រជាន់ខ្ពស់នៅកម្ពុជា។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០០៩ ដល់ខែមករា ឆ្នាំ ២០១១, ឯកឧត្តមបានបញ្ចប់កិច្ចការស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិតនៅវិទ្យាស្ថាន Flemish Center for International Policy នៃសាកលវិទ្យាល័យ Antwerp ដែលតាមរយៈ ស្ថាប័ននេះ ឯកឧត្តមបានធ្វើលើគម្រោងស្រាវជ្រាវរួមគ្នាជាមួយធនាគារជាតិនៃប្រទេសប៊ែលហ្ស៊ិកក្រោមប្រធានបទ "ឥទ្ធិពលនៃសាកលភាវូបនីយកម្មលើទីផ្សារការងារក្នុង ប្រទេសប៊ែលហ្ស៊ិក"។ ឯកឧត្តមបានបោះពុម្ពឯកសារស្រាវជ្រាវវិទ្យាសាស្ត្រលើផ្នែកសេដ្ឋកិច្ចជាបន្តបន្ទាប់នៅក្នុងទិន្នានុប្បវត្តិវិទ្យាសាស្ត្រ និងធ្លាប់ជាអ្នកត្រួតពិនិត្យលើឯកសារសម្រាប់បោះពុម្ពក្នុងទិន្នានុប្បវត្តិវិទ្យាសាស្ត្រជាច្រើន ដូចជា Journal of Asian Economics, International Trade Journal, Economics Bulletin, International Journal of Commerce and Management, Journal ofInternational Trade and Economic Development, International Journal of Manpower, Journal of International Trade Law and Policy។ ការងារស្រាវជ្រាវរបស់ឯកឧត្តមក៏ត្រូវបានទទួលឱ្យធ្វើជាបទបង្ហាញនៅសហរដ្ឋអាមេរិក ប្រទេសចិន ប្រទេសហ្វីលីពីន ប្រទេសប៊ែលហ្ស៊ិក ប្រទេសកូរ៉េ ប្រទេសឥណ្ឌូនេស៊ី ប្រទេសសិង្ហបុរី និងប្រទេសថៃផងដែរ។ បច្ចុប្បន្នឯកឧត្តមក៏ជាសមាជិកនៃក្រុមប្រឹក្សាត្រួតពិនិត្យនៃ Journal of Business and Management ហើយក៏ជាសមាជិក (Council of Fellows) នៃ East Asian and Economic Association (EAEA) ផងដែរ។ ជាមួយគ្នានេះដែរ, ឯកឧត្តមបណ្ឌិតក៏ជាទីប្រឹក្សាគម្រោង (international consultant) របស់វិទ្យាស្ថាន Economic Research Institute for ASEAN and East Asia (ERIA) លើគម្រោងសេដ្ឋកិច្ចឌីជីថល និងបរិវត្តកម្មឌីជីថល។

**ឯកឧត្តម ប៉ិច សានី** ជាអគ្គនាយករងនៃធនាគារ ARDB។ ឯកឧត្តម មានបទពិសោធន៍ការងារក្នុងវិស័យធនាគារជាង ២០ ឆ្នាំមកហើយ។ មុននឹងចូលបម្រើការងារនៅធនាគារ ARDB ក្នុងឆ្នាំ២០០១ ឯកឧត្តមបានបម្រើការងារ និងមានបទពិសោធន៍ការងារជាច្រើននៅធនាគារជាតិនៃកម្ពុជា និងនៅធនាគារពាណិជ្ជ។ ឯកឧត្តម ប៉ិច សានី ត្រូវបានតែងតាំងជាអគ្គនាយករងនៃ ធនាគារ ARDB នៅខែតុលា ឆ្នាំ២០០៨។ ឯកឧត្តមបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៤ និងបរិញ្ញាបត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារប្រទេសវៀតណាមក្នុងឆ្នាំ១៩៩១។




**ឯកឧត្តម បាន លឹម** បានចូលបម្រើការងារក្នុងតួនាទីជាអគ្គនាយករង នៃធនាគារ ARDB នៅឆ្នាំ២០២១។ ឯកឧត្តមធ្លាប់បានបម្រើការងារជាទីប្រឹក្សាផ្នែកច្បាប់ និងមានបទពិសោធន៍ ក្នុងវិស័យធនាគាររយៈពេល ២០ឆ្នាំ ក្នុងតួនាទីជាសវនករផ្ទៃក្នុងនិងជាមន្ត្រីត្រួតពិនិត្យធនាគារនៅធនាគារជាតិនៃកម្ពុជា។ ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលធុរកិច្ច នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅ ឆ្នាំ ២០០៥ និងបានបញ្ចប់បរិញ្ញាបត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ ១៩៩៨។ ឯកឧត្តមក៏ជាសាស្ត្រាចារ្យផ្នែកច្បាប់ និងបទប្បញ្ញត្តិធនាគារ នៅមជ្ឈមណ្ឌលសម្រាប់ការសិក្សាធនាគារ




នៃធនាគារជាតិនៃកម្ពុជា និងនៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ អស់រយៈពេលជាច្រើនឆ្នាំ។




ធនាគារអភិវឌ្ឍន៍ជនបទត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៨ ដោយអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ ដោយមានឈ្មោះថា ធនាគារអភិវឌ្ឍន៍ជនបទ ដែលជាធនាគារឯកទេសវិស័យកសិកម្ម។ នៅឆ្នាំ ២០១៤ រាជរដ្ឋាភិបាលបានចេញ អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ក្នុងការកែសម្រួលមុខងារ ភារកិច្ច និងរចនាសម្ព័ន្ធរបស់ធនាគារ ARDB។ បន្ទាប់មក ធនាគារអភិវឌ្ឍន៍ជនបទ បានប្រែក្លាយពីធនាគារឯកទេស ទៅជាធនាគារពាណិជ្ជដោយបានប្តូរឈ្មោះថា ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម តាមអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។ ធនាគារ ARDB ត្រូវបានកំណត់ជាសហគ្រាសសាធារណៈ ក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលមានឧបនិស្ស័យជាធនាគារពាណិជ្ជ និងមានស្វ័យភាពបរិបូរណ៍ក្នុងការដឹកនាំ និងគ្រប់គ្រងសកម្មភាពរបស់ខ្លួន។

ធនាគារ ARDB ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។

## ចក្ខុវិស័យ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) គឺជាស្ថាប័នហិរញ្ញវត្ថុឈានមុខ ដែលផ្តោតលើការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ នៅប្រទេសកម្ពុជា។

## បេសកកម្ម

១ ការអភិវឌ្ឍ ការផ្សារភ្ជាប់យ៉ាងរឹងមាំនៅគ្រប់បណ្តោយខ្សែច្រវាក់តម្លៃកសិកម្ម និងវិស័យជនបទ តាមរយៈបរិយាប័ន្នសេវាកម្មហិរញ្ញវត្ថុ។

២ ការកំណត់, ការសម្របសម្រួល, និងការដោះស្រាយចន្លោះទីផ្សារ នៅក្នុង វិស័យកសិកម្ម និងជនបទតាមរយៈភាពជាដៃគូ យុទ្ធសាស្ត្រ។

៣ ការជំរុញពិពិធកម្មសេដ្ឋកិច្ចជនបទ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុដល់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងវិស័យសេដ្ឋកិច្ចជនបទ។

៤ ការលើកកម្ពស់ការសន្សំប្រាក់នៅតាមទីជនបទ។

## គោលដៅ

ធនាគារ ARDB មានគោលដៅរួមគឺផ្តល់សេវាធនាគារពេញលេញប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីគាំទ្រវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងនោះផងដែរ ធនាគារក៏មានគោលដៅរយៈពេល ៣ ឆ្នាំរំកិល ដើម្បីសម្រេចបាននូវគោលដៅរួមរបស់ធនាគារ មានដូចជា៖

- ធ្វើបរិវត្តកម្មទៅជាធនាគារឌីជីថលពេញលេញ
- ជំរុញការផ្តល់ហិរញ្ញប្បទានបៃតងប្រកបដោយចីរភាព
- ប្រែក្លាយកសិករដែលធ្វើកសិកម្មជាលក្ខណៈគ្រួសារទៅជាកសិករសហគ្រិន។
- ជំរុញចង្កោមសហគ្រាសធុនតូច និងមធ្យម
- បង្កើនប្រាក់ចំណូលមិនមែនការប្រាក់ឱ្យបានជាអតិបរមា



## គុណតម្លៃ




### សុចរិតភាព

យើងប្រាថ្នាឱ្យមាននូវបទដ្ឋានខ្ពស់បំផុតនៃភាពស្មោះត្រង់ និងអាកប្បកិរិយាបុគ្គល។ យើងមិនបណ្តោយឱ្យកេរ្តិ៍ឈ្មោះរបស់យើងអាប់ឱនឡើយ ហើយជានិច្ចកាលយើងធ្វើសកម្មភាព ដើម្បីឧត្តមប្រយោជន៍កសិករ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។



### ការសហការ

យើងគោរព និងផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក ប្រើប្រាស់នូវជំនាញ និងបទពិសោធន៍ផ្សេងៗគ្នា និងធ្វើការជាមួយដៃគូ ដើម្បីប្រមូលផ្តុំកម្លាំងសកលរបស់យើង សំដៅធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានសម្រាប់អាជីវកម្ម និងប្រទេសជាតិ។




### នវានុវត្តន៍

យើងរក្សានូវការពុះពារ ដើម្បីកំណត់នូវភាពឥតខ្ចោះនូវរាល់កិច្ចការ។ ដូចនេះ យើងបើកចំហចំពោះគំនិតថ្មីៗដែលអាចមាននូវភាពស្តង់ដារនិងនាំមកនូវការច្នៃប្រឌិតនានាសម្រាប់និរន្តរភាពនិងភាពរីកចម្រើននៃអាជីវកម្ម និងប្រទេសជាតិ។

# ផ្នែកទី១ – អភិបាលកិច្ចសាជីវកម្ម

## ១.១ រចនាសម្ព័ន្ធ




## ១.២ – គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្មគឺជាគណៈកម្មការឯករាជ្យ ដែលស្ថិតនៅក្រោមក្រុមប្រឹក្សាភិបាលផ្ទាល់។ គណៈកម្មការនេះមានតួនាទីពង្រឹងអភិបាលកិច្ចសាជីវកម្មនិងការគ្រប់គ្រងហានិភ័យ ដូចខាងក្រោម៖

- ពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃរបាយការណ៍ប្រចាំឆ្នាំរបស់ស្នងការគណនេយ្យឯករាជ្យដោយធានាថាព័ត៌មានដែលបានផ្តល់ជូនសាធារណជន និងធនាគារជាតិ ពិតជាត្រឹមត្រូវច្បាស់លាស់
- ពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់អនុសាសន៍ដល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើចំណុចខ្វះខាតដែលបានរកឃើញដោយស្នងការគណនេយ្យ និងក្រុមអធិការកិច្ចត្រួតពិនិត្យរបស់បញ្ញត្តិករ និងក្រសួងអាណាព្យាបាល
- វាយតម្លៃភាពសមស្របនៃវិធីសាស្ត្រគណនេយ្យ ដែលបានប្រើប្រាស់ដើម្បីរៀបចំគណនីដោយឡែក និងគណនីរួមបញ្ចូលគ្នា
- ពិនិត្យប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការរបស់ធនាគារតាមរយៈរបាយការណ៍ហិរញ្ញវត្ថុ និងគោលនយោបាយ នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសវាយតម្លៃប្រព័ន្ធសម្រាប់វាស់វែង តាមដាន និងត្រួតពិនិត្យទៅនឹងទម្រង់ការសម្រាប់ការកំណត់នូវ អត្តសញ្ញាណកម្ម វាយតម្លៃការធ្វើរបាយការណ៍ និងកិច្ចប្រតិបត្តិការដើម្បីឱ្យមានសង្គតិភាពតាមគោលនយោបាយ ផែនការនីតិវិធី បទប្បញ្ញត្តិនានា ដែលមានឥទ្ធិពលជាធរមាន
- អនុម័តលើរបាយការណ៍សវនករផ្ទៃក្នុងដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាភិបាលធនាគារ
- វាយតម្លៃនូវប្រសិទ្ធភាពការងារ បុគ្គលិកលក្ខណៈ និងឯករាជ្យភាពការងាររបស់សវនករផ្ទៃក្នុង និងពិនិត្យអនុម័តផែនការប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុង ដើម្បីធានាបាននូវការគ្រប់គ្រងហានិភ័យរបស់ធនាគារ។

## ១.៣ – គណៈកម្មការគ្រប់គ្រងហានិភ័យ

គណៈកម្មការគ្រប់គ្រងហានិភ័យគឺជាគណៈកម្មការស្ថិតក្រោមក្រុមប្រឹក្សាភិបាលផ្ទាល់។ គណៈកម្មការនេះ មានតួនាទីទទួលខុសត្រូវចំពោះក្រុមប្រឹក្សាភិបាល លើការគ្រប់គ្រងហានិភ័យដូចខាងក្រោម៖

- ពិនិត្យ និងអនុម័តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យក្របខណ្ឌការងារហានិភ័យ និងកំណត់អំពីហានិភ័យ
- ពិនិត្យ និងវាយតម្លៃភាពសមស្របនៃគោលនយោបាយនិងក្របខ័ណ្ឌការងារហានិភ័យក្នុងការកំណត់ អត្តសញ្ញាណ វាស់វែង តាមដាន និងគ្រប់គ្រងការវិវឌ្ឍហានិភ័យ
- ធានានូវរាល់ដំណើរការរចនាសម្ព័ន្ធ ធនធាន និងប្រព័ន្ធគ្រប់គ្រងហានិភ័យ
- ពិនិត្យមើល និងតាមដានការវិវឌ្ឍរបស់ទីផ្សារហិរញ្ញវត្ថុក្នុងប្រទេស និងទីផ្សារអន្តរជាតិ ព្រមទាំងស្ថានភាពនយោបាយ
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យរបស់ធនាគារ
- កំណត់នូវបញ្ហាប្រឈមក្នុងការអនុវត្តដែលអាចមានហានិភ័យ ទៅក្រុមប្រឹក្សាភិបាល ដើម្បីសុំការណែនាំ។

## ១.៤ គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌរបស់ ARDB
- ពិនិត្យ និងតាមដានការរៀបចំ និងបំពេញបែបបទ និងនីតិវិធី ដើម្បីទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលស្ថិតក្រោមការកាន់កាប់
- ប្រមូលចងក្រង និងរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជូនអគ្គនាយកនៃ ARDB ពិនិត្យ និងសម្រេច
- ពិនិត្យ និងផ្តល់យោបល់សំណើសុំជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពប្រើប្រាស់ ដើម្បី

ដាក់ជូនអគ្គនាយកនៃ ARDB ពិនិត្យ និងសម្រេច

- ពិនិត្យ និងលើកសំណើសុំលក់ ជួល ផ្ទេរ និងដោះដូរទីតាំងដីធ្លី អគារ ព្រមទាំងជម្រះអចលនទ្រព្យចេញពីបញ្ជីសារពើភណ្ឌរបស់ ARDB
- ចាត់វិធានការដាក់ស្តែង ដើម្បីធានាភាពត្រឹមត្រូវ ភាពគ្រប់ជ្រុងជ្រោយ និងភាពទាន់ពេល នៃការរៀបចំនិងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការ
- ជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រង ថែរក្សា និងតាមដានការប្រើប្រាស់យានយន្តគ្រប់ប្រភេទរបស់ ARDB
- ពិនិត្យលើរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងលើកសំណើដំណោះស្រាយ លើបញ្ហាប្រឈមនានាពាក់ព័ន្ធគណនេយ្យភាព និងបូរណភាពនៃការរៀបចំនិងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនអគ្គនាយកនៃ ARDB ពិនិត្យ និងសម្រេច
- លើកសំណើត្រួតពិនិត្យ និងធ្វើសវនកម្មលើការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពប្រើប្រាស់ ព្រមទាំងការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនអគ្គនាយកនៃ ARDB ពិនិត្យ និងសម្រេច។

## ១.៥ – ក្រុមប្រឹក្សាវិន័យ

ក្រុមប្រឹក្សាវិន័យគឺជាគណៈកម្មការពិសេសមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ថ្នាក់ដឹកនាំប្រតិបត្តិ។ គណៈកម្មការនេះ មានតួនាទីដូចខាងក្រោម៖

- ពិនិត្យ និងវាយតម្លៃលើសំណើសុំតែងតាំង និងដំឡើងឋានៈ និងប្រាក់បៀវត្សរ៍ដល់បុគ្គលិកគ្រប់ថ្នាក់ ដែលបំពេញការងារក្នុងក្របខណ្ឌពេញសិទ្ធិ និងកិច្ចសន្យាការងារ
- ពិនិត្យអំពីកម្រិតប្រាក់បៀវត្សរ៍ និងលាភការផ្សេងៗរបស់បុគ្គលិក
- ពិនិត្យ និងវាយតម្លៃលើសមត្ថភាពការងាររបស់បុគ្គលិកជាប់កិច្ចសន្យាការងារសាកល្បងដើម្បីបញ្ចូលជាបុគ្គលិកក្របខណ្ឌពេញសិទ្ធិ
- ពិនិត្យ និងវាយតម្លៃបុគ្គលិកគ្រប់ថ្នាក់ ដើម្បីលើកទឹកចិត្តនិងផ្តល់រង្វាន់សរសើរចំពោះបុគ្គលិក ដែលមានគុណសម្បត្តិក្នុងការបំពេញការដូចបានចែងក្នុងលក្ខន្តិកៈបុគ្គលិក
- ពិនិត្យ និងវាយតម្លៃលើការដាក់ទណ្ឌកម្មចំពោះបុគ្គលិកដែលមិនគោរពវិន័យដូចបានចែងក្នុងលក្ខន្តិកៈបុគ្គលិក
- ពិនិត្យ និងសិក្សាស្រាវជ្រាវអំពីករណីខុសឆ្គងរបស់បុគ្គលិកគ្រប់ថ្នាក់។

## ១.៦ – គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល

គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលត្រូវបំពេញតួនាទី និងភារកិច្ចស្របគោលការណ៍ស្តីពីតួនាទីនិងភារកិច្ចរបស់គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

- ទំនាក់ទំនងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍វិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទតាមរយៈផ្តល់ការគាំទ្រលើផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស
- សិក្សាគម្រោងនានារបស់រាជរដ្ឋាភិបាលដែលជាប់ទាក់ទងទៅនឹងបេសកកម្មរបស់ ARDB
- លើកសំណើគាំទ្រផ្នែកបច្ចេកទេស និង/ឬ ហិរញ្ញវត្ថុដែល ARDB អាចផ្តល់សម្រាប់អនុវត្តគម្រោង
- សិក្សាអំពីតម្រូវការហិរញ្ញវត្ថុរបស់គម្រោង កំណត់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងគោលការណ៍នៃការផ្តល់ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាព
- រៀបចំឯកសារគម្រោងអភិវឌ្ឍន៍អាជីវកម្មគំរូដែលអាចជួយកាត់បន្ថយនូវការចំណាយលើផលិតកម្ម
- វាយតម្លៃអំពីលទ្ធផលនៃសមត្ថភាពចូលរួមរបស់ARDB ក្នុងគម្រោង
- តាមដាននិងវិភាគលើការប្រើប្រាស់ហិរញ្ញប្បទានដែល ARDB បានផ្តល់
- ទំនាក់ទំនងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលដើម្បីវិភាគអំពីប្រសិទ្ធភាព នៃការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អ្នកអនុវត្តគម្រោង។

## ១.៧ – គណៈកម្មការគ្រប់គ្រង និងចាត់ចែងទ្រព្យសកម្ម និងទ្រព្យអកម្ម

គណៈកម្មការគ្រប់គ្រង និងចាត់ចែងទ្រព្យសកម្ម និងទ្រព្យអកម្ម មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំក្របខណ្ឌគោលនយោបាយនានា និងកំណត់សិទ្ធ-អំណាចស្តីពីការកំណត់កម្រិតនៃការទទួលយកហានិភ័យហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងតារាងតុល្យការរបស់ ARDB ដាក់ជូនក្រុម ប្រឹក្សាភិបាលនៃ ARDB ពិនិត្យ និងអនុម័ត
- ពិនិត្យ និងតាមដានកម្រិតហានិភ័យរបស់ ARDB ដែលអាចប៉ះពាល់ដល់តម្លៃទ្រព្យសកម្ម ទ្រព្យអកម្ម និងមូលនិធិភាគទុនិករបស់ ARDB ដើម្បីសម្រេចចាត់វិធានការសមស្របនឹងកម្រិតនៃការទទួលយកហានិភ័យរបស់ ARDB
- ពិនិត្យ តាមដាន និងវិភាគលើរាល់ការប្រែប្រួល និងការផ្លាស់ប្តូរ នៃនិន្នាការអាជីវកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសសន្ទនីយភាពអត្រាការប្រាក់ និងអត្រាប្តូរប្រាក់ដែលអាចប៉ះពាល់ដល់តម្លៃទ្រព្យសកម្ម ទ្រព្យអកម្ម និងមូលនិធិភាគទុនិករបស់ ARDB ដើម្បីចាត់វិធានការសមស្រប
- តាមដាន និងត្រួតពិនិត្យលើបទប្បញ្ញត្តិ បទដ្ឋានគតិយុត្តគោលនយោបាយ និងនីតិវិធីនានាដែលអាចប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យសម្បត្តិ ទ្រព្យអកម្ម និងមូលនិធិភាគទុនិករបស់ ARDB រួមមានជាអាទិ៍ ការតម្កល់ទុនបម្រុងកាតព្វកិច្ច កម្រិតសន្ទនីយភាពការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្ម និងទ្រព្យអកម្ម ការធ្វើសំវិធានធន និងការលុបចោលទ្រព្យសកម្ម
- ពិនិត្យ និងលើកសំណើលើការវិនិយោគលើបុត្រសម្ព័ន្ធ និង/ឬ ការចូលភាគកម្មជាមួយដៃគូអាជីវកម្មផ្សេងៗ
- ពិនិត្យ និងលើកសំណើលើផែនការថវិកាប្រចាំឆ្នាំថ្មីពាក់ព័ន្ធនឹងភាពសមស្របនៃទ្រព្យសកម្ម ទ្រព្យអកម្ម និងមូលនិធិភាគទុនិក ដោយផ្អែកលើផែនការយុទ្ធ-សាស្ត្រអាជីវកម្មរបស់ ARDB ។

## ១.៨ – គណៈកម្មាធិការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា

គណៈកម្មាធិការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យាមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- លើកកម្ពស់សមត្ថភាពគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យារបស់ ARDB ដោយរួមទាំងការសម្របសម្រួលក្នុងការអភិវឌ្ឍជំនាញគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យារបស់ ARDB
- បង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព ដើម្បីធានាឱ្យបាននូវភាពសម្ងាត់នៃទិន្នន័យ សន្តិសុខនៃប្រព័ន្ធព័ត៌មានវិទ្យា និងភាពអាចស្តារឡើងវិញបាននូវប្រព័ន្ធព័ត៌មានវិទ្យានៅក្នុងស្ថាប័ន
- បង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យារួម ដែលរួមមានការវាស់វែងកម្រិតហានិភ័យ ផលប៉ះពាល់ និងប្រភេទហានិភ័យ ដោយដាក់បញ្ចូលផងដែរនូវប្រព័ន្ធគ្រប់គ្រងហានិភ័យដែលមានភាពរឹងមាំ និងនីតិវិធីនៃការអនុវត្តដើម្បីគ្រប់គ្រងហានិភ័យ
- ដាក់ឱ្យអនុវត្តនូវការប្រតិបត្តិ និងត្រួតពិនិត្យឱ្យបានសមស្រប ដើម្បីកាត់បន្ថយហានិភ័យ និងធ្វើបច្ចុប្បន្ន-ភាពជាទៀងទាត់ និងការត្រួតពិនិត្យលើការវាយតម្លៃហានិភ័យទៅតាមកាលកំណត់ ដើម្បីរួមបញ្ចូល និងការផ្លាស់ប្តូរក្នុងលក្ខខណ្ឌប្រព័ន្ធព័ត៌មានវិទ្យា លក្ខខណ្ឌបរិស្ថាន ឬ លក្ខខណ្ឌប្រតិបត្តិការដែលអាចប៉ះពាល់ដល់ការវិភាគហានិភ័យ
- ធានាឱ្យបាននូវការអនុវត្តគោលនយោបាយ និងនីតិវិធីដូចដែលបានកំណត់ដោយ ARDB។

## ១.៩ – គណៈកម្មាធិការតម្រង់ទិសព័ត៌មានវិទ្យា

គណៈកម្មាធិការតម្រង់ទិសព័ត៌មានវិទ្យាមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រង និងដឹកនាំការងារ ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការយុទ្ធសាស្ត្រព័ត៌មានវិទ្យា
- ធ្វើការកំណត់នូវគម្រោងអាទិភាព និងធ្វើការវាយតម្លៃឡើងវិញនូវយុទ្ធសាស្ត្រដែលសមស្របទៅនឹងផែនការព័ត៌មានវិទ្យាដែលត្រូវយកមកប្រើប្រាស់
- ពិនិត្យឡើងវិញនូវការអនុវត្តបច្ចេកទេសព័ត៌មានវិទ្យានិងការកំណត់នូវបច្ចេកទេសព័ត៌មានវិទ្យាឆ្លើយតបទៅនឹងអាជីវកម្មរបស់ធនាគារ
- ធ្វើជាជំនួយក្នុងការគ្រប់គ្រង កំណត់ហានិភ័យ ត្រួត-ពិនិត្យ និងការតាមដាននូវដំណើរការគ្រប់គ្រងបច្ចេក-ទេសព័ត៌មានវិទ្យាសំខាន់ៗ
- ធ្វើការណែនាំទៅលើការប្រើប្រាស់ផលិតផលនៃបច្ចេក-ទេសព័ត៌មានវិទ្យា និងផ្តល់នូវទិសដៅក្នុងការអនុវត្តបច្ចេកទេសព័ត៌មានវិទ្យាឱ្យបានត្រឹមត្រូវហើយត្រូវធានាថាការប្រើប្រាស់បច្ចេកទេសថ្មីគឺអាចអនុវត្តបានហើយមានហានិភ័យតិចបំផុត
- ធានាឱ្យបាននូវការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងតាមគោលការណ៍ណែនាំនៃស្តង់ដារបច្ចេកវិទ្យា។

## ១.១០ – គណៈកម្មាធិការយុទ្ធសាស្ត្រព័ត៌មានវិទ្យា

គណៈកម្មាធិការយុទ្ធសាស្ត្រព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- បំពេញការងារតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៃ ARDB
- ត្រួតពិនិត្យសកម្មភាពការងាររបស់គណៈកម្មាធិការតម្រង់ទិសព័ត៌មានវិទ្យា នៃ ARDB
- ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រព័ត៌មានវិទ្យាឆ្លើយតបជាមួយនឹងតម្រូវការ ឬផែនការអាជីវកម្មរបស់ ARDB
- ធានាឱ្យបាននូវរចនាសម្ព័ន្ធ នៃអង្គភាពព័ត៌មានវិទ្យាដែលបានកំណត់ ដើម្បីជួយបំពេញបន្ថែមនូវតម្រូវការអាជីវកម្ម
- ធានាឱ្យបាននូវបច្ចេកវិទ្យាព័ត៌មានវិទ្យាឱ្យបានគ្រប់គ្រាន់នៅពេលមានតម្រូវការសម្រាប់ប្រតិបត្តិការ និងការគ្រប់គ្រងហានិភ័យផ្នែកព័ត៌មានវិទ្យា។



# ផ្នែកទី២ – ផលិតផល និងសេវាកម្ម

## ២.១ ឥណទាន

### ឥណទាន SMAEs ក្នុងវិស័យកសិកម្ម

ឥណទាននេះផ្តល់ទៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលស្ថិតក្នុងខ្សែច្រវាក់ផលិតកម្មពាក់ព័ន្ធនឹងវិស័យកសិកម្ម រួមមាន៖ ការផលិតការកែច្នៃការស្តុកទុកការចែកចាយនិងការនាំចេញនូវ ផលិតផលកសិកម្ម ជាពិសេសក្នុងវិស័យស្រូវ-អង្ករ និងផ្នែកផ្សេងទៀតដែលផ្សារភ្ជាប់នឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដែលមានអត្រាការប្រាក់ចាប់ពី ៥% - ៥.៥% ក្នុង ១ឆ្នាំ។



### ឥណទានសហគមន៍កសិកម្ម

ឥណទាននេះផ្តល់ឱ្យដើម្បីរួមចំណែកគាំទ្រការពង្រឹង និងពង្រីកសកម្មភាពអាជីវកម្មរបស់សហគមន៍កសិកម្ម ចង្កោមអ្នកផលិត និងសហគមន៍ផ្សេងទៀត ក្នុងទិសដៅបង្កើនផលចំណូលសមាជិករបស់សហគមន៍ ឬ ចង្កោមអ្នកផលិតប្រកបដោយនិរន្តរភាព ដែលមានអត្រាការប្រាក់ចាប់ពី ៩,៥% - ១០,៥% ក្នុង ១ឆ្នាំ។



### ឥណទានកសិកម្មខ្នាតតូច

ឥណទាននេះផ្តល់ទៅដល់រូបវន្តបុគ្គលដែលធ្វើអាជីវកម្មផ្ទាល់ខ្លួនពាក់ព័ន្ធនឹងវិស័យកសិកម្ម ដើម្បីបង្កើនសមត្ថភាពកសិករក្នុងការបង្កបង្កើនផល ផលិត កែច្នៃ ផ្គត់ផ្គង់ និងស្តុកទុកឱ្យមានបរិមាណ និងគុណភាពខ្ពស់សម្រាប់ការបង្កើនចំណូល ក្នុងកម្រិតអតិបរមា ដែលមានអត្រាការប្រាក់ចាប់ពី ៨-១១% ក្នុង ១ឆ្នាំ។



### ឥណទានបោះដុំ

ជាឥណទានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលគាំទ្រក្នុងវិស័យកសិកម្ម។ អតិថិជនដែលអាចទទួលបានឥណទាននេះ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងបំពេញតាមលក្ខខណ្ឌតម្រូវពីអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធដែលមានអត្រាការប្រាក់ចាប់ពី ៨-៩% ក្នុង ១ឆ្នាំ។





## ឥណទានក្នុងវិស័យស្រូវ-អង្ករ

មជ្ឈមណ្ឌលប្រមូលទិញស្រូវ រោងម៉ាស៊ីនកិនស្រូវ ឃ្លាំងសន្និធិស្រូវ-អង្កររួម/ធនាគារស្រូវ ព្រមទាំងអ្នកប្រមូលទិញស្រូវ ម្ចាស់ឃ្លាំង-ឡសម្ងួត ឬ ម្ចាស់ស៊ីឡូកសិផលផ្សេងទៀត ដែលមានឆន្ទៈនិងសមត្ថភាពប្រមូលទិញស្រូវក្រអូបនាងខុនឬកសិផលផ្សេងទៀតពីកសិករតាមតម្លៃកំណត់ដោយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម តាមការចង្អុលទិសរបស់រាជរដ្ឋាភិបាល ជាមួយនឹងអត្រាការប្រាក់ចាប់ពី ៥-៥,៥% ក្នុង ១ឆ្នាំ។

## ២.២ ឥណទានបៃតង



ឥណទានបៃតងគឺជាប្រភេទឥណទានមួយដែលគាំទ្រដល់ការដាំបន្លែសុវត្ថិភាព ( Safe vegetable ), ផ្ទះបៃតង ( Green /net house ), ប្រព័ន្ធស្រោចស្រពដំណាំ ( Irrigation system ), ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ( Panel/Renewable ), ឡជីវឧស្ម័ន ( Biogas ), ប្រព័ន្ធដំណាំមិនដាំផ្ទាល់ដី ( Hydroponic system-soilless crops ) ប្រព័ន្ធអាក្វាផូនិក ( Aquaponic system ), គម្រោងអាកាសធាតុបៃតង ( Climate resilience ) និងផ្សេង ៗទៀត ដែលមានអត្រាការប្រាក់ចាប់ពី ៥-១១% ក្នុង ១ឆ្នាំ។

## ២.៣ ប្រាក់បញ្ញើ



### ប្រាក់បញ្ញើសន្សំ

ជាមធ្យោបាយដ៏មានសុវត្ថិភាព និងមានប្រសិទ្ធភាព សម្រាប់អ្នកចង់សន្សំប្រាក់ និងទទួលបានការប្រាក់។



### ប្រាក់បញ្ញើមានកាលកំណត់

ជាប្រភេទគណនីដែលដាក់ប្រាក់បញ្ញើនៅធនាគារ ដែលមានកាលកំណត់ មានរយៈពេលពី ១ ទៅ ២៤ ខែ ឬ ក្នុងកាលកំណត់ណាមួយ ដើម្បីទទួលបានអត្រាការប្រាក់ប្រកួតប្រជែង។



### ប្រាក់បញ្ញើចរន្ត

ជាគណនីដែលងាយស្រួលក្នុងការទូទាត់ដោយប្រើប្រាស់មូលប្បទានបត្រ។

## ២.៤ សេវាធនាគារឌីជីថល

### កម្មវិធីទូរស័ព្ទដៃ



ធនាគារ ARDB បានមើលឃើញពីសក្តានុពលនៃការធ្វើប្រតិបត្តិធនាគារតាមទូរស័ព្ទដៃមានការកើនឡើងជាលំដាប់ ដូចនេះធនាគារ ARDB បានព្យាយាមពន្លឿន ពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវមុខងារថ្មី ៗក្នុងកម្មវិធីទូរស័ព្ទដៃ ប្រកបដោយគុណភាព និងការប្រកួតប្រជែង។ សេវាធនាគារតាមទូរស័ព្ទដៃ ( ARDB Mobile App ) មានមុខងារជាច្រើន ដូចជា៖ ការពិនិត្យសមតុល្យគណនីប្រាក់បញ្ញើ, ការពិនិត្យសមតុល្យឥណទាន, ការផ្ទេរប្រាក់, ការទូទាត់វិក្កយបត្រ, បញ្ចូលកាតទូរស័ព្ទ, ការស្នើសុំប្រាក់កម្ចី, ព័ត៌មានអំពីអត្រាប្តូរប្រាក់ជាប្រចាំ និងថែមទាំងអាចស្វែងរកឯកសារ និងព័ត៌មានដែលទាក់ទងនឹងវិស័យកសិកម្មទៀតផង ដោយការតភ្ជាប់ចូលក្នុងវេបសាយរបស់ធនាគារ ARDB ផ្ទាល់ដោយមានភាពងាយស្រួល រហ័ស និងសុវត្ថិភាព។




ប្រព័ន្ធបាគងគឺជាជំនាន់ចុងក្រោយនៃការទូទាត់តាមទូរស័ព្ទ និងជាថ្នាលធនាគារដែលផ្តួចផ្តើមដោយធនាគារជាតិ នៃកម្ពុជាសម្រាប់សេវាផ្ទេរប្រាក់ឆ្លងស្ថាប័នរបស់ធនាគារក្នុងស្រុក ស្ថាប័នហិរញ្ញវត្ថុ និងអ្នកផ្តល់សេវាទូទាត់ក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធបាគងអនុញ្ញាតឱ្យអតិថិជននៃធនាគារដែលចូលរួមទាំងអស់ផ្ទេរប្រាក់បានយ៉ាងងាយស្រួលដោយការស្កេន QR កូដ និងចុចលេខគណនី ដើម្បីផ្ញើ/ទទួលប្រាក់ ឬធ្វើការទូទាត់តាម QR ទៅកាន់ស្ថាប័នហិរញ្ញវត្ថុក្នុងស្រុកផ្សេងទៀត។

## ២.៥ ហិរញ្ញប្បទានពាណិជ្ជកម្ម

ផលិតផលសេវាកម្មហិរញ្ញប្បទានពាណិជ្ជកម្ម របស់ធនាគារ ARDB មានដូចខាងក្រោម៖

- សេវាផ្ទេរប្រាក់អន្តរជាតិ ( International Remittance )
- សេវាប្រមូលឯកសារទូទាត់ ( Documentary Collection )
- សេវាលិខិតឥណទាន ( Documentary Letter of Credit )
- សេវាលិខិតធានា ( Bank Guarantee )





## ២.៦ ការពង្រីកបណ្តាញប្រតិបត្តិការ និងដៃគូអភិវឌ្ឍន៍របស់ធនាគារ ARDB




បច្ចុប្បន្ននេះធនាគារARDBមានការិយាល័យចល័តនៅតាមបណ្តាខេត្តចំនួន ១៥ រួមមាន៖ ខេត្តបាត់ដំបង, បន្ទាយមានជ័យ, ឧត្តរមានជ័យ, ពោធិ៍សាត់, កំពង់ធំ, ព្រះវិហារ, ព្រៃវែង, ត្បូងឃ្មុំ, តាកែវ, ស្ទឹងត្រែង, សៀមរាប, កំពង់ចាម, កំពង់ឆ្នាំង, ក្រចេះ និងខេត្តរតនគិរី។ ការិយាល័យនីមួយៗបានពង្រឹងនូវបណ្តាញប្រតិបត្តិការរបស់ខ្លួនដោយជំរុញការផ្តល់ឥណទានឱ្យបានកាន់តែច្រើន និងដើម្បីឱ្យស្របតាមផែនទីចង្អុលផ្លូវរយៈពេល ១០ឆ្នាំ របស់ធនាគារ ARDB ដែលពង្រីកបណ្តាញសាខា និងការិយាល័យចល័តគ្រប់បណ្តាខេត្ត-ក្រុង ទូទាំងប្រទេស ជាមួយនឹងការផ្តល់សេវាកម្មធនាគារតាមបែបឌីជីថល ដែលជាមធ្យោបាយក្នុងការពង្រីកការផ្តល់សេវាកម្មរបស់ខ្លួនដល់អតិថិជនគោលដៅដើម្បីរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ នៅក្នុងប្រទេសជាពិសេសនៅតាមជនបទ។

កិច្ចសហការជាមួយស្ថាប័នលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានារបស់ធនាគារ ARDB ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម មានដូចជា៖ ធនាគារពិភពលោក ( WB ), មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្ម ( IFAD ), ធនាគារអភិវឌ្ឍន៍អាស៊ី ( ADB ), ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត ( SIDA ), ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ( AFD ), Bank for Agriculture and Agricultural Cooperatives ( BAAC ), សហព័ន្ធស្រូវអង្ករកម្ពុជា ( CRF ), សមាគមធនាគារនៅកម្ពុជា ( ABC ), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( MEF ), ក្រសួងពាណិជ្ជកម្ម ( MoC ), ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( MAFF ) និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( NCDD )។

ការចូលជាសមាជិកជាមួយនឹងស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់៖ Asia-Pacific Rural and Agricultural Credit Association ( APRACA ) និង The Association of Development Financing Institutions in Asia and the Pacific ( ADFIAP )។

ដៃគូសហការអាជីវកម្មរបស់ធនាគារ ARDB រួមមាន៖ ធនាគាររីងជាដៃគូសហការអាជីវកម្ម ក្នុងការសម្របសម្រួលការទូទាត់ឥណទាន, អគ្គិសនីកម្ពុជា-EDC ជាដៃគូទូទាត់វិក្កយបត្រអគ្គិសនីតាមរយៈការប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ ARDB Mobile និងធនាគារកាណាឌីយ៉ាជាដៃគូធនាគារក្នុងការសម្របសម្រួលនូវការបញ្ចេញមូលប្បទានបត្រ,Guangxi Beibu Gulf Bank ក្នុងការធ្វើប្រតិបត្តិការសេវាកម្មធនាគារក្រៅប្រទេស, CIMB of Thailand និងកិច្ចសហការរវាងធនាគារ ARDB ជាមួយនឹងធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងគោលបំណងពង្រីកវិសាលភាពការដាំដុះបន្លែ ផ្លែឈើ ការចិញ្ចឹមសត្វវារីវប្បកម្មនិងការកែច្នៃផលិតផលកសិកម្មដោយការប្រើប្រាស់យន្តការសហហិរញ្ញប្បទានចែករំលែកហានិភ័យ និងការចូលរួមអនុវត្តលើគោលនយោបាយហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីពង្រីកវិស័យកសិកម្ម និងជំរុញឱ្យមានស្ថិរភាពខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងទីផ្សារ។

# ផ្នែកទី៣ – សមិទ្ធផលការងារ ឆ្នាំ២០២២

## ៣.១ សំពៀតឥណទានបែងចែកតាមវិស័យ

ធនាគារ ARDB សម្រេចបាននូវការបញ្ចេញឥណទានសរុប ៣៦៤ លានដុល្លារអាមេរិក ដែលបែងចែកតាមវិស័យ ដូចបង្ហាញនៅក្នុងរូបភាពខាងក្រោម៖

ក្រាហ្វទី១៖ សំពៀតឥណទានបែងចែកតាមវិស័យ




ក្រាហ្វទី២៖ ចំនួនអតិថិជនឥណទានបែងចែកតាមវិស័យ




ក្រាហ្វទី៣៖ ទំហំឥណទានបែងចែកតាមភូមិសាស្ត្រ






## ៣.២ សំពៀតឥណទានបៃតងបែងចែកតាមវិស័យ

ក្រាហ្វទី៤៖ សំពៀតឥណទានបៃតងបែងចែកតាមវិស័យ




ក្រាហ្វទី៥៖ ចំនួនអតិថិជនឥណទានបៃតងបែងចែកតាមវិស័យ



## ៣.៣ ប្រាក់បញ្ញើ

ធនាគារ ARDB មានសមតុល្យប្រាក់បញ្ញើគ្រប់ប្រភេទសរុបចំនួន ៨,០៤ លានដុល្លារអាមេរិក ដែលចំនួនប្រាក់បញ្ញើនេះ មានសន្ទុះកើនឡើងជាបន្តបន្ទាប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដូចមានបង្ហាញក្នុងក្រាហ្វខាងក្រោម។



ក្រាហ្វទី៦៖ សមតុល្យប្រាក់បញ្ញើតាមប្រភេទគណនី (គិតជា លានដុល្លារអាមេរិក)



ក្រាហ្វទី៧៖ ចំនួនគណនីតាមប្រភេទប្រាក់បញ្ញើ

## ៣.៤ សមិទ្ធផលនៃការអនុវត្តកម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល






សមាគមនៃការអភិវឌ្ឍគ្រឹះស្ថានហិរញ្ញវត្ថុនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ADFIAP) មានបេសកកម្មរបស់ខ្លួន គឺជំរុញការអភិវឌ្ឍប្រកបដោយនិរន្តរភាពដោយការពង្រឹងមុខងារហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងការបង្កើនសមត្ថភាពសមាជិក និងការតស៊ូមតិលើការបង្កើតថ្មីផ្នែកហិរញ្ញវត្ថុ។

ពានរង្វាន់ ADFIAP Awards លើកទី៤៥ ប្រារព្ធឡើងក្នុងគោលបំណងផ្តល់កិត្តិយសដល់ស្ថាប័នសមាជិកដែលបានអនុវត្ត ឬគាំទ្រគម្រោងដែលជះឥទ្ធិពលជាវិជ្ជមានដល់ការអភិវឌ្ឍក្នុងវិស័យពាក់ព័ន្ធ ដូចជា៖ ការអភិវឌ្ឍមូលធនមនុស្ស, ការអភិវឌ្ឍបរិស្ថាន, ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការអភិវឌ្ឍបច្ចេកវិទ្យា, ការអភិវឌ្ឍពាណិជ្ជកម្ម, ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់, បរិយាបន្នផ្នែកហិរញ្ញវត្ថុ, អភិបាលកិច្ចសាជីវកម្ម និងទំនួលខុសត្រូវសង្គមសាជីវកម្ម។

ធនាគារ ARDB បានចូលរួមប្រកួតប្រជែងក្នុងកម្មវិធីពានរង្វាន់លើការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ (Local Economic Development) និងទទួលបានពានរង្វាន់សម្រាប់ការអភិវឌ្ឍឆ្នាំ២០២២ (Development Awards 2022) ក្រោមប្រភេទការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានថ្នាក់ក្រោមជាតិ (Local Economic Development) ដែលផ្តល់ដោយ Association of Development Financing Institutions in Asia and the Pacific (ADFIAP) កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ ដោយតំណាងដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកធនាគារ ARDB។ ពានរង្វាន់នេះផងដែរ ត្រូវបានផ្តល់ជូនធនាគារ ARDB សម្រាប់ការអនុវត្តកម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់វិស័យស្រូវ-អង្ករនៅកម្ពុជា តាមរយៈការគាំទ្រផ្តល់ហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាលជូនដល់ប្រជាកសិករ រោងម៉ាស៊ីនកិនស្រូវ និងភាគីពាក់ព័ន្ធផ្សេងទៀត។



## ៣.៥ ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងស្ថាប័ន




ធនាគារ ARDB បានបង្កើតមធ្យោបាយនៃការបណ្តុះបណ្តាលតាមរយៈឆានែល រួមមាន៖ តាមរយៈ E-learning ដែលជាកម្មវិធីផ្ទាល់របស់ធនាគារ ARDB ដោយការបង្កើតជាវីដេអូ និងការបណ្តុះបណ្តាលផ្ទាល់ (In class training)។

ធនាគារក៏មានផ្តល់ជូនដល់បុគ្គលិកដើម្បីពង្រឹងសមត្ថភាព ដោយផ្តល់ជូននូវការសិក្សាវគ្គបណ្តុះបណ្តាលខាងក្នុងស្ថាប័ន សរុបចំនួន ៥៩ វគ្គ និងវគ្គបណ្តុះបណ្តាលផ្សេងទៀត។

## ផ្នែកទី៤ – ការចូលរួមចំណែកលើគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព

នៅក្នុងការចូលរួមចំណែកលើគោលដៅ នៃការអភិវឌ្ឍប្រកបដោយចីរភាព និងយូរអង្វែងដែលជាកម្លាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច, សង្គម, និងបរិស្ថាន ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានខិតខំសហការជាមួយដៃគូយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងអន្តរជាតិដើម្បីជំរុញការផ្សារភ្ជាប់ទៅនឹងគោលដៅ នៃការអភិវឌ្ឍប្រកប ដោយនិរន្តរភាព។ ធនាគារ ARDB បានរួមចំណែកនៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាពលើគោលដៅមួយចំនួន រួមមាន៖ គោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាពទី១, ទី២, ទី៨, ទី១៣,និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាពទី១៧។

(១) ពុំមានភាពក្រីក្រ៖ ធនាគារARDBបានរួមចំណែកយ៉ាងសកម្មជាមួយដៃគូអភិវឌ្ឍន៍នៅក្នុងការសហការយ៉ាងយកចិត្តទុកដាក់ដល់អតិថិជនគោលដៅដែលជាកសិករនៅតាមទីជនបទ ដោយផ្តល់ឥណទាន ការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ជំនាញក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនិងជំនាញដែលពាក់ព័ន្ធផ្សេង ៗទៀតក្នុងវិស័យកសិកម្ម ដើម្បីប្រែក្លាយពីកសិករទៅ ជាកសិករសហគ្រិនស្របតាមសម័យកាលបច្ចេកវិទ្យាឌីជីថលព្រមទាំងជំរុញឱ្យមានលំហូរនៃប្រាក់ចំណូលខ្ពស់ផងដែរ។



(២) គ្រោះអត់ឃ្លានស្មើសូន្យ៖ ធនាគារ ARDB បាននិងកំពុងអនុវត្តគម្រោងដែលគាំទ្រយ៉ាងសំខាន់ដល់ ផលិតករធុនតូច មធ្យម និងធំ ក្នុងវិស័យកសិកម្ម វារីវប្បកម្ម និងការកែច្នៃផលិតផលកសិកម្មជាដើម ដើម្បីបង្កើនការផលិតទាំងនៅក្នុងស្រុកក៏ដូចជាអាចផ្គត់ផ្គង់ការនាំចេញទៅក្រៅប្រទេសឱ្យបានកាន់តែច្រើន។




(៨) ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច៖ ធនាគារ ARDB ដែលជាធនាគារពាណិជ្ជបម្រើគោលនយោបាយរបស់រាជរដ្ឋាភិបាលបាននិងកំពុងដើរតួនាទីក្នុងការចូលរួមស្តារ និងជំរុញវិស័យកសិកម្ម តាមរយៈការផ្តល់ហិរញ្ញប្បទានដល់ប្រជាកសិករនិងគាំទ្រដល់បណ្តាតួអង្គដែលស្ថិតនៅក្នុងខ្សែប្រវាក់ផលិតកម្មកសិកម្មឱ្យកាន់តែទូលំទូលាយ ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ច លើកកម្ពស់ផលិតភាពការងារ និងការបង្កើតការងារសមរម្យ។




(១៣) សកម្មភាពបរិស្ថាន៖ ធនាគារ ARDB បានជំរុញការផ្តល់ហិរញ្ញប្បទានបៃតង ដល់អតិថិជនគោលដៅដែលពាក់ព័ន្ធនឹងវិស័យដូចជា៖ ការដាំដុះបន្លែសុវត្ថិភាព ផ្ទះបៃតង ប្រព័ន្ធស្រោចស្រពដំណាំ ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ឡជីវឧស្ម័ន ប្រព័ន្ធដំណាំមិនដាំផ្ទាល់ដី ប្រព័ន្ធអាក្វាផូនិក និងគម្រោងអាកាសធាតុបៃតង ជាដើម។




(១៧) ភាពជាដៃគូ ដើម្បីសម្រេចគោលដៅ៖ ធនាគារ ARDB បានសហការជាមួយដៃគូយុទ្ធសាស្ត្រអន្តរជាតិជាច្រើនដូចជា៖ ធនាគារពិភពលោក (WB), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្ម (IFAD) ដើម្បីចូលរួមគាំទ្រលើវិស័យកសិកម្ម តាមរយៈការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ។ បន្ថែមពីនេះ ធនាគារ ARDB ក៏បានសហការជាមួយដៃគូយុទ្ធសាស្ត្រ និងដៃគូយុទ្ធសាស្ត្រអាជីវកម្មថ្នាក់ជាតិមួយចំនួនទៀតផងដែរ ដើម្បីជំរុញឱ្យការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកាន់តែប្រសើរឡើង។






# ផ្នែកទី៥ – ព្រឹត្តិការណ៍សំខាន់ៗរបស់ ARDB

## ៥.១ ការរួមចំណែកនៅក្នុងការងារសង្គម



### កម្មវិធីវិភាគទានសប្បុរសធម៌ជូនមូលនិធិគន្ធបុប្ផាកម្ពុជា

ធនាគារ ARDB បានរៀបចំកម្មវិធីចុះអនុស្សរណៈយោគយល់គ្នាស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម សម្រាប់កៀរគរ និងទទួលវិភាគទានសប្បុរសធម៌ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និង ឯកឧត្តមបណ្ឌិត ចន ណារិទ្ធ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម និងជាប្រធានលេខាធិការដ្ឋានមូលនិធិគន្ធបុប្ផាកម្ពុជា។

## ៥.២ កិច្ចប្រជុំថ្នាក់តំបន់ និងទស្សនកិច្ចសិក្សា




### កិច្ចប្រជុំស្តីពី “ការលើកកម្ពស់សេវាហិរញ្ញវត្ថុឌីជីថលដែលជាយន្តការដ៏សំខាន់សម្រាប់បរិយាប័ន្នហិរញ្ញវត្ថុដល់ប្រជាកសិករ”

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២, ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានដឹកនាំគណៈប្រតិភូទៅចូលរួមវេទិកាគោលនយោបាយតំបន់ស្តីពី “ការលើកកម្ពស់សេវាហិរញ្ញវត្ថុឌីជីថលដែលជាយន្តការដ៏សំខាន់សម្រាប់បរិយាប័ន្នហិរញ្ញវត្ថុដល់ប្រជាកសិករ” ដែលបានសហការរៀបចំឡើងដោយសមាគមឥណទានជនបទ និងកសិកម្មអាស៊ីប៉ាស៊ីហ្វិក (Asia-Pacific Rural and Agricultural Credit Association-APRACA) និងធនាគារ Agribank នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

## កម្មវិធីអង្គសន្និបាទ 7th World Congress

ឯកឧត្តមបណ្ឌិត សឹង រេត និង ឯកឧត្តម បាន លឹម អគ្គនាយករងនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានអញ្ជើញចូលរួមក្នុងអង្គសន្និបាទ 7th World Congress on Rural and Agricultural Finance នៅទីក្រុង Morelia, ប្រទេសម៉ិកស៊ិក ដែលមានសមាជិកចូលរួមចំនួនប្រមាណជាង ២០០នាក់ មកពី ២៧ ប្រទេសកាលពីថ្ងៃទី២៣ ដល់ ២៥ ខែវិច្ឆិកា ឆ្នាំ២០២២។ ឯកឧត្តមបណ្ឌិត សឹង រេត ក៏បានធ្វើបទបង្ហាញលើប្រធានបទ "Accelerating Green Finance to Agriculture and Food Sector in Cambodia: The Role of ARDB ដល់អង្គសន្និបាតទាំងមូលផងដែរ។



## កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩៣

ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) ដែលជាសមាជិកក្រុមប្រឹក្សាភិបាលនៃ ADFIAP បានដឹកនាំសហការី ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាលើកទី៩៣ នាព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ នៅប្រទេសហ្វីលីពីន។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩៣ នេះ ត្រូវបានរៀបចំឡើងដោយមានរបៀបវារៈដូចខាងក្រោម៖

១. ការអនុម័តលើរបាយការណ៍កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩២,
២. ការធ្វើបច្ចុប្បន្នភាពលើការអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៩២,
៣. ការស្នើសុំការអនុម័តលើ៖ សមាជិកថ្មី, ផែនការថវិកាឆ្នាំ២០២៣, វេទិកាអន្តរជាតិសម្រាប់ CEO ឆ្នាំ២០២៣,
៤. ការអនុម័តលើសមាជិកក្រុមប្រឹក្សាភិបាលថ្មី និង
៥. ការអនុម័តលើរបាយការណ៍របស់អគ្គលេខាធិការដ្ឋាន ADFIAP។








## កិច្ចប្រជុំ ADFIAP

ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានចែករំលែកបទពិសោធន៍ក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើបទបង្ហាញលើប្រធានបទ តួនាទីរបស់ស្ថាប័នផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, បច្ចេកវិទ្យា, និងកសិកម្ម និងធ្វើជាវាគ្មិនក្នុងកិច្ចពិភាក្សាក្នុងកិច្ចប្រជុំ Association of Development Financing Institutions in Asia and the Pacific (ADFIAP) ឆ្នាំ២០២២ លើកទី៤៥ នារសៀលថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ប្រទេសហ្វីលីពីន។ ឯកឧត្តមបណ្ឌិត បានលើកឡើងអំពីគោលនយោបាយអន្តរាគមន៍របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងអំឡុងពេល និងក្រោយវិបត្តិកូវីដ-១៩ ក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ និងបង្ហាញអំពីតួនាទីរបស់ធនាគារ ARDB ក្នុងកិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាលកម្ពុជា។



## ទស្សនកិច្ចសិក្សានៅក្រុមហ៊ុន Thai Agro Exchange Co., Ltd

ឯកឧត្តមបណ្ឌិត កៅ ថាច បានដឹកនាំក្រុមការងារបំពេញទស្សនកិច្ចសិក្សាស្វែងយល់ និងដកស្រង់បទពិសោធន៍ការងារនៅក្រុមហ៊ុន Thai Agro Exchange Co., Ltd ដែលគ្រប់គ្រងផ្សារបោះដុំផលិតផលកសិកម្ម TALAAD THAI ជាពិសេសបន្លែ-ផ្លែឈើក្នុងស្រុក និងពីបរទេស នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២។ ផ្សារបោះដុំ TALAAD THAI ជាផ្សារបោះដុំធំជាងគេនៅប្រទេសថៃហើយដើរតួរនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលរវាងតម្រូវការ និងការផ្គត់ផ្គង់ផលិតផលបន្លែ-ផ្លែឈើបោះដុំ ប្រកបដោយគុណភាព សម្រាប់ចែកចាយបន្តដល់អ្នកប្រើប្រាស់ ហើយក៏ជាទីផ្សារមួយដ៏សំខាន់សម្រាប់ប្រជាកសិករដាំដុះបន្លែ-ផ្លែឈើ ផងដែរ។

## ទស្សនកិច្ចសាខាធនាគារ Agribank ប្រទេសវៀតណាម

នាថ្ងៃទី២១-២២ ខែកក្កដា ឆ្នាំ២០២២, ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម(ARDB)បានដឹកនាំគណៈប្រតិភូចុះបំពេញទស្សនកិច្ចសិក្សានៅសាខាធនាគារ Agribank ក្នុងខេត្ត Hai Phong នៃប្រទេសវៀតណាម ដើម្បីស្វែងយល់អំពីប្រតិបត្តិការរបស់សាខាធនាគារ Agribank ហើយគណៈប្រតិភូក៏បានចុះស្វែងយល់ផ្ទាល់ និងដកស្រង់បទពិសោធន៍លើការអនុវត្តការងារផ្តល់ឥណទានជាក្រុមការធ្វើប្រតិបត្តិការធនាគារដោយប្រើប្រាស់រថយន្តជាការិយាល័យចល័តដល់ទីជនបទ របស់សាខាធនាគារ Agribank ព្រមទាំងបានចុះសិក្សាដល់ទីកន្លែងកសិដ្ឋានចិញ្ចឹមជ្រូក និងកសិដ្ឋានដាំដុះបន្លែសុវត្ថិភាពក្នុង Greenhouse ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើបផងដែរ។




## ទស្សនកិច្ចសិក្សាធនាគារជាតិវៀតណាម

នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២, ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានដឹកនាំគណៈប្រតិភូទៅបំពេញទស្សនកិច្ចសិក្សានៅធនាគារវៀតណាមសម្រាប់ការអនុវត្តគោលនយោបាយសង្គម (VietNam Bank for Social Policies-VBSP) នៅទីក្រុងហាណូយ ប្រទេសវៀតណាម។ ឯកឧត្តមបណ្ឌិត កៅ ថាច និងគណៈប្រតិភូ ក៏បានជួបសម្តែងការគួរសមជាមួយលោក Huynh Van Thuan អគ្គនាយករងនៃធនាគារវៀតណាមសម្រាប់ការអនុវត្តគោលនយោបាយសង្គម (VBSP) និងថ្នាក់ដឹកនាំ ហើយនៅក្នុងជំនួបនេះដែរ ថ្នាក់ដឹកនាំនៃធនាគារទាំងពីរ បានផ្លាស់ប្តូរនូវបទពិសោធន៍ការងាររបស់ធនាគារទាំងពីរដែលមានបេសកកម្ម និងមុខងារភារកិច្ចប្រហាក់ប្រហែលគ្នា ក្នុងនាមជាធនាគារបម្រើគោលនយោបាយ ក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ជាពិសេសការអភិវឌ្ឍវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ។ ជាងនេះទៀត ឯកឧត្តមបណ្ឌិត កៅ ថាច ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក Huynh Van Thuan និងថ្នាក់ដឹកនាំនៃធនាគារ VBSP ដែលបានអនុញ្ញាតឱ្យគណៈប្រតិភូនៃធនាគារARDBបានជួបប្រជុំស្វែងយល់និងដកបទពិសោធន៍លើការអនុវត្តការងារផ្តល់ឥណទានខ្នាតតូច និងឥណទានជាក្រុមដល់ប្រជាកសិករនៅទីជនបទរបស់ធនាគារ VBSP។






## កិច្ចពិភាក្សាជាមួយអគ្គនាយក Philippine Guarantee Corporation

ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានដឹកនាំសហការីជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Alberto E. Pascual អគ្គនាយក (President and CEO) Philippine Guarantee Corporation នៅស្នាក់ការកណ្តាលនៃ Philippine Guarantee Corporation ប្រទេសហ្វីលីពីន នារសៀលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ដោយមានការសម្របសម្រួលដោយ ADFIAP។ ជំនួបនេះ គឺធ្វើឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍ក្នុងការផ្តល់ការធានាឥណទានដោយបានពិភាក្សាជាពិសេសការធានាឥណទានក្នុងវិស័យកសិកម្ម និងការកំណត់នូវម៉ូដែលអាជីវកម្ម និងយុទ្ធសាស្ត្រដែលសមស្រប។ បន្ថែមពីនេះ ស្ថាប័នទាំងពីរ ក៏បានពិនិត្យលទ្ធភាពក្នុងការស្វែងរកការពង្រីកកិច្ចសហប្រតិបត្តិការ។



## កិច្ចពិភាក្សាជាមួយអគ្គនាយក LandBank of the Philippines

ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានដឹកនាំសហការីជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកស្រី Cecilia C. Borromeo អគ្គនាយកធនាគារ (President and CEO) LandBank of the Philippines នៅស្នាក់ការកណ្តាលនៃ LandBank of the Philippines ប្រទេសហ្វីលីពីន នាព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ដោយមានការសម្របសម្រួលដោយ ADFIAP។ ជំនួបនេះ គឺធ្វើឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍ក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ (Development Financing) ដោយមានការធ្វើបទបង្ហាញ ក្រោមមូលបទ Sustainability Growth Vision, Innovation of Sustainable Business Model and Strategies, និង Data-Driven in Agriculture និងស្វែងរកការពង្រីកកិច្ចសហប្រតិបត្តិការរវាងធនាគារទាំងពីរ។



## កម្មវិធីសិក្ខាសាលាស្តីពីហិរញ្ញប្បទានបៃតង

ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងលោកបណ្ឌិត Prasun Kumar Das អគ្គលេខាធិការ សមាគមឥណទានកសិកម្ម និងជនបទ នៃតំបន់អាស៊ីប៉ាស៊ីហ្វិក (Asia-Pacific Rural and Agricultural Credit Association-APRACA) បានចូលរួមបើកកម្មវិធីសិក្ខាសាលាស្តីពីហិរញ្ញប្បទានបៃតងក្នុងវិស័យកសិកម្មនិងចំណីអាហារ “Green and Sustainable Finance to Agriculture and Food Sector” ដែលរៀបចំដោយ APRACA ពីថ្ងៃទី១១ ដល់ ១៧ ខែកញ្ញា ឆ្នាំ២០២២ នៅទីក្រុងបាងកក ប្រទេសថៃ។ កម្មវិធីសិក្ខាសាលានេះមានគោលបំណងពង្រឹងសមត្ថភាពដល់បុគ្គលិកធនាគារ ARDB អំពីការរៀបចំ Green Finance Taxonomy, ស្វែងយល់ពីឧបករណ៍ហិរញ្ញវត្ថុបៃតង និងការអនុវត្តហិរញ្ញប្បទានបៃតងនៅកម្ពុជា តាមរយៈការដកស្រង់បទពិសោធន៍ពីបណ្តាប្រទេសផ្សេងៗ។



## កិច្ចពិភាក្សាជាមួយអគ្គនាយក BAAC

ឯកឧត្តមបណ្ឌិត កៅ ថាច បានដឹកនាំក្រុមការងារ ARDB ជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយអគ្គនាយកធនាគារ BAAC (Bank for Agriculture and Agricultural Cooperatives) នៅស្នាក់ការកណ្តាលនៃ BAAC ក្រុងបាងកក ប្រទេសថៃ នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២។ ជំនួបនេះ គឺធ្វើឡើងក្នុងគោលបំណងពង្រីកកិច្ចសហប្រតិបត្តិការរវាងធនាគារទាំងពីរលើការផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ការងារពាក់ព័ន្ធនឹងផ្តល់ឥណទានគាំទ្រដល់វិស័យកសិកម្ម នាពេលអនាគតផងដែរ។



# ៥.៣ ការចូលរួមអន្តរាគមន៍ក្នុងវិស័យស្រូវ-អង្ករ

## ការចុះវាយតម្លៃផលប៉ះពាល់ដំណាំស្រូវដោយគ្រោះទឹកជំនន់

ក្នុងរយៈពេល ០៤ ថ្ងៃគិតចាប់ពីថ្ងៃទី១២ ដល់ទី១៥ ខែតុលា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត កៅ ថាច បានអញ្ជើញចុះសួរសុខទុក្ខអតិថិជន ចំនួន៦០ គ្រួសារ ដែលកំពុងទទួលរងគ្រោះមហន្តរាយដោយសារទឹកជំនន់ បានបំផ្លាញផលដំណាំស្រូវ និងបន្លែផ្សេងៗដែលជិតទទួលផល និងកំពុងប្រមូលផល នៅក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ និងកំពង់ធំ។ ដោយមើលឃើញពីការលំបាកនេះ, ឯកឧត្តមបណ្ឌិត បានអនុញ្ញាតអោយបងប្អូនពិនិត្យលទ្ធភាពដាក់ពាក្យស្នើសុំពន្យារការសងប្រាក់ដើម និង/ឬ អាចដាក់ពាក្យស្នើសុំខ្ចីបន្ថែមសម្រាប់យកមកប្រើប្រាស់នៅពេលទឹកស្រកចុះវិញ។ ជាការរួមចំណែកដោះស្រាយបញ្ហារបស់បងប្អូនសហគមន៍, ឯកឧត្តមបណ្ឌិត បានធ្វើការចែកជូននូវអង្ករ ត្រីខ មី ទឹកត្រី ទឹកស៊ីអ៊ីវ និងថវិកាមួយចំនួនផងដែរ។



## ការចូលរួមអន្តរាគមន៍នៅពេលតម្លៃស្រូវធ្លាក់ថ្លៃ

ឯកឧត្តមបណ្ឌិត កៅ ថាច អមដោយអគ្គនាយករង និងសហការី បានដឹកនាំកិច្ចប្រជុំបន្ទាន់ ជាមួយតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងម្ចាស់ក្រុមហ៊ុននាំចេញអង្ករដើម្បីពិភាក្សា (១) លើបញ្ហាតម្លៃស្រូវនៅតាមតំបន់ខេត្តសក្តានុពលរួមមាន៖ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ ខេត្តកំពង់ធំ និងខេត្តព្រៃវែង ជាដើម, (២) ស្ថានភាពនៃការនាំចេញអង្ករកម្ពុជា។ ក្នុងកិច្ចពិភាក្សានេះផងដែរម្ចាស់រោងម៉ាស៊ីនកិនស្រូវបានធ្វើបច្ចុប្បន្នភាពនៃស្ថានភាពប្រមូលទិញស្រូវ និងតម្លៃស្រូវ នៅតាមតំបន់គោលដៅ និងម្ចាស់ក្រុមនាំចេញអង្ករ បានធ្វើបច្ចុប្បន្នភាពនៃទីផ្សារអង្ករអន្តរជាតិ និងការបញ្ជាទិញពីប្រទេសចិន និងសហភាពអឺរ៉ុបជាដើម។ ជាចុងបញ្ចប់នៃកិច្ចពិភាក្សា ឯកឧត្តមបណ្ឌិត កៅ ថាច បានស្នើឱ្យបណ្តារោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញអង្ករ បន្តជួយទិញស្រូវប្រជាកសិករក្នុងតម្លៃសមរម្យនិងជំរុញការនាំចេញអង្ករកម្ពុជា ព្រមទាំងកំណត់នូវតំបន់នៃការប្រមូលទិញស្រូវពីប្រជាកសិករ, នារសៀលថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២។



# របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងរបាយការណ៍របស់សវនករឯករាជ្យ

# ទំនាក់ទំនង

023 220 810 | 023 220 811

info@ardb.com.kh

www.ardb.com.kh

ARDB Bank

អគារលេខ 9-13 ផ្លូវលេខ 7 សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
# និង
# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច

# ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

# មាតិកា


| | ទំព័រ |
|---|---|
| **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** | **១ - ៤** |
| **របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច** | |
| **របាយការណ៍របស់សវនករឯករាជ្យ** | **៥ - ៨** |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៩ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ | ១០ |
| របាយការណ៍បម្រែបម្រួលមូលធន | ១១ - ១២ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៣ - ១៤ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ១៥ - ៨៤ |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍របស់ខ្លួនព្រមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ហៅកាត់ថា "ធនាគារ") គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

## អំពីធនាគារ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម គឺជាអង្គភាពដែលគ្រប់គ្រងដោយរដ្ឋាភិបាលទាំងស្រុង ដែលបានបង្កើតឡើងតាមអនុក្រឹត្យ (អនុក្រឹត្យលេខ ០១ អនក្រ.បក) ក្នុងគោលបំណងលើកកម្ពស់សកម្មភាពកសិកម្ម និងសេដ្ឋកិច្ចជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យជីវភាពប្រជាពលរដ្ឋតាមជនបទដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានភាពល្អប្រសើរឡើង។ ធនាគារបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co. ៣៩៨២Et/១៩៩៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៨។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ធនាគារបានចុះបញ្ជីរួចរាល់ជាមួយនឹងវិញ្ញាបនបត្រលេខ ០៣២៧ ដែលចេញដោយក្រសួងពាណិជ្ជកម្ម។ ធនាគារបានទទួលអាជ្ញាបណ្ណពីធនាគារជាតិ នៃ កម្ពុជា ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេសដែលមានសុពលភាពជាអចិន្ត្រៃយ៍នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៧។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ធនាគារបានទទួលអាជ្ញាបណ្ណពីធនាគារជាតិ នៃ កម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងនៅអគារលេខ ៩-១៣ ផ្លូវ ៧ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ធនាគារមាននិយោជិតចំនួន ២៥២នាក់ (ឆ្នាំ២០២១៖ មាននិយោជិតចំនួន ២២៣នាក់)។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ធនាគារ គឺចូលរួមគ្រប់ទិដ្ឋភាពទាំងអស់នៃធនាគារពាណិជ្ជ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធក្នុងប្រទេសកម្ពុជា។

ពុំមានការផ្លាស់ប្តូរណាមួយគួរឱ្យកត់សម្គាល់ទៅលើលក្ខណៈនៃសកម្មភាពអាជីវកម្មចម្បងក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

## លទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងភាគលាភ

លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងស្ថានភាពនៃប្រតិបត្តិការអាជីវកម្មរបស់ធនាគារគិតត្រឹមកាលបរិច្ឆេទនេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ។

ក្រុមប្រឹក្សាភិបាលពុំបានផ្តល់អនុសាសន៍ក្នុងការទូទាត់ភាគលាភណាមួយសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នេះឡើយ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| ឯកឧត្តម រស់ សីលវ៉ា | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ |
| ឯកឧត្តមបណ្ឌិត កៅ ថាច | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ |
| ឯកឧត្តម សាន វិសាល | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ |
| ឯកឧត្តម ទាន សុសេរី | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ |
| ឯកឧត្តម ឃី កុសល | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ |
| លោក ប៉ាក សេរីវឌ្ឍនា | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ |
| ឯកឧត្តម ចាន់ សីហា | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ |

## មន្ត្រីត្រួតពិនិត្យរដ្ឋ

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក ដេត វាសនា | មន្ត្រីត្រួតពិនិត្យរដ្ឋ |

## គណៈគ្រប់គ្រង

សមាជិកគណៈគ្រប់គ្រងរបស់ធនាគារក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង |
|---|---|
| ឯកឧត្តមបណ្ឌិត កៅ ថាច | អគ្គនាយក |
| ឯកឧត្តម ចាន់ សីហា | អគ្គនាយករង |
| ឯកឧត្តម ប៉ិច សានី | អគ្គនាយករង |
| ឯកឧត្តម បាន លឹម | អគ្គនាយករង |
| លោក សុខ ឧស្សាហ៍ | ប្រធានលេខាធិការដ្ឋាន |
| លោកស្រី សាន គីមមួយ | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| លោក នេត បញ្ញា | ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងប្រតិបត្តិតាម |
| លោកស្រី អ៊ឹង ពិសិដ្ឋណាលីន | ប្រធាននាយកដ្ឋានធនធានមនុស្ស និងបណ្តុះបណ្តាល |
| លោកស្រី ឈុន សុខា | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ |
| លោក ខែក ពិសិដ្ឋ | ប្រធាននាយកដ្ឋានប្រតិបត្តិការ និងកិច្ចការរតនាគារ |
| លោក មិត្ត ប៊ុន | ប្រធាននាយកដ្ឋានឥណទាន |
| លោក គុយ បញ្ញា | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្ម និងយុទ្ធសាស្ត្រ |
| លោក ថាត ចាន់ថាគៀ | ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ |
| លោក ណែម ឡុន | ប្រធាននាយកដ្ឋានតាមដានការប្រើប្រាស់ឥណទាន និងប្រមូលបំណុល |
| លោក ឈិន ឌីណា | ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាធនាគារឌីជីថល |
| លោក ជិន ជ័យាបុត្រ | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ និងទំនាក់ទំនងសាធារណៈ |
| លោក សុខុម ដារ៉ារដ្ឋ | ប្រធាននាយកដ្ឋានគ្រប់គ្រងសាខា និងប្រតិបត្តិការចល័ត |
| លោក អ៊ុច ចន្ថា | ប្រធានគណៈកម្មការគាំទ្រគោលនយោបាយរបស់រដ្ឋាភិបាល |
| លោកស្រី ផៃ សាម៉ែន | ប្រធានអង្គភាពលទ្ធកម្មសាធារណៈ |
| លោកស្រី អៀង ច័ន្ទគ្រីស្នា | ប្រធានអង្គភាពសម្របសម្រួលគម្រោង (PCU) |
| លោក ថៃ ហ្សឺឌី | ប្រធាននាយកដ្ឋានហិរញ្ញប្បទានបៃតង |
| លោក សុង ឈាង | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យាទទួលបន្ទុកការិយាល័យហេដ្ឋារចនាសម្ព័ន្ធបណ្តាញ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនស្នងការគណនេយ្យ ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុង និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានធនាគារជាភាគី ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍តាមរយៈមធ្យោបាយទិញយកភាគហ៊ុន ឬសញ្ញាបណ្ណពីធនាគារ ឬអង្គភាពសាជីវកម្មណាមួយផ្សេងទៀតឡើយ។

នៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់របស់ធនាគារបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលរួមបញ្ចូលក្នុងសមតុល្យសរុបដែលបានទទួល ឬដល់កាលកំណត់សង និងត្រូវទទួលដោយក្រុមប្រឹក្សាភិបាលដូចដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬដោយសាជីវកម្មពាក់ព័ន្ធជាមួយនឹងធនាគារដែលមានសមាជិកអភិបាលនោះជាសមាជិក ឬក៏ជាមួយធនាគារដែលសមាជិកអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុក្រៅពីបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវគ្រប់ទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុ និងរបាយការណ៍លំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមការអនុវត្តក្របខណ្ឌរបាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញ។ នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

១. អនុម័តនូវគោលនយោបាយគណនេយ្យឱ្យបានសមស្របដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") និងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

២. អនុលោមតាមគោលការណ៍លាតត្រដាងដែលតម្រូវដោយស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយពីតម្រូវការទាំងនោះក្នុងការបង្ហាញនូវភាពទិដ្ឋភាពពិត និងត្រឹមត្រូវ ហើយធានាឱ្យបានថាការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ

៣. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនអាចសន្មតថាធនាគារនឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នាពេលអនាគតបន្តទៀតបាន និង

៥. ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព ចូលរួមលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថារាល់ការសម្រេចចិត្ត និង/ឬ សេចក្តីណែនាំនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ធនាគារ ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់និងរកឱ្យឃើញនូវការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល អមជាមួយរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ រួមជាមួយនឹងកំណត់សម្គាល់នានា ត្រូវបានរៀបចំឡើងយ៉ាងសមស្រប និងផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

**ឯកឧត្តម រស់ សីលវ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

Grant Thornton

# របាយការណ៍របស់សវនករឯករាជ្យ

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

**ជូនចំពោះភាគហ៊ុនិករបស់**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម**

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ហៅកាត់ថា"ធនាគារ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ព្រមជាមួយកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ និងសេចក្តីពន្យល់ព័ត៌មានផ្សេងទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") និងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា ("NBC")។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកនៃការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមានឯករាជ្យភាពពីធនាគារ ដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបានគឺគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំឡើយ ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្ម ព្រមទាំងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងទុកថាបានរៀបចំរួចរាល់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

គណនេយ្យករជំនាញ និងសវនករប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។
រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

Grant Thornton

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំមិនផ្តល់សេចក្តីសន្និដ្ឋានក្នុងទម្រង់នៃការធានាបែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើផ្អែកតាមការងារសវនកម្មដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តនៃព័ត៌មានផ្សេងទៀតនេះ យើងខ្ញុំតម្រូវឱ្យរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការប្រាស្រ័យទាក់ទងពីបញ្ហានេះទៅកាន់ក្រុមប្រឹក្សាភិបាល និងឆ្លើយតបទៅលើបញ្ហានោះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

## បញ្ហាផ្សេងៗ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងៗទៀត ដែលបានបង្ហាញពីមតិយោបល់ត្រឹមត្រូវតែលើកលែងលើរបាយការណ៍ទាំងនោះនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពធនាគារក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## ការទទួលខុសត្រូវរបស់សវនករនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូលដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជានឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលកើតមានឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

Grant Thornton

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារនោះទេ។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យ និងផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ធនាគារ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យធនាគារមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

Grant Thornton

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

Grant Thornton

ព្រះរាជាណាចក្រកម្ពុជា
ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
GRANT THORNTON (CAMBODIA) LIMITED
ក្រសួងពាណិជ្ជកម្ម

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | | | | (បានបញ្ជាក់ឡើងវិញ) | | (បានបញ្ជាក់ឡើងវិញ) | |
|---|---|---|---|---|---|---|---|
| | | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
| | កំណត់សម្គាល់ | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៦ | **៧.៤៣៤.២៩២** | **៣០.៦០៦.៩៨០** | ៧.១៣៧.៣៥៤ | ២៩.០៧៧.៥៨០ | ៤៨.៥៩០.៧៦៩ | ១៩៦.៥៤៩.៦៦១ |
| ប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ | ៧ | **២៧៤.៤៩៥** | **១.១៣០.០៩៦** | ៣១៦.៨២៧ | ១.២៩០.៧៥៣ | - | - |
| ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ | ៨ | **១៣.៨៥៨.៦៣៦** | **៥៧.០៥៦.០០៤** | ៩.៧៩៨.៣០៨ | ៣៩.៩១៨.៣០៧ | ៩.៤០២.១២៦ | ៣៨.០៣១.៦០០ |
| ឥណទាន និងបុរេប្រទានផ្តល់ជូន អតិថិជន-សុទ្ធ | ៩ | **៣៦៣.៧៧៦.២១៩** | **១.៤៩៧.៦៦៦.៦៩៤** | ២៧៩.៣១២.៩៣៨ | ១.១៣៧.៩២០.៩០៩ | ២៣២.៩០៥.៦០៩ | ៩៤២.១០៣.១៨៨ |
| ទ្រព្យសម្បត្តិបានរឹបអូស | ១០ | **៤.៣១២.៦៣៨** | **១៧.៧៥៥.១៣១** | ៣.៧៤៨.២៣៤ | ១៥.២៧០.៣០៥ | ៣.៧៧៣.៨៨៧ | ១៥.២៦៥.៣៧៣ |
| ទ្រព្យសកម្មផ្សេងៗ | ១១ | **១.៨៧២.៧១១** | **៧.៧០៩.៩៥១** | ៦៣៦.៩២០ | ២.៥៩៤.៨១២ | ៤៦៩.២៨៤ | ១.៨៩៨.២៥៤ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | **១៤.០១០.៥៣៦** | **៥៧.៦៨១.៣៧៧** | ៨.៦៧១.៦៩៨ | ៣៥.៣២៨.៤៩៨ | ៤.១០៥.១៧៨ | ១៦.៦០៥.៤៤៥ |
| ទ្រព្យសកម្មពន្ធពន្យារ-សុទ្ធ | ១៩(ក) | **១.៥៣៤.៤២១** | **៦.៣១៧.២១១** | - | - | - | - |
| ទ្រព្យសកម្មអរូបី | ១៣ | **១.៧៨៨.៩៧១** | **៧.៣៦៥.១៩៤** | ៩៥២.២៥៤ | ៣.៨៧៩.៤៨៣ | ៩៨៣.៦៤៦ | ៣.៩៧៨.៨៤៨ |
| **ទ្រព្យសកម្មសរុប** | | **៤០៨.៨៦២.៩១៩** | **១.៦៨៣.២៨៨.៦៣៨** | ៣១០.៥៧៤.៥៣៣ | ១.២៦៥.២៨០.៦៤៧ | ៣០០.២៣០.៤៩៩ | ១.២១៤.៤៣២.៣៦៩ |
| **បំណុល និងមូលធន** | | | | | | | |
| **បំណុល** | | | | | | | |
| ប្រាក់បញ្ញើពីអតិថិជន | ១៤ | **៨.០៣៨.០៩១** | **៣៣.០៩២.៨២១** | ៥.៧៥៣.៦៥៧ | ២៣.៤៤០.៣៩៩ | ៥.៣០១.០៨៦ | ២១.៤៤២.៨៩៣ |
| ប្រាក់បញ្ញើពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ១៥ | **៦.០០៨** | **២៤.៧៣៥** | ២.៦២៧ | ១០.៧០២ | ៤.៦៦១ | ១៨.៨៥៤ |
| ប្រាក់កម្ចី | ១៦ | **២៣៦.៦០០.៨៤៨** | **៩៧៤.០៨៥.៦៩១** | ១៥៦.៥៩១.៥៨៤ | ៦៣៧.៩៥៤.១១៣ | ១៩៤.៣៦៣.៤១៨ | ៧៨៦.២០០.០២៦ |
| បំណុលបន្ទាប់បន្សំ | ១៧ | **១.០៤៤.០៨៤** | **៤.២៩៨.៤៩៤** | ១.០៤៤.០៨៤ | ៤.២៥៣.៥៩៨ | ១.០៤៤.០៨៤ | ៤.២២៣.៣២០ |
| បំណុលផ្សេងៗ | ១៨ | **២.៦៨៩.៩០៨** | **១១.០៧៤.៣៤៤** | ៩៩៧.០៥០ | ៤.០៦១.៩៨២ | ៧៦៣.៥០២ | ៣.០៨៨.៣៦៥ |
| សំវិធានធនសម្រាប់កិច្ចសន្យាធានាហិរញ្ញវត្ថុ | | **៦.០៩៤** | **២៥.០៨៩** | ៣៣.៣៥៤ | ១៣៥.៨៨៤ | ១៤.៩០៤ | ៦០.២៨៧ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ១៩(ខ) | **៩៦៨.៦២៧** | **៣.៩៨៧.៨៣៧** | ១.៥១៩.៨៣៦ | ៦.១៩១.៨១២ | ១៥.៧៣៧ | ៦៣.៦៥៦ |
| បំណុលពន្ធពន្យារ-សុទ្ធ | ១៩(ក) | - | - | ១.២០៧.៨១៦ | ៤.៩២០.៦៤២ | ១.៩២៣.៩០៣ | ៧.៧៨២.១៨៨ |
| **បំណុលសរុប** | | **២៤៩.៣៥៣.៦៦០** | **១.០២៦.៥៨៩.០១១** | ១៦៧.១៥០.០០៨ | ៦៨០.៩៦៩.១៣២ | ២០៣.៤៣១.២៩៥ | ៨២២.៨៧៩.៥៨៩ |
| **មូលធន** | | | | | | | |
| ដើមទុន | ២០ | **១៣៧.២៣៣.៦០៦** | **៥៥៦.៤៧៥.៣៣០** | ៩៦.៥០៤.៦៤៦ | ៣៩០.៦២៧.០០០ | ៩៦.៥០៤.៦៤៦ | ៣៩០.៦២៧.០០០ |
| ដើមទុនផ្សេងៗ | ២១ | **(៤.៥១១.៦៩៩)** | **(១៧.៨០៧.៦១៩)** | ៣៥.១៣២.៥៣៣ | ១៤៣.៥៧៤.៨៨៦ | (១១.២៨០.២២៧) | (៤៥.៤២៩.២៤៥) |
| ដើមទុនបម្រុងទុក | ២២ | **១.៧៨៦.៧៧៩** | **៧.២៦០.៥១២** | ១.៤០៦.១៦៤ | ៥.៦៩៣.៥២១ | ១.២០២.៤២៤ | ៤.៨៦៣.៤៨៤ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ២៣ | **១២.០១៦.៣៧៣** | **៤៩.៤៧១.៤០៨** | ១២.០២០.៤០៧ | ៤៨.៥០៧.៩៣៤ | ១៤.៩៣០.៣៣៩ | ៦០.៣៤៥.៥៣៧ |
| ប្រាក់ចំណេញរក្សាទុក/(ខាតបង្គរ) | | **១២.៩៨៤.២០០** | **៥៣.០៨៤.៤៥៨** | (១.៦៣៩.២២៥) | (៦.៦៨១.៤៨០) | (៤.៥៥៧.៩៧៨) | (១៨.៥៥៤.៩៦៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | | - | **៨.៧១៥.៥៣៨** | - | ២.៥៨៩.៦៥៤ | - | (២៩៩.០២៨) |
| **មូលធនសរុប** | | **១៥៩.៥០៩.២៥៩** | **៦៥៦.៦៩៩.៦២៧** | ១៤៣.៤២៤.៥២៥ | ៥៨៤.៣១១.៥១៥ | ៩៦.៧៩៩.២០៤ | ៣៩១.៥៥២.៧៨០ |
| **បំណុល និងមូលធនសរុប** | | **៤០៨.៨៦២.៩១៩** | **១.៦៨៣.២៨៨.៦៣៨** | ៣១០.៥៧៤.៥៣៣ | ១.២៦៥.២៨០.៦៤៧ | ៣០០.២៣០.៤៩៩ | ១.២១៤.៤៣២.៣៦៩ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ

| | | | | | (បានបញ្ជាក់ឡើងវិញ) |
|---|---|---|---|---|---|
| | | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | កំណត់សម្គាល់ | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ចំណូលការប្រាក់ | ២៤ | **២១.០៦៦.១១៨** | **៨៦.០៩៧.២២៤** | ១៧.៦២៣.៩៧៣ | ៧១.៦៩៤.៣២២ |
| ចំណាយការប្រាក់ | ២៥ | **(១៣០.៧០៧)** | **(៥៣៤.២០០)** | (៩២.០៥៦) | (៣៧៤.៤៨៤) |
| **ចំណូលការប្រាក់សុទ្ធ** | | **២០.៩៣៥.៤១១** | **៨៥.៥៦៣.០២៤** | ១៧.៥៣១.៩១៧ | ៧១.៣១៩.៨៣៨ |
| ចំណូលផ្សេងៗ | ២៦ | **៥១៩.១៨៧** | **២.១២១.៩១៧** | ៥៤៧.៣៨៥ | ២.២២៦.៧៦២ |
| **ចំណូលប្រតិបត្តិការសរុប** | | **២១.៤៥៤.៥៩៨** | **៨៧.៦៨៤.៩៤១** | ១៨.០៧៩.៣០២ | ៧៣.៥៤៦.៦០០ |
| ចំណាយបុគ្គលិក | ២៧ | **(៥.៨៩៩.១១៦)** | **(២៤.១០៩.៦៨៧)** | (៤.២៨៥.៨៨៦) | (១៧.៤៣៤.៩៨៤) |
| ចំណាយប្រតិបត្តិការផ្សេងៗ | ២៨ | **(៤.៥៧៩.២៤៦)** | **(១៨.៧១៥.៣៧៨)** | (២.៥១៤.៤៩៦) | (១០.២២៨.៩៧០) |
| **ចំណាយប្រតិបត្តិការសរុប** | | **(១០.៤៧៨.៣៦២)** | **(៤២.៨២៥.០៦៥)** | (៦.៨០០.៣៨២) | (២៧.៦៦៣.៩៥៤) |
| **ចំណេញប្រតិបត្តិការមុនឱនភាព** | | **១០.៩៧៦.២៣៦** | **៤៤.៨៥៩.៨៧៧** | ១១.២៧៨.៩២០ | ៤៥.៨៨២.៦៤៧ |
| សំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ | ៣១(ខ) | **២.៤៧១.៨៩០** | **១០.១០២.៦១៤** | (៩.៩៣២.៨៣០) | (៤០.៤០៦.៧៥២) |
| **ប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | **១៣.៤៤៨.១២៦** | **៥៤.៩៦២.៤៩១** | ១.៣៤៦.០៩០ | ៥.៤៧៥.៨៩៥ |
| អត្ថប្រយោជន៍ពន្ធលើប្រាក់ចំណូល/(ចំណាយ) | ១៩(គ) | **១.១៧៥.២៩៩** | **៤.៨០៣.៤៤៧** | (១.៣៣៧.២៦៩) | (៥.៤៤០.០១០) |
| **ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | **១៤.៦២៣.៤២៥** | **៥៩.៧៦៥.៩៣៨** | ៨.៨២១ | ៣៥.៨៨៤ |
| ចំណូលលម្អិតផ្សេងៗ - | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **៥.៦២៥.៨៨៤** | - | ២.៨៨៨.៦៨៤ |
| **ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | **១៤.៦២៣.៤២៥** | **៦៥.៣៩១.៨២២** | ៨.៨២១ | ២.៩២៤.៥៦៨ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុន | | ដើមទុនផ្សេងៗ | | ដើមទុនបម្រុងទុក | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៩៦.៥០៤.៦៤៦ | ៣៩០.៦២៧.០០០ | ៣៥.១៣២.៥៣៣ | ១៤៣.៥៧៤.៨៨៦ | ១.៤០៦.១៦៤ | ៥.៦៩៣.៥២១ | ១២.០២០.៤០៧ | ៤៨.៥០៧.៩៣៤ | (១.៦៣៩.២២៥) | (៦.៦៨១.៤៨០) | ២.៥៨៩.៦៥៤ | ១៤៣.៤២៤.៥២៥ | ៥៨៤.៣១១.៥១៥ |
| *ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន* | | | | | | | | | | | | | |
| ផ្ទេរទៅដើមទុនដែលបានបង់ (កំណត់សម្គាល់ ២១) | ៤០.៧២៨.៩៦០ | ១៦៥.៨៤៨.៣៣០ | (៤០.៧២៨.៩៦០) | (១៦៥.៨៤៨.៣៣០) | - | - | - | - | - | - | - | - | - |
| ដើមទុនបន្ថែមក្នុងអំឡុងការិយបរិច្ឆេទ (កំណត់សម្គាល់ ២១) | - | - | ១.០៨៤.៧២៨ | ៤.៤៦៥.៨២៥ | - | - | - | - | - | - | - | ១.០៨៤.៧២៨ | ៤.៤៦៥.៨២៥ |
| ការស្តារឡើងវិញនៃចំណូលការប្រាក់ពីឥណទានមិនមានដំណើរការ (កំណត់សម្គាល់ ២២) | - | - | - | - | ៣៨០.៦១៥ | ១.៥៦៦.៩៩១ | - | - | - | - | - | ៣៨០.៦១៥ | ១.៥៦៦.៩៩១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណលើទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | - | - | (៤.០៣៤) | (១៦.៦០៨) | - | - | - | (៤.០៣៤) | (១៦.៦០៧) |
| | ៤០.៧២៨.៩៦០ | ១៦៥.៨៤៨.៣៣០ | (៣៩.៦៤៤.២៣២) | (១៦១.៣៨២.៥០៥) | ៣៨០.៦១៥ | ១.៥៦៦.៩៩១ | (៤.០៣៤) | (១៦.៦០៨) | - | - | - | ១.៤៦១.៣០៩ | ៦.០១៦.២០៩ |
| *ចំណូលលម្អិតសរុប* | | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | - | - | ១៤.៦២៣.៤២៥ | ៥៩.៧៦៥.៩៣៨ | ៥.៦២៥.៨៨៤ | ១៤.៦២៣.៤២៥ | ៦៥.៣៩១.៨២១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | ៩៨០.០៨២ | - | - | - | - | ៩៨០.០៨២ |
| | - | - | - | - | - | - | - | ៩៨០.០៨២ | ១៤.៦២៣.៤២៥ | ៥៩.៧៦៥.៩៣៨ | ៥.៦២៥.៨៨៤ | ១៤.៦២៣.៤២៥ | ៦៦.៣៧១.៩០៣ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១៣៧.២៣៣.៦០៦** | **៥៥៦.៤៧៥.៣៣០** | **(៤.៥១១.៦៩៩)** | **(១៧.៨០៧.៦១៩)** | **១.៧៨៦.៧៧៩** | **៧.២៦០.៥១២** | **១២.០១៦.៣៧៣** | **៤៩.៤៧១.៤០៨** | **១២.៩៨៤.២០០** | **៥៣.០៨៤.៤៥៨** | **៨.២១៥.៥៣៨** | **១៥៩.៥០៩.២៥៩** | **៦៥៦.៦៩៩.៦២៧** |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍បម្រែបម្រួលមូលធន (ត)

| | ដើមទុន | | ដើមទុនផ្សេងៗ | | ដើមទុនបម្រុងទុក | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ខាតបង្គរ | | លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៩៦.៥០៤.៦៤៦ | ៣៩០.៦២៧.០០០ | (១១.២៨០.២២៧) | (៤៥.៤២៩.២៤៥) | ១.២០២.៤២៤ | ៤.៨៦៣.៤៨៤ | ១៤.៩៣០.៣៣៩ | ៦០.៣៤៥.៥៣៧ | (៤.៥៥៧.៩៧៨) | (១៨.៥៥៤.៩៦៨) | (២៩៩.០២៨) | ៩៦.៧៩៩.២០៤ | ៣៩១.៥៥២.៧៨០ |
| *ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន* | | | | | | | | | | | | | |
| ផ្ទេរពីប្រាក់កម្ចី-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ -ASDF (កំណត់សម្គាល់ ២១) | - | - | ៣៦.៩៣៧.៥០០ | ១៥០.៤០៩.៥០០ | - | - | - | - | - | - | - | ៣៦.៩៣៧.៥០០ | ១៥០.៤០៩.៥០០ |
| វិភាគទានដើមទុនបន្ថែមក្នុងអំឡុងការិយបរិច្ឆេទ (កំណត់សម្គាល់ ២១) | - | - | ៣.៧៩១.៤៦០ | ១៥.៤៣៨.៨៣០ | - | - | - | - | - | - | - | ៣.៧៩១.៤៦០ | ១៥.៤៣៨.៨៣០ |
| ការស្តារឡើងវិញនៃចំណូលការប្រាក់ពីឥណទានមិនមានដំណើរការ (កំណត់សម្គាល់ ២១) | - | - | ១៥៨.៧០០ | ៦៤៦.៥៤៤ | - | - | - | - | - | - | - | ១៥៨.៧០០ | ៦៤៦.៥៤៤ |
| ការស្តារឡើងវិញនៃចំណូលការប្រាក់ពីឥណទានមិនមានដំណើរការ (កំណត់សម្គាល់ ២២) | - | - | - | - | ២០៣.៧៤០ | ៨៣០.០៣៧ | - | - | - | - | - | ២០៣.៧៤០ | ៨៣០.០៣៧ |
| ផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅប្រាក់ចំណេញរក្សាទុក (កំណត់សម្គាល់ ២៣) | - | - | - | - | - | - | (២.៩០៩.៩៣២) | (១១.៨៣៧.៦០៣) | ២.៩០៩.៩៣២ | ១១.៨៣៧.៦០៣ | - | - | - |
| ដើមទុនបន្ថែមក្នុងអំឡុងការិយបរិច្ឆេទ (កំណត់សម្គាល់ ២១) | - | - | ៥.៥២៥.១០០ | ២២.៥០៩.២៥៧ | - | - | - | - | - | - | - | ៥.៥២៥.១០០ | ២២.៥០៩.២៥៧ |
| | - | - | ៤៦.៤១២.៧៦០ | ១៨៩.០០៤.១៣១ | ២០៣.៧៤០ | ៨៣០.០៣៧ | (២.៩០៩.៩៣២) | (១១.៨៣៧.៦០៣) | ២.៩០៩.៩៣២ | ១១.៨៣៧.៦០៣ | - | ៤៦.៦១៦.៥០០ | ១៨៩.៨៣៤.១៦៨ |
| *ចំណូលលម្អិតសរុប* | | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | - | - | ៨.៨២១ | ៣៥.៨៨៥ | - | ៨.៨២១ | ៣៥.៨៨៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | ២.៨៨៨.៦៨២ | - | ២.៨៨៨.៦៨៣ |
| | - | - | - | - | - | - | - | - | ៨.៨២១ | ៣៥.៨៨៥ | ២.៨៨៨.៦៨២ | ៨.៨២១ | ២.៩២៤.៥៦៨ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៩៦.៥០៤.៦៤៦ | ៣៩០.៦២៧.០០០ | ៣៥.១៣២.៥៣៣ | ១៤៣.៥៧៤.៨៨៦ | ១.៤០៦.១៦៤ | ៥.៦៩៣.៥២១ | ១២.០២០.៤០៧ | ៤៨.៥០៧.៩៣៤ | (១.៦៣៩.២២៥) | (៦.៦៨១.៤៨០) | ២.៥៨៩.៦៥៤ | ១៤៣.៤២៤.៥២៥ | ៥៨៤.៣១១.៥១៥ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍លំហូរសាច់ប្រាក់

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ៤.២) | (បានបញ្ជាក់ឡើងវិញ) សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | **១៤.៦២៣.៤២៥** | **៥៩.៧៦៥.៩៣៨** | ៨.៨២១ | ៣៥.៨៨៤ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| ចំណាយពន្ធលើប្រាក់ចំណូល | ១៩(គ) | **(១.១៧៥.២៩៩)** | **(៤.៨០៣.៤៤៧)** | ១.៣៣៧.២៦៩ | ៥.៤៤០.០១០ |
| រំលស់លើទ្រព្យសកម្មរូបី និងអរូបី | ១២ និង ១៣ | **១.១១៩.១៦២** | **៤.៥៧៤.០១៣** | ៤៩២.២៤៦ | ២.០០២.៤៥៧ |
| ការខាតបង់ឱនភាពតម្លៃលើទ្រព្យសម្បត្តិដែលបានរឹបអូស | ១០ | **២៣៩.២៧២** | **៩៧៧.៩០៥** | ៩១.៩១៦ | ៣៧៣.៩១៤ |
| សំវិធានធននៃការខាតបង់ឱនភាពតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | | **(២.៤៧១.៨៨៩)** | **(១០.១០២.៦១០)** | ៩.៩៣២.៨៣០ | ១៩.២៧៧.៥៩៣ |
| ចំណូលការប្រាក់សុទ្ធ | ២៤ និង ២៥ | **(២០.៩៣៥.៤១១)** | **(៨៥.៥៦៣.០២៤)** | (១៧.៥៣១.៩១៧) | (៧១.៣១៩.៨៣៨) |
| ខាតលើអត្រាប្តូររូបិយប័ណ្ណ | | **(១២៤.៥០៥)** | **(៥០៨.៨៥២)** | (៨៨២.៧៦០) | (៣.៥៩១.០៦៨) |
| **ខាតប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **(៨.៧២៥.២៤៦)** | **(៣៥.៦៦០.០៧៧)** | (៦.៥៥១.៩៩៥) | (៤៧.៧៨១.០៤៨) |
| បម្រែបម្រួលសុទ្ធក្នុង៖ | | | | | |
| ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ | | **(៤.០៦០.៣២៨)** | **(១៦.៥៩៤.៥៦១)** | (៣៩៦.១៨២) | (១.៦១១.៦៦៨) |
| ឥណទាន និងបុរេប្រទានផ្តល់ជូនអតិថិជន | | **(៤០.៩២១.៦៥៦)** | **(១៦៧.២៤៦.៨០៨)** | (៥០.៨៩២.៤១៨) | (២០៧.០៣០.៣៥៦) |
| ទ្រព្យសកម្មផ្សេងៗ | | **(១.២៨៦.៥៤៦)** | **(៥.២៥៨.១១៤)** | (២៦៨.៣៩១) | (១.០៩១.៨១៤) |
| ប្រាក់បញ្ញើពីអតិថិជន | | **២.២៤៤.៥១០** | **៩.១៧៣.៣១២** | ៤៥១.២០៧ | ១.៨៣៥.៥១០ |
| ប្រាក់បញ្ញើពីធនាគារផ្សេងៗ | | **៣.៣៨១** | **១៣.៨១៨** | (២.០៣៤) | (៨.២៧៤) |
| បំណុលផ្សេងៗ | | **២.៤០៨.៩៤៤** | **៩.៨៤៥.៣៥៤** | ២៣៣.៥៤៨ | ៩៥០.០៧៣ |
| **សាច់ប្រាក់សុទ្ធទទួលបានសកម្មភាពប្រតិបត្តិការ** | | **(៥០.៣៣៦.៩៤១)** | **(២០៥.៧២៧.០៧៦)** | (៥៧.៤២៥.៨៦៥) | (២៥៤.៧៣៧.៥៧៧) |
| ចំណូលការប្រាក់ដែលបានទទួល | | **(១៩.៩៣០.៧៦៧)** | **(៨១.៤៥៧.០៤៥)** | ១៧.៥៩០.០៧០ | ៧១.៥៥៦.៤០៥ |
| ចំណាយការប្រាក់ដែលបានបង់ | | **(១.១៦៩.០២៦)** | **(៤.៧៧៧.៨០៨)** | (៧៦.១០៤) | (៣០៩.៥៩១) |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | | **(២.៨៣៤.២៣៣)** | **(១១.៥៨៣.៥១០)** | (៥៤៩.២៥៧) | (២.២៣៤.៣៧៧) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | **(៧៤.២៧០.៩៦៧)** | **(៣០៣.៥៤៥.៤៣៩)** | (៤០.៤៦១.១៥៦) | (១៨៥.៧២៥.១៤០) |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | **(៦.៣៨១.៩៧៩)** | **(២៦.០៨៣.១៤៨)** | (៥.០២៧.៣៧៤) | (២០.៤៥១.៣៥៧) |
| ការទិញទ្រព្យសកម្មអរូបី | ១៣ | **(៩១២.៧៣៨)** | **(៣.៧៣០.៣៦០)** | - | - |
| ប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ | | **៤០.០៤៥** | **១៦៣.៦៦៤** | (៣២០.០០០) | (១.៣០១.៧៦០) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(៧.២៥៤.៦៧២)** | **(២៩.៦៤៩.៨៤៤)** | (៥.៣៤៧.៣៧៤) | (២១.៧៥៣.១១៧) |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍លំហូរសាច់ប្រាក់(ត)

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | (បានបញ្ជាក់ឡើងវិញ) សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ដើមទុនបន្ថែមក្នុងអំឡុងការិយបរិច្ឆេទ | | **១.០៨៤.៧២៨** | **៤.៤៣៣.២៨៣** | ៣.៧៩១.៤៦០ | ១៥.៤២៣.៦៥៩ |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | **៨១.១៦៧.៦៩៨** | **៣៣១.៧៣២.៣៨២** | ៣៣.៨៣៨ | ១៣៧.៦៥៣ |
| ការស្តារឡើងវិញនៃចំណូលការប្រាក់ពីឥណទាន មិនមានដំណើរការ | | **(៤២៣.០៦២)** | **(១.៧២៩.០៥៤)** | ១៣៧.៤៧៧ | ៥៥៩.២៥៦ |
| ការស្តារឡើងវិញនូវប្រាក់ដើមពីឥណទានមិនមានដំណើរការ | ២១ | - | - | ១៥៨.៧០០ | ៦៤៥.៥៩២ |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញវត្ថុ** | | **៨១.៨២៩.៣៦៤** | **៣៣៤.៤៣៦.៦១១** | **៤.១២១.៤៧៥** | **១៦.៧៦៦.១៦០** |
| | | | | | |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **៣០៣.៧២៥** | **១.២៤១.៣២៨** | (៤១.៦៨៧.០៥៥) | (១៦៩០.៧១២.០៩៧) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | **៧.១៦៧.៩៣៩** | **២៩.២០២.១៨៦** | ៤៨.៨៥៤.៩៩៤ | ១៩៧.៦១៨.៤៥០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **៣១៧.៣២៨** | - | ២២.២៩៥.៨៣៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | ៦ | **៧.៤៧១.៦៦៤** | **៣០.៧៦០.៨៤២** | ៧.១៦៧.៩៣៩ | ២៩.២០២.១៨៦ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## ១. ព័ត៌មានទូទៅ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ហៅកាត់ថា "ធនាគារ) គឺជាអង្គភាពដែលគ្រប់គ្រងដោយរដ្ឋាភិបាលទាំងស្រុង ដែលបានបង្កើតឡើងតាមអនុក្រឹត្យ (អនុក្រឹត្យលេខ ០១ អនក្រ.បក) ក្នុងគោលបំណងលើកកម្ពស់សកម្មភាពកសិកម្ម និងសេដ្ឋកិច្ចជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យជីវភាពប្រជាពលរដ្ឋតាមជនបទដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានភាពល្អប្រសើរឡើង។ ធនាគារបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co. ៣៩៤២Et/១៩៩៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៨។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ធនាគារបានចុះបញ្ជីរួចរាល់ជាមួយនឹងវិញ្ញាបនបត្រលេខ ០៣២៧ ពីក្រសួងពាណិជ្ជកម្ម។ ធនាគារបានទទួលអាជ្ញាបណ្ណពីធនាគារជាតិ នៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេសដែលមានសុពលភាពជាអចិន្ត្រៃយ៍នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៧។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ធនាគារបានទទួលអាជ្ញាបណ្ណពីធនាគារជាតិ នៃ កម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងនៅអគារលេខ ៩-១៣ ផ្លូវ ៧ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ធនាគារមាននិយោជិតចំនួន ២៥២នាក់ (ឆ្នាំ២០២១៖ មាននិយោជិតចំនួន ២២៣នាក់)។

### សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ធនាគារ គឺចូលរួមរាល់ទិដ្ឋភាពទាំងអស់នៃធនាគារពាណិជ្ជ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធក្នុងប្រទេសកម្ពុជា។

ពុំមានការផ្លាស់ប្តូរណាមួយគួរឱ្យកត់សម្គាល់ទៅលើលក្ខណៈនៃសកម្មភាពអាជីវកម្មចម្បងក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

## ២. របាយការណ៍ដែលអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺដូចគ្នាទៅនឹងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("IFRSs") ដូចដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ("IASB") ពីព្រោះ IFRS ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាជាតិគណនេយ្យដែលបច្ចុប្បន្នត្រូវបានគេស្គាល់ថាជានិយ័តករគណនេយ្យ និងសវនកម្ម ("ACAR") ដោយមិនមានការកែប្រែទៅលើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានេះឡើយ។

## ៣. ស្តង់ដារថ្មី ឬស្តង់ដារដែលបានកែសម្រួល និងការបកស្រាយ

### ៣.១ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយទៅលើស្តង់ដារដែលមានស្រាប់ ដែលបានអនុវត្តដោយធនាគារ

នៅដើមការិយបរិច្ឆេទនៃហិរញ្ញវត្ថុបច្ចុប្បន្ន ធនាគារបានអនុវត្តវិសោធនកម្មថ្មីទៅលើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលចាំបាច់សម្រាប់ការិយបរិច្ឆេទចាប់ផ្តើម ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២។

គណៈគ្រប់គ្រងបានវាយតម្លៃថាការអនុម័តនៃវិសោធនកម្មទៅលើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ពុំមានផលប៉ះពាល់ជាសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារឡើយ។

- កិច្ចសន្យាស្មុគស្មាញ - ចំណាយក្នុងការបំពេញកិច្ចសន្យា (វិសោធនកម្មទៅលើ CIAS ៣៧)
- ឯកសារយោងទាក់ទងនឹងក្របខណ្ឌទស្សនទាន (វិសោធនកម្មទៅលើ CIFRS ៣)
- ទ្រព្យសម្បត្តិ និងបរិក្ខារ៖ សាច់ប្រាក់ទទួលបានមុនការប្រើប្រាស់ដែលបានគ្រោងទុក (វិសោធនកម្មទៅលើ CIAS ១៦)

## ៣.២ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយទៅលើស្តង់ដារដែលមានស្រាប់ ដែលមិនទាន់មានប្រសិទ្ធភាព និងមិនទាន់អនុវត្តជាមុនដោយធនាគារ

នាកាលបរិច្ឆេទនៃការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ស្តង់ដារថ្មីមួយចំនួន ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព និងវិសោធនកម្មទៅលើស្តង់ដារដែលមានស្រាប់ និងការបកស្រាយត្រូវបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។

ស្តង់ដារ និងវិសោធនកម្មផ្សេងៗ ដែលមិនទាន់មានប្រសិទ្ធភាពនៅឡើយ និងមិនទាន់បានអនុវត្តជាមុនដោយធនាគាររួមមាន៖

- ចំណាត់ថ្នាក់បំណុលរយៈពេលខ្លី និងបំណុលរយៈពេលវែង (វិសោធនកម្មទៅលើ CIAS ១)
- ការលាតត្រដាងគោលនយោបាយគណនេយ្យ (វិសោធនកម្មទៅលើ CIAS ១ និង ការអនុវត្តរបាយការណ៍ CIFRS ២)
- និយមន័យគណនេយ្យប៉ាន់ស្មាន (វិសោធនកម្មទៅលើ CIAS ៨)
- បំណុលភតិសន្យាក្នុងការលក់ និងជួលបន្ត (វិសោធនកម្មទៅលើ CIFRS ១៦)
- កិច្ចព្រមព្រៀងបំណុលរយៈពេលវែង (វិសោធនកម្មទៅលើ CIAS ១)

វិសោធនកម្មទាំងនេះ គឺមិនត្រូវបានរំពឹងទុកថានឹងមានផលប៉ះពាល់ខ្លាំងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារនៅក្នុងអំឡុងពេលនៃការអនុវត្តដំបូងនេះទេ។

## ៤. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះបានកំណត់ដូចខាងក្រោម។ គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តយ៉ាងជាប់លាប់នៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ។

### ៤.១ មូលដ្ឋាននៃការបង្ហាញ

គណៈគ្រប់គ្រងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើលទ្ធភាពនៃការទូទាត់សង។ ព័ត៌មានអំពីទ្រព្យសកម្ម និងបំណុលរយៈពេលខ្លី និងរយៈពេលវែងត្រូវបានលាតត្រដាងនៅក្នុងផ្នែកនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។ ការវិនិយោគផ្សេងៗ ទ្រព្យសកម្មអរូបី ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មពន្ធពន្យារ គឺជាទ្រព្យសកម្មរយៈពេលវែង។

### ៤.២ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារធនាគារមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់យករូបិយប័ណ្ណដុល្លារអាមេរិកជារូបិយប័ណ្ណរបស់ធនាគារសម្រាប់គោលបំណងនៃការវាស់វែង និងបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងស្ថានការណ៍របស់ធនាគារ។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសក្រៅពីដុល្លារអាមេរិក ត្រូវបានប្តូរទៅជាដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់ទូទៅនាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុ ដែលកំណត់ជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិក នៅកាលបរិច្ឆេទនៃរបាយការណ៍ត្រូវបានប្តូរទៅជាដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃរបាយការណ៍នោះ។ លម្អៀងពីការប្តូររូបិយប័ណ្ណ ដែលបានកើតឡើងពីការប្តូរប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងៗ។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាខ្មែររៀល ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរួមបញ្ចូលទាំងស្រុងដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ និងត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ ដុល្លារអាមេរិក ដែលបានចេញសេចក្តីប្រកាសដោយអគ្គនាយកដ្ឋានពន្ធដារ ("GDT")។ គិតចាប់ពីខែមករា ឆ្នាំ២០២១ អគ្គនាយដ្ឋានពន្ធដារបានធ្វើសេចក្តីណែនាំឱ្យប្រើប្រាស់អត្រាប្តូរប្រាក់ដែលបានចេញផ្សាយដោយធនាគារជាតិ នៃ កម្ពុជា៖

| | **ឆ្នាំ២០២២** | ឆ្នាំ២០២១ |
|---|---|---|
| អត្រាប្តូរប្រាក់ជាមធ្យម* | **៤.០៨៧** | ៤.០៧៤ |
| អត្រាប្តូរប្រាក់ចុងគ្រា | **៤.១១៧** | ៤.០៦៨ |

*អត្រាប្តូរប្រាក់ជាមធ្យមត្រូវបានគណនាដោយផ្អែកលើអត្រាប្តូរប្រាក់ចុងគ្រាប្រចាំខែក្នុងអំឡុងការិយបរិច្ឆេទ

អត្រាប្តូរប្រាក់ទាំងនេះ មិនត្រូវបានធ្វើសវនកម្ម និងមិនត្រូវបានបកស្រាយថា ជាតំណាងនៃប្រាក់ដុល្លារអាមេរិក ឬដែលត្រូវបាន ឬអាចនឹងត្រូវបាន ឬអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគតតាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតឡើយ។

## ៤.៣ ការបង្គត់តួលេខ

តួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ប្រាក់ដុល្លារអាមេរិកត្រូវបានបង្គត់ឱ្យគៀកបំផុតទៅនឹងដុល្លារអាមេរិក ហើយសម្រាប់ខ្មែររៀល ("KHR") ត្រូវបានបង្គត់ឱ្យគៀកបំផុតទៅនឹងពាន់រៀល (KHR'000)។

## ៤.៤ ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

### (១) ការទទួលស្គាល់ និងការវាស់វែងដំបូង

ធនាគារទទួលស្គាល់ជាលើកដំបូងនូវឥណទាន និងបុរេប្រទាន ប្រាក់កម្ចី និងបំណុលបន្ទាប់បន្សំ នៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ។ រាល់ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ (រាប់បញ្ចូលទាំងវិធីសាស្ត្រក្នុងការទិញ និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ) ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទជួញដូរនៃកាលបរិច្ឆេទដែលធនាគារក្លាយជាភាគីកិច្ចសន្យាសំវិធានធននៃឧបករណ៍នោះ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របបូក ហើយសម្រាប់សមាសធាតុដែលមិនមែន FVTPL ចំណាយប្រតិបត្តិការដែលរួមចំណែកដោយផ្ទាល់ក្នុងការទិញ ឬអនុម័ត។

### (២) ការធ្វើចំណាត់ថ្នាក់

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

នៅពេលទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែង៖ ថ្លៃដើមបានរំលស់ FVOCI ឬ FVTPL។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់តាមថ្លៃដើមបានរំលស់ ប្រសិនបើវាមានលក្ខខណ្ឌដូចខាងក្រោម ហើយមិនត្រូវបានកំណត់តាម FVTPL៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានរក្សាក្រោមគំរូអាជីវកម្មក្នុងគោលបំណងគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុធ្វើឱ្យមានការកើនឡើងនូវលំហូរសាច់ប្រាក់ដែលបានកំណត់ទាក់ទងនឹង SPPI។

ឧបករណ៍បំណុលត្រូវបានវាស់វែងនៅ FVOCI លុះត្រាតែវាបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL៖

- ទ្រព្យសកម្មត្រូវបានកាន់កាប់នៅក្នុងគំរូអាជីវកម្មក្នុងគោលបំណងទទួលបានទាំងការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុធ្វើឱ្យមានការកើនឡើងនូវលំហូរសាច់ប្រាក់ដែលទាក់ទងនឹងដែលបានកំណត់ចំពោះតែ SPPI។

ការទទួលស្គាល់ការវិនិយោគមូលធនដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ធនាគារមិនអាចធ្វើការជ្រើសរើស ដើម្បីបង្ហាញពីការផ្លាស់ប្តូរជាបន្តបន្ទាប់នៃតម្លៃសមស្របនៅក្នុងគណនីចំណូលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃការវិនិយោគ។

ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទាំងអស់ ត្រូវបានចាត់ថ្នាក់ដោយធ្វើការវាស់វែងតាម FVTPL។

លើសពីនេះទៀត ការទទួលស្គាល់ដំបូង ធនាគារអាចកំណត់ចុងក្រោយនូវទ្រព្យសកម្មហិរញ្ញវត្ថុ ប្រសិនបើមិនបានបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមថ្លៃដើមបានរំលស់ ឬតាម FVOCI ឬតាមFVTPL ប្រសិនបើអនុវត្តដូច្នេះ ត្រូវបានលុបបំបាត់ ឬកាត់បន្ថយគួរឱ្យកត់សម្គាល់នូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងអាចកើតមានឡើង។

**ការវាយតម្លៃគំរូអាជីវកម្ម**
ធនាគារធ្វើការវាយតម្លៃពីគោលបំណងនៃគំរូអាជីវកម្មដែលទ្រព្យសកម្មត្រូវបានកាន់កាប់នៅកម្រិតផលបត្រ ព្រោះវាឆ្លុះបញ្ចាំងយ៉ាងល្អបំផុតពីមធ្យោបាយដែលអាជីវកម្មត្រូវបានគ្រប់គ្រង និងព័ត៌មាន ដែលបានផ្តល់ជូនគណៈគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់កម្រិតផលបត្រ និងការអនុវត្តជាក់ស្តែងនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា ការរក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ភាពស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលបំណុល ដែលផ្តល់មូលនិធិដល់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម

- របៀបនៃការវាយតម្លៃនូវការអនុវត្តរបស់កម្រិតផលបត្រ និងវិធីរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ធនាគារ

- ហានិភ័យដែលជះឥទ្ធិពលដល់ការអនុវត្តគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរក្សាទុកនៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យទាំងនោះ

- របៀបដែលប្រធានគ្រប់គ្រងអាជីវកម្មទទួលបានសំណង (ឧទាហរណ៍ថាតើសំណងគឺផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្ម ដែលបានគ្រប់គ្រង ឬលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និងភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់ក្នុងការិយបរិច្ឆេទពីមុន ហើយមូលហេតុនៃការលក់ទាំងនេះ និងការរំពឹងទុកពីសកម្មភាពលក់នាពេលអនាគត។ ទោះយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានពិចារណាតែមួយផ្នែកទេ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃរួម ដែលធនាគារបានបញ្ជាក់អំពីគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ គឺអាចសម្រេចបាន និងរបៀបនៃការទទួលស្គាល់លំហូរសាច់ប្រាក់។

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកាន់កាប់សម្រាប់ការធ្វើពាណិជ្ជកម្ម ឬគ្រប់គ្រង និងការអនុវត្តដែលត្រូវបានវាយតម្លៃ ដោយផ្អែកលើមូលដ្ឋានតម្លៃសមស្រប ដែលត្រូវបានវាស់វែងនៅ FVTPL ពីព្រោះទ្រព្យសកម្មទាំងនោះមិនមែនរក្សាទុកសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនទុកសម្រាប់ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ទ្រព្យសកម្មទាំងនោះឡើយ។

***ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់***
សម្រាប់គោលបំណងនៃការវាយតម្លៃនេះ 'ប្រាក់ដើម' ត្រូវបានកំណត់ជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ដំបូង។ 'ការប្រាក់' ត្រូវបានកំណត់ជាតម្លៃតបស្នងមួយសម្រាប់តម្លៃនៃពេលវេលា និងសម្រាប់ហានិភ័យដែលឥណទានពាក់ព័ន្ធនឹងសមតុល្យប្រាក់ដើមដែលនៅជាប់ជំពាក់ក្នុងអំឡុងការិយបរិច្ឆេទជាក់លាក់មួយ និងសម្រាប់ហានិភ័យ និងការចំណាយលើប្រាក់កម្ចីមូលដ្ឋានផ្សេងទៀត (ឧទាហរណ៍ ហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងគម្លាតប្រាក់ចំណេញ។

ក្នុងការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺជា SPPI ឬទេ ធនាគារពិចារណាលើលក្ខខណ្ឌកិច្ចសន្យានៃឧបករណ៍នោះ។ ការវាយតម្លៃនេះរួមបញ្ចូល ទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានកិច្ចសន្យាមានកាលកំណត់ដែលអាចផ្លាស់ប្តូរពេលវេលា ឬសមតុល្យលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលមិនអាចបំពេញតាមលក្ខខណ្ឌបាននោះទេ។

ក្នុងការវាយតម្លៃ ធនាគារពិចារណាលើ៖
- ព្រឹត្តិការណ៍យថាហេតុ ដែលអាចផ្លាស់ប្តូរសមតុល្យ និងពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខណៈពិសេសអានុភាព
- លក្ខខណ្ឌចំណាយបង់មុន និងការពន្យារពេល
- លក្ខខណ្ឌ ដែលកំណត់ការទាមទាររបស់ធនាគារចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មដែលបានបញ្ជាក់ (ឧទាហរណ៍៖ ឥណទានដែលមានទ្រព្យបញ្ចាំជាក់លាក់) និង
- លក្ខណៈដែលកែតម្រូវនូវតម្លៃនៃពេលវេលា (ឧទាហរណ៍៖ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់)

**ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់**

ក្នុងករណីខ្លះឥណទានត្រូវបានធ្វើឡើងដោយធនាគារ ដែលត្រូវបានធានាដោយកំណត់នូវទ្រព្យបញ្ចាំរបស់អ្នកខ្ចី ទៅលើការទាមទាររបស់ធនាគារចំពោះលំហូរសាច់ប្រាក់នៃទ្រព្យបញ្ចាំមូលដ្ឋាន (ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់)។ ធនាគារអនុវត្តការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទានមានទ្រព្យបញ្ចាំជាក់លាក់ទាំងនោះ បានបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់ SPPI ដែរឬទេ។ ជាធម្មតា ធនាគារពិចារណាលើព័ត៌មានមួយចំនួននៅពេលធ្វើការវិនិច្ឆ័យ ដូចខាងក្រោមនេះ៖

- ថាតើការរៀបចំកិច្ចសន្យាមានកំណត់សមតុល្យ និងកាលបរិច្ឆេទជាក់លាក់នៃការទូទាត់ជាសាច់ប្រាក់នៃឥណទាន
- តម្លៃសមស្របនៃទ្រព្យបញ្ចាំទាក់ទងនឹងសមតុល្យទ្រព្យសកម្មហិរញ្ញវត្ថុដែលបានធានា
- សមត្ថភាព និងឆន្ទៈរបស់អ្នកខ្ចីក្នុងការទូទាត់តាមកិច្ចសន្យាទោះបីមានឱនភាពតម្លៃលើទ្រព្យបញ្ចាំ
- ថាតើអ្នកខ្ចី គឺជាបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ៗ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ធនាគារលើការខាតបង់ទ្រព្យសកម្មទាក់ទងនឹងឥណទានដែលមានទ្រព្យបញ្ចាំពេញលេញ
- ទំហំដែលទ្រព្យបញ្ចាំតំណាងឱ្យផ្នែកទាំងអស់ ឬផ្នែកសំខាន់នៃទ្រព្យសកម្មរបស់អ្នកខ្ចី និង
- ថាតើធនាគារនឹងទទួលបានអត្ថប្រយោជន៍ពីការកើនឡើងណាមួយលើមូលដ្ឋានទ្រព្យសកម្ម។

**ការធ្វើចំណាត់ថ្នាក់ឡើងវិញ**

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញឡើយ បន្ទាប់ពីមានការទទួលស្គាល់ដំបូង លើកលែងតែក្នុងការិយបរិច្ឆេទបន្ទាប់ពីធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួនក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

### (៣) ការឈប់ទទួលស្គាល់

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលដែលសិទ្ធិនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យាពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកាលកំណត់ ឬផ្ទេរសិទ្ធិក្នុងការទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលរាល់ហានិភ័យ និងតម្លៃតបស្នងនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរ ឬដែលធនាគារមិនបានផ្ទេរ ឬរក្សាទុកនូវរាល់ហានិភ័យ និងតម្លៃតបស្នងនៃភាពជាម្ចាស់កម្មសិទ្ធិ ហើយក៏មិនរក្សាបាននូវការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុនេះឡើយ។

ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងសមតុល្យយោងរបស់ទ្រព្យសកម្ម (ឬសមតុល្យយោងដែលត្រូវបានបែងចែកទៅជាផ្នែកនៃទ្រព្យសកម្មដែលបានឈប់ទទួលស្គាល់) និងផលបូកនៃ (ក) តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មី ដែលទទួលបានដកបំណុលថ្មីដែលបានកំណត់) និង (ខ) ចំណេញ ឬខាតបង្គរដែលបានទទួលស្គាល់នៅក្នុង OCI ដែលត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ និងខាត។

**បំណុលហិរញ្ញវត្ថុ**

ធនាគារឈប់ទទួលស្គាល់នូវបំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្នុងកិច្ចសន្យាត្រូវបានរំសាយ ឬលុបចោល ឬផុតកាលកំណត់។

### (៤) ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារធ្វើការវាយតម្លៃថាតើលំហូរសាច់ប្រាក់នៃទ្រព្យសកម្ម ដែលបានកែប្រែមានភាពខុសគ្នាច្រើនឬទេ។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានចាត់ទុកថាផុតកាលកំណត់។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានឈប់ទទួលស្គាល់ (សូមមើលកំណត់សម្គាល់ (គ)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃដើមប្រតិបត្តិការដែលមានលក្ខណៈគ្រប់គ្រាន់។ កម្រៃសេវា ដែលទទួលបានណាមួយជាផ្នែកនៃការកែប្រែ ត្រូវបានកត់ត្រាដូចខាងក្រោម៖

- កម្រៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងកម្រៃសេវាដែលតំណាងឱ្យការទូទាត់តាមថ្លៃដើមប្រតិបត្តិការ ត្រូវបានរួមបញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- កម្រៃសេវាផ្សេងៗត្រូវបានរួមបញ្ចូលក្នុងគណនីចំណេញ និងខាត ដែលជាផ្នែកនៃចំណេញ ឬខាតពីការឈប់ទទួលស្គាល់។
- ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែតម្រូវ នៅពេលដែលអ្នកខ្ចីជួបការលំបាកផ្នែកហិរញ្ញវត្ថុ ដូច្នេះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីប្រមូលបានមកវិញនូវលក្ខខណ្ឌកិច្ចសន្យាដើមជាអតិបរមា ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាច្រើន។ ប្រសិនបើធនាគារមានផែនការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ នោះទ្រព្យសកម្មត្រូវពិចារណាជាមុនថាតើផ្នែកណាមួយនៃទ្រព្យសកម្ម គួរតែត្រូវបានលុបចោលមុនពេលមានការប្រែប្រួលនឹងកើតមានឡើង (សូមមើលគោលនយោបាយនៃការលុបចោលទ្រព្យសកម្មខាងក្រោម)។ វិធីសាស្ត្រនេះបានប៉ះពាល់ដល់លទ្ធផលនៃការវាយតម្លៃបរិមាណ និងមានន័យថាលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ មិនបានបំពេញតាមករណីបែបនេះទេ។
- ប្រសិនបើការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ ឬFVOCI ដែលមិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុនោះទេ នោះធនាគារនឹងគណនាឡើងវិញនូវសមតុល្យយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម ហើយទទួលស្គាល់លទ្ធផលកែតម្រូវជាចំណេញ ឬខាតដែលបានកែប្រែក្នុងគណនីចំណេញ និងខាត។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាអណ្តែត អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលត្រូវបានប្រើដើម្បីគណនាការកើនឡើង ឬការខាតបង់ ត្រូវបានកែតម្រូវ ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលធ្វើការកែប្រែ។ ថ្លៃដើម ឬកម្រៃសេវាណាមួយដែលបានកើតឡើង ហើយកម្រៃសេវាដែលបានទទួលគឺជាផ្នែកមួយនៃការកែប្រែសមតុល្យយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ ហើយត្រូវបានធ្វើរំលស់លើកាលកំណត់ដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ។
- ប្រសិនបើមានការកែប្រែបែបនេះ ត្រូវបានអនុវត្តដោយសារតែផលលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី នោះចំណេញ ឬខាត ត្រូវបានបង្ហាញរួមគ្នាជាមួយនឹងការខាតបង់ឱនភាពតម្លៃ។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ដែលបានគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

**បំណុលហិរញ្ញវត្ថុ**

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុនៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែប្រែមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីមួយ ដែលផ្អែកលើលក្ខខណ្ឌដែលបានកែប្រែត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពខុសគ្នារវាងសមតុល្យយោងនៃបំណុលហិរញ្ញវត្ថុដែលបានឈប់ទទួលស្គាល់ និងតម្លៃតបស្នងដែលបានបង់ ត្រូវបានទទួលស្គាល់ក្នុងចំណេញ និងខាត។ តម្លៃតបស្នងដែលបានបង់ រួមបញ្ចូលទាំងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដែលត្រូវបានផ្ទេរ ប្រសិនបើមាន និងការសន្មតបំណុល រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែប្រែថ្មី។

ប្រសិនបើការកែប្រែបំណុលហិរញ្ញវត្ថុនេះមិនបានកត់ត្រាជាការឈប់ទទួលស្គាល់ទេ នោះថ្លៃដើមបានរំលស់នៃបំណុល ត្រូវបានគណនាឡើងវិញដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់បំណុលហិរញ្ញវត្ថុដែលមានអត្រាអណ្តែត អត្រាការប្រាក់ប្រសិទ្ធភាពដំបូង ដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែប្រែ។ រាល់ចំណាយ និងកម្រៃសេវាដែលកើតឡើង ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើសមតុល្យយោងនៃបំណុល និងត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែប្រែនោះ ដោយធ្វើការគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញទៅលើឧបករណ៍នេះ។

### (៥) ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានកាត់កង និងសមតុល្យសុទ្ធត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលដែលធនាគារមានសិទ្ធិស្របច្បាប់ក្នុងការកំណត់នូវសមតុល្យ ហើយមានបំណងទូទាត់ដោយផ្អែកលើមូលដ្ឋានសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

### (៦) ការវាស់វែងតម្លៃសមស្រប

'តម្លៃសមស្រប' គឺជាតម្លៃដែលត្រូវទទួលដើម្បីលក់ទ្រព្យសកម្ម ឬទូទាត់ដើម្បីផ្ទេរបំណុលក្នុងប្រតិបត្តិការតាមលំដាប់រវាងអ្នកចូលរួមទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែងជាចម្បង ឬក្នុងករណីដែលមិនមានទីផ្សារ ហើយទីផ្សារដែលមានអត្ថប្រយោជន៍បំផុតដែលធនាគារមានសិទ្ធិប្រើប្រាស់នាកាលបរិច្ឆេទនោះ។ តម្លៃសមស្របនៃបំណុលដែលឆ្លុះបញ្ចាំងពីហានិភ័យមិនមានប្រតិបត្តិការ។

នៅពេលមានតម្លៃសមស្រប ធនាគារវាស់វែងតម្លៃសមស្របនៃឧបករណ៍ដោយប្រើតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ឧបករណ៍នោះ។ ទីផ្សារត្រូវបានចាត់ទុកថា 'សកម្ម' ប្រសិនបើប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុលកើតឡើងជាមួយនឹងភាពញឹកញាប់ និងបរិមាណគ្រប់គ្រាន់ដើម្បីផ្តល់ព័ត៌មានអំពីតម្លៃតាមមូលដ្ឋាននិរន្តរភាព។

ប្រសិនបើមិនមានការដកស្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះធនាគារប្រើបច្ចេកទេសវាយតម្លៃដែលបង្កើនការប្រើប្រាស់ធាតុចូល ដែលអាចសង្កេតបាន និងបង្រួមអប្បបរមានៃការប្រើប្រាស់ធាតុចូលដែលមិនអាចសង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលត្រូវបានជ្រើសរើសរួមបញ្ចូលកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារពិចារណាលើការកំណត់តម្លៃប្រតិបត្តិការ។

ភស្តុតាងល្អបំផុតនៃតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុនៅលើការទទួលស្គាល់ដំបូង គឺតម្លៃប្រតិបត្តិការ ឧទាហរណ៍ តម្លៃសមស្របរបស់តម្លៃតបស្នងដែលបានផ្តល់ឱ្យ ឬទទួលបាន។ ប្រសិនបើធនាគារកំណត់ថាតម្លៃសមស្របលើការទទួលស្គាល់ដំបូងខុសគ្នាពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្រប មិនត្រូវបានបង្ហាញដោយតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្ម សម្រាប់កំណត់អត្តសញ្ញាណទ្រព្យសកម្ម ឬបំណុលដូចគ្នា និងមិនផ្អែកលើបច្ចេកទេសវាយតម្លៃសម្រាប់ធាតុចូលណាមួយដែលមិនអាចអង្កេតបាន ដែលត្រូវវិនិច្ឆ័យថាមិនមានទំនាក់ទំនងក្នុងការវាស់វែងដែលមិនគួរឱ្យកត់សម្គាល់ បន្ទាប់មកឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប និងបានកែប្រែដើម្បីបម្លែងភាពខុសគ្នារវាងតម្លៃសមស្របចំពោះការទទួលស្គាល់ដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ និងខាតលើមូលដ្ឋានដែលត្រឹមត្រូវលើអាយុកាលនៃឧបករណ៍ ប៉ុន្តែមិនលើសពីអាយុកាលប្រើប្រាស់ទេ នៅពេលដែលធ្វើការវាយតម្លៃត្រូវបានគាំទ្រទាំងស្រុងដោយទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬប្រតិបត្តិការដែលត្រូវបានលុបចោល។

ប្រសិនបើទ្រព្យសកម្ម ឬបំណុល ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របមានតម្លៃស្នើទិញ និងតម្លៃដេញថ្លៃ នោះធនាគារវាស់វែងទ្រព្យសកម្ម និងស្ថានភាពរយៈពេលវែងក្នុងតម្លៃស្នើទិញ និងបំណុលព្រមទាំងស្ថានភាពរយៈពេលខ្លីតាមតម្លៃដេញថ្លៃ។

ផលបត្រនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលត្រូវបានប្រឈមនឹងហានិភ័យទីផ្សារ និងហានិភ័យឥណទានដែលត្រូវបានគ្រប់គ្រងដោយធនាគារដោយផ្អែកលើមូលដ្ឋានផលប៉ះពាល់សុទ្ធចំពោះហានិភ័យទីផ្សារ ឬហានិភ័យឥណទានត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានតម្លៃដែលនឹងត្រូវបានទទួលដើម្បីលក់ស្ថានភាពរយៈពេលវែងសុទ្ធ (ឬទូទាត់ដើម្បីផ្ទេរស្ថានភាពរយៈពេលខ្លីសុទ្ធ) សម្រាប់ហានិភ័យជាក់លាក់។ ការកែតម្រូវកម្រិតផលបត្រ ឧទាហរណ៍ ការដេញថ្លៃស្នើសុំការកែតម្រូវ ឬការកែតម្រូវហានិភ័យឥណទានដែលឆ្លុះបញ្ចាំងពីការវាស់វែងដោយឈរលើមូលដ្ឋាននៃការប៉ះពាល់សុទ្ធត្រូវបានបែងចែកជាទ្រព្យសកម្ម និងបំណុលដាច់ដោយឡែក ដោយផ្អែកលើមូលដ្ឋាននៃការកែតម្រូវហានិភ័យដែលទាក់ទងនឹងឧបករណ៍នីមួយៗនៅក្នុងផលបត្រ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុដែលមានលក្ខណៈតម្រូវ (ឧទាហរណ៍ ប្រាក់បញ្ញើតាមតម្រូវការ) មិនតិចជាងសមតុល្យដែលត្រូវបង់តាមតម្រូវការដែលត្រូវបានធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលសមតុល្យអាចតម្រូវឱ្យបង់។

ធនាគារ ទទួលស្គាល់ការផ្ទេររវាងកម្រិតឋានានុក្រមនៃតម្លៃសមស្របនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ក្នុងអំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

(៧) ឱនភាពតម្លៃ

ធនាគារទទួលស្គាល់នូវសំវិធានពីការខាតបង់ឥណទានដែលបានរំពឹងទុកលើឧបករណ៍ហិរញ្ញវត្ថុ ដែលមិនត្រូវបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាឧបករណ៍បំណុល និង
- កិច្ចសន្យាឥណទានដែលបានអនុម័ត។

ពុំមានការខាតបង់លើឱនភាពតម្លៃ ត្រូវបានទទួលស្គាល់លើការវិនិយោគមូលធននោះទេ។

ធនាគារវាស់វែងសំវិធានធនពីការខាតបង់តាមសមតុល្យស្មើនឹង ECL មួយអាយុកាល លើកលែងតែចំណុចដូចខាងក្រោម ដែលត្រូវបានវាស់វែងជា ECL រយៈពេល ១២ ខែ៖

- ការវិនិយោគបំណុលដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាបនៅកាលបរិច្ឆេទនៃការរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាដែលត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីមានការទទួលស្គាល់ដំបូង។

ECL រយៈពេល ១២ ខែ គឺជាផ្នែកមួយនៃ ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍មិនប្រក្រតីលើឧបករណ៍ហិរញ្ញវត្ថុដែលអាចធ្វើទៅបានក្នុងរយៈពេល ១២ ខែបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុសម្រាប់ ECL មានរយៈពេល ១២ខែ ត្រូវបានទទួលស្គាល់ថាជា ‘ឧបករណ៍ហិរញ្ញវត្ថុកម្រិតទី ១’។

ECL មួយអាយុកាល គឺជា ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍មិនប្រក្រតីដែលអាចកើតមានទាំងអស់លើអាយុកាលដែលបានរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែល ECL មួយអាយុកាល ត្រូវគេទទួលស្គាល់ ប៉ុន្តែមិនមានឱនភាពឥណទាន ត្រូវបានគេហៅថា “ ឧបករណ៍ហិរញ្ញវត្ថុកម្រិតទី ២”។

នៅកាលបរិច្ឆេទនៃការរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីមានការទទួលស្គាល់ដំបូងឬទេ។ នៅពេលហានិភ័យឥណទានបានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់ដំបូងនោះ សំវិធានធនលើការខាតបង់ត្រូវបានវាស់វែងតាមសមតុល្យស្មើនឹង ECL មួយអាយុកាល។

នៅពេលកំណត់ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់ដំបូង និងនៅពេលប៉ាន់ស្មាន ECL ធនាគារពិចារណាលើព័ត៌មានដែលសមហេតុផល និងអាចទុកចិត្តបានដែលពាក់ព័ន្ធ និងអាចរកបានដោយមិនរួមបញ្ចូលចំណាយមិនទាន់បានទូទាត់សងៗ ទាំងនេះរួមមានទាំងបរិមាណ និងព័ត៌មានប្រកបដោយគុណភាព និងការវិភាគ ផ្អែកលើបទពិសោធន៍របស់ធនាគារ និងការវាយតម្លៃឥណទានដែលមានស្រាប់ និងរួមបញ្ចូលទាំងព័ត៌មានយោងទៅមុខ។

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់ដំបូង ឬប្រសិនបើគុណភាពឥណទានរបស់ឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើងនោះ ពុំមានការកើនឡើងគួរឱ្យកត់សម្គាល់លើហានិភ័យឥណទានចាប់តាំងពីមានការទទួលស្គាល់ដំបូង ហើយសំវិធានធនលើការខាតបង់ត្រូវបានវាស់វែងក្នុងសមតុល្យស្មើនឹង ECL រយៈពេល ១២ ខែ។

រយៈពេលអតិបរមាដែលត្រូវបានពិចារណានៅពេលធ្វើការប៉ាន់ស្មាន ECL គឺជារយៈពេលកិច្ចសន្យាអតិបរមាដែលធនាគារត្រូវប្រឈមនឹងហានិភ័យឥណទាន។

**កំណត់ថាតើហានិភ័យឥណទានបានកើនឡើងគួរឱ្យកត់សម្គាល់**

ធនាគារវាយតម្លៃថាតើហានិភ័យឥណទានបានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់តាំងពីមានការទទួលស្គាល់ដំបូងនៅកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ។ ការកំណត់ថាតើការកើនឡើងនៃហានិភ័យឥណទានមានសារៈសំខាន់ឬទេ គឺអាស្រ័យលើលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអ្នកខ្ចី ព្រមទាំងតំបន់ភូមិសាស្ត្រ។

ធនាគារចាត់ទុកថាការកើនឡើងគួរអោយកត់សម្គាល់នូវហានិភ័យឥណទានកើតឡើងមិនលើសពីពេលដែលទ្រព្យសកម្មហួសកាលកំណត់ ៣០ថ្ងៃ។ ថ្ងៃដែលហួសកំណត់ត្រូវបានកំណត់ដោយរាប់ចំនួនថ្ងៃចាប់តាំងពីថ្ងៃផុតកំណត់ដំបូងបំផុតដែលទាក់ទងនឹងការហួសកំណត់សងក្នុងការទូទាត់ប្រាក់ពេញលេញមិនត្រូវបានទទួល។ កាលបរិច្ឆេទកំណត់សងត្រូវបានកំណត់ដោយមិនគិតពីរយៈពេលអនុគ្រោះណាមួយដែលអាចមានសម្រាប់អ្នកខ្ចីឡើយ។

ប្រសិនបើមានភស្តុតាងបង្ហាញថាមិនមានការកើនឡើងគួរឱ្យកត់សម្គាល់លើហានិភ័យឥណទានទាក់ទងនឹងការទទួលស្គាល់ដំបូងទេនោះ សំវិធានធនលើការខាតបង់លើឧបករណ៍មួយនឹងវិលត្រឡប់ជាការវាស់វែង ECL រយៈពេល ១២ ខែ។

**និយមន័យនៃការខកខានទូទាត់សង**

ធនាគារពិចារណាលើទ្រព្យសកម្មហិរញ្ញវត្ថុដែលស្ថិតក្នុងការខកខានទូទាត់សងនៅពេលដែល៖

- អ្នកខ្ចីទំនងជាមិនបង់នូវកាតព្វកិច្ចឥណទានរបស់ខ្លួនដល់ធនាគារទាំងស្រុង ដោយគ្មានការប្រមូលមកវិញពីធនាគារតាមរយៈសកម្មភាពដូចជា ការរឹបអូសទ្រព្យបញ្ចាំ (ប្រសិនបើមានការរក្សាទុក) ឬ
- ធនាគារពិចារណាថាការកើនឡើងគួរអោយកត់សម្គាល់នូវហានិភ័យឥណទានកើតឡើងមិនលើសពីពេលដែលទ្រព្យសកម្មលើស ឬស្មើ ៣០ថ្ងៃ ដែលហួសកាលកំណត់សម្រាប់ហ្វាស៊ីលីធីរយៈពេលវែង ឬច្រើនជាង ឬស្មើ ១៤ថ្ងៃ ដែលហួសកាលកំណត់សងសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី ឬ
- អ្នកខ្ចីអាចនឹងរៀបចំនូវទ្រព្យសកម្មឡើងវិញ ដែលជាលទ្ធផលនៃការក្ស័យធនដោយសារតែភាពអសមត្ថភាពរបស់អ្នកខ្ចី ក្នុងការបង់នូវកាតព្វកិច្ចឥណទានរបស់ខ្លួន។

**ការវាស់វែងនៃ ECL**

ECL គឺជាការប៉ាន់ស្មានដោយផ្អែកលើការថ្លឹងថ្លែងប្រូបាប៊ីលីតេនៃការខាតបង់ឥណទាន។ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពឥណទាននៅកាលបរិច្ឆេទនៃរបាយការណ៍៖ ជាតម្លៃបច្ចុប្បន្នដែលមានកង្វះខាតសាច់ប្រាក់ (ភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជំពាក់អង្គភាព ស្របតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងថានឹងទទួលបាន)
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាននៅកាលបរិច្ឆេទនៃរបាយការណ៍៖ ជាភាពខុសគ្នារវាងសមតុល្យយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មាន និង
- កិច្ចសន្យាឥណទានដែលមិនបានដក៖ ជាតម្លៃបច្ចុប្បន្នដែលមានភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលត្រូវសងទៅធនាគារ ប្រសិនបើកិច្ចសន្យានេះមិនបានប្រើប្រាស់ ហើយលំហូរសាច់ប្រាក់ដែលធនាគាររំពឹងថានឹងទទួលបាន។
- កិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ការទូទាត់ដែលបានរំពឹងទុកក្នុងការសងទៅកាន់អ្នកកាន់កាប់ ដកនឹងសមតុល្យណាមួយដែលធនាគាររំពឹងក្នុងការស្តារមកវិញ។

នៅពេលដែលធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគត អត្រាអប្បហារត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ក្រៅពីទ្រព្យសកម្មហិរញ្ញវត្ថុឥណទានឱនភាពតម្លៃដែលបានទិញ ឬបានចាប់ផ្តើម ("POCI") និងភតិសន្យាត្រូវបានទទួល៖ អត្រាការប្រាក់ប្រសិទ្ធភាពដើម ឬប្រហាក់ប្រហែល
- ទ្រព្យសកម្ម POCI៖ ឥណទានដែលបានកែតម្រូវចំពោះអត្រាការប្រាក់ប្រសិទ្ធភាព
- ភតិសន្យាត្រូវទទួល៖ អត្រាអប្បហារដែលត្រូវបានប្រើប្រាស់ក្នុងការវាស់វែងភតិសន្យាត្រូវទទួល
- កិច្ចសន្យាឥណទានដែលមិនបានដក៖ អត្រាការប្រាក់ប្រសិទ្ធភាព ឬការប្រហាក់ប្រហែលដែលនឹងត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាលទ្ធផលពីកិច្ចសន្យាឥណទាន និង
- កិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានអនុម័ត ៖ អត្រាដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលា និងហានិភ័យដែលជាក់លាក់ចំពោះលំហូរសាច់ប្រាក់។

**ធាតុចូល ការសន្មត និងបច្ចេកទេសដែលត្រូវបានប្រើសម្រាប់ការប៉ាន់ស្មានឱនភាពតម្លៃ**
ធាតុចូលសំខាន់ៗ ក្នុងការវាស់វែងរបស់ ECL គឺជារចនាសម្ព័ន្ធតាមកាលកំណត់អថេរដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានទូទាត់សង ("PD")
- ការខាតបង់ក្នុងការផ្តល់ឥណទានដែលខកខានទូទាត់សង ("LGD") និង
- ផលប៉ះពាល់នៃការខកខានទូទាត់សង ("EAD")។

ECL សម្រាប់ការបង្ហាញនៅដំណាក់កាលទី១ ត្រូវបានគណនាដោយធ្វើការគុណ PD រយៈពេល១២ ខែដោយ LGD និង EAD។ ECL មួយអាយុកាល គឺត្រូវបានគណនាដោយគុណ PD មួយអាយុកាលដោយ LGD និង EAD។

គម្រូស្ថិតិដែលត្រូវបានធ្វើឡើងដើម្បីវិភាគទិន្នន័យដែលបានប្រមូល និងបម្លែងភាពប៉ាន់ស្មាននៃអាយុកាលរបស់ PD ដែលនៅសល់ពីការប្រឈម និងរបៀបដែលគម្រូទាំងនេះត្រូវបានរំពឹងទុកដើម្បីផ្លាស់ប្តូរលទ្ធផលនៃពេលវេលា។

LGD គឺជាទំហំនៃការខាតបង់ដែលអាចកើតមានប្រសិនបើមានការខកខានទូទាត់សង។ ធនាគារប៉ាន់ស្មានប៉ារ៉ាម៉ែត្ររបស់ LGD ដោយផ្អែកលើប្រវត្តិនៃអត្រាស្តារឡើងវិញនៃការទាមទារការទូទាត់សងពីសមភាគី។ គំរូ LGD ធ្វើការពិចារណាលើរចនាសម្ព័ន្ធ ទ្រព្យបញ្ចាំការទូទាត់ប្រាក់អតីតភាពការងារ ការទូទាត់ វិស័យរបស់សមភាគី និងថ្លៃដើមនៃការស្តារឡើងវិញនូវទ្រព្យបញ្ចាំណាមួយដែលជាផ្នែករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ សម្រាប់ឥណទានដែលមានការធានាដោយអចលនទ្រព្យលក់វាយ សមាមាត្រLTV គឺជាប៉ារ៉ាមែត្រសំខាន់ៗក្នុងការកំណត់ LGD។ ការប៉ាន់ស្មាន LGD ត្រូវបានគណនាឡើងវិញសម្រាប់សេណារីយ៉ូសេដ្ឋកិច្ចផ្សេងគ្នា និងសម្រាប់ការផ្តល់ប្រាក់កម្ចីអចលនទ្រព្យ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលអាចកើតមានក្នុងតម្លៃទ្រព្យសម្បត្តិ។ ត្រូវបានគណនាលើមូលដ្ឋានលំហូរសាច់ប្រាក់ដែលបានពីអប្បហារដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពជាកត្តាអប្បហារ។

EAD តំណាងឱ្យការប៉ះពាល់ដែលរំពឹងទុកក្នុងករណីនៃការខកខានទូទាត់សង។ ធនាគារទាញយក EAD ពីការប៉ះពាល់នាពេលបច្ចុប្បន្នទៅនឹងសមភាគី និងការផ្លាស់ប្តូរសក្តានុពលនៃសមតុល្យបច្ចុប្បន្នដែលបានអនុញ្ញាតក្រោមកិច្ចសន្យា និងកើតឡើងពីការរំលស់លើទ្រព្យសកម្មអរូបី។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាសមតុល្យយោងដុលតាមកាលកំណត់នៃការខកខានទូទាត់សង។ ចំពោះកិច្ចសន្យាផ្តល់ឥណទាន EADs គឺជាសមតុល្យសក្តានុពលនាពេលអនាគត ដែលអាចត្រូវបានបង្ហាញក្រោមកិច្ចសន្យាដែលត្រូវបានប៉ាន់ស្មានផ្អែកលើការសង្កេតជាប្រវត្តិសាស្រ្ត និងការព្យាករណ៍នាពេលខាងមុខ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុមួយចំនួន EAD ត្រូវបានកំណត់ដោយយកគំរូតាមកម្រិតលទ្ធផលដែលអាចកើតមាននៅចំណុចផ្សេងៗ ក្នុងពេលកំណត់ដោយប្រើសេណារីយ៉ូ និងបច្ចេកទេសស្ថិតិ។

ដូចដែលបានរៀបរាប់ខាងលើ EPD គឺត្រូវប្រើប្រាស់អតិបរមារយៈពេល ១២ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី១ ធនាគារវាស់វែង ECL ដោយធ្វើការពិចារណាលើហានិភ័យនៃការខកខានទូទាត់សងក្នុងរយៈពេលកិច្ចសន្យាអតិបរមា (រាប់បញ្ចូលទាំងជម្រើសពន្យាររបស់អ្នកខ្ចី) ដែលប្រឈមនឹងហានិភ័យឥណទាន ទោះបីក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ ធនាគារពិចារណារយៈពេលយូរជាងនេះ។ រយៈពេលកិច្ចសន្យាអតិបរមាពង្រីកវិសាលភាពរហូតដល់កាលបរិច្ឆេទដែលធនាគារមានសិទ្ធិតម្រូវឱ្យទូទាត់សងជាមុន ឬបញ្ចប់កិច្ចសន្យា ឬការធានាឥណទាន។

**ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ**

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានពិភាក្សាឡើងវិញ ឬកែប្រែ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី នោះការវាយតម្លៃត្រូវបានធ្វើឡើងថាតើទ្រព្យសកម្មហិរញ្ញវត្ថុ គួរត្រូវបានឈប់ទទួលស្គាល់ ហើយ ECL ត្រូវបានធ្វើការវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញដែលបានរំពឹងទុកនឹងមិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះលំហូរសាច់ប្រាក់ដែលរំពឹងទុកដែលបានមកពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែត្រូវបានរាប់បញ្ចូលក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។

- ប្រសិនបើការរៀបចំឡើងវិញដែលបានរំពឹងទុកនឹងមានបណ្តាលឱ្យមាននៃការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របដែលបានរំពឹងទុកនៃទ្រព្យសកម្មថ្មី ត្រូវបានចាត់ទុកជាលំហូរសាច់ប្រាក់ចុងក្រោយពីទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់នៅពេលឈប់ទទួលស្គាល់។ សមតុល្យនេះត្រូវបានរាប់បញ្ចូលក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានស្រាប់ ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទដែលបានរំពឹងទុកនៃការឈប់ទទួលស្គាល់រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍ ដោយប្រើប្រាស់អត្រាការប្រាក់ដើមដែលមានប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់។

**ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាន**

នៅកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ធនាគារធ្វើការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានអនុវត្តតាមថ្លៃដើមបានរំលស់ និងបំណុលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានអនុវត្តតាម FVOCI មានឱនភាពឥណទាន (សំដៅដល់" ដំណាក់កាលទី ៣ នៃទ្រព្យសកម្មហិរញ្ញវត្ថុ")។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមាន"ឱនភាពឥណទាន" នៅពេលព្រឹត្តិការណ៍មួយឬច្រើនមានផលប៉ះពាល់យ៉ាងខ្លាំងលើលំហូរសាច់ប្រាក់ហិរញ្ញវត្ថុនាពេលអនាគតរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកើតឡើង។

ភស្តុតាងដែលទ្រព្យសកម្មហិរញ្ញវត្ថុ មានឱនភាពឥណទាន រួមមានទិន្នន័យដែលអាចសង្កេតបានដូចខាងក្រោម៖

- ផលលំបាកផ្នែកហិរញ្ញវត្ថុសំខាន់ៗរបស់អ្នកខ្ចី ឬអ្នកអនុម័ត
- ការរំលោភកិច្ចសន្យាដូចជាការខកខានទូទាត់សង ឬហួសកាលបរិច្ឆេទកំណត់សង
- ការរៀបចំឡើងវិញនូវឥណទាន ឬបុរេប្រទានដោយធនាគារតាមលក្ខខណ្ឌដែលធនាគារមិនដែលបានពិចារណាពីមុនមក
- វាអាចនឹងកើតឡើងដែលថាអ្នកខ្ចីនឹងជួបវិបត្តិក្ស័យធន ឬការរៀបចំហិរញ្ញវត្ថុឡើងវិញផ្សេងៗ ឬ
- អវត្តមាននៃទីផ្សារសកម្មសម្រាប់ការធានាដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

ឥណទានដែលត្រូវបានគេពិចារណាឡើងវិញ ដោយសារតែការខាតបង់គុណភាពលើស្ថានភាពរបស់អ្នកខ្ចីត្រូវបានគេចាត់ទុកថាជាឱនភាពឥណទាន លុះត្រាតែមានភស្តុតាងដែលបង្ហាញថាហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានថយចុះគួរឱ្យកត់សម្គាល់ ហើយមិនមានសូចនាករផ្សេងទៀតនៃឱនភាពនោះទេ។ លើសពីនេះទៅទៀត ឥណទានដែលហួសកាលកំណត់សងរយៈពេល ៩០ ថ្ងៃ ឬលើសពីនេះ ត្រូវបានគេចាត់ទុកថាមានឱនភាពឥណទាន ទោះបីជានិយមន័យបទប្បញ្ញត្តិនៃការខកខានមានភាពខុសគ្នាក៏ដោយ។

**ការបង្ហាញនូវសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**

ការខាតបង់សំវិធានធនសម្រាប់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់៖ ជាការកាត់កងពីសមតុល្យយោងដុលរបស់ទ្រព្យសកម្ម។

**ការលុបចេញ**
ឥណទាន និងបុរេប្រទានត្រូវបានលុបចោល (មិនថាផ្នែកខ្លះ ឬទាំងស្រុង) នៅពេលគ្មានការរំពឹងទុកសមហេតុផលក្នុងការប្រមូលមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុទាំងមូល ឬផ្នែកណាមួយឡើយ។ ជាទូទៅករណីនេះកើតឡើងនៅពេលដែលធនាគារកំណត់ថា អ្នកខ្ចីមិនមានទ្រព្យសកម្ម ឬប្រភពចំណូលដែលអាចបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងសមតុល្យដែលត្រូវបានលុបចោលឡើយ។ ការវាយតម្លៃនេះត្រូវបានអនុវត្តតាមកម្រិតទ្រព្យសកម្មដាច់ដោយឡែក។

លទ្ធភាពក្នុងការប្រមូលមកវិញនូវសមតុល្យដែលបានលុបចោលពីមុន ត្រូវបានរាប់បញ្ចូលក្នុង"ការខាតបង់ឧបករណ៍ហិរញ្ញវត្ថុ" ក្នុងរបាយការណ៍ចំណេញ និងខាត និងចំណូលលម្អិតផ្សេងៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចោលអាចជាកម្មវត្ថុនៃការអនុវត្តសកម្មភាពនានា ដើម្បីអនុលោមតាមនីតិវិធីរបស់ធនាគារក្នុងការប្រមូលបានមកវិញនូវសមតុល្យដល់កាលកំណត់សង។

### (៨) កំណែទម្រង់គោលការណ៍អត្រាការប្រាក់
ប្រសិនបើមូលដ្ឋាននៃការកំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមបានរំលស់មានការប្រែប្រួលដែលជាលទ្ធផលនៃកំណែទម្រង់អត្រាការប្រាក់ នោះធនាគារនឹងធ្វើបច្ចុប្បន្នភាពលើអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរតាមការតម្រូវនៃកំណែទម្រង់នេះ។ ការផ្លាស់ប្តូរមូលដ្ឋានសម្រាប់ការកំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺត្រូវបានតម្រូវដោយកំណែទម្រង់គោលការណ៍អត្រាការប្រាក់ ប្រសិនបើលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ការផ្លាស់ប្តូរ គឺចាំបាច់ជាលទ្ធផលផ្ទាល់នៃកំណែទម្រង់នេះ និង
- មូលដ្ឋានថ្មីសម្រាប់កំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺសមមូលនឹងមូលដ្ឋានសេដ្ឋកិច្ចពីមុន ពោលគឺមូលដ្ឋានភ្លាមៗមុនពេលមានការផ្លាស់ប្តូរ។

ប្រសិនបើការផ្លាស់ប្តូរត្រូវបានធ្វើឡើងចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ បន្ថែមពីលើការផ្លាស់ប្តូរមូលដ្ឋានសម្រាប់កំណត់នូវលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលតម្រូវក្នុងកំណែទម្រង់អត្រាការប្រាក់ នោះធនាគារនឹងធ្វើបច្ចុប្បន្នភាពលើអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមុនសិន ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលតម្រូវក្នុងការធ្វើកំណែទម្រង់អត្រាការប្រាក់។ បន្ទាប់ពីនោះ ធនាគារធ្វើការអនុវត្តគោលនយោបាយស្តីពីគណនេយ្យសម្រាប់ការកែប្រែដែលបានកំណត់ខាងលើចំពោះការគិតថ្លៃបន្ថែម។

## ៤.៥ សាច់ប្រាក់ និងសាច់ប្រាក់សមមូល
សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យនៅធនាគារ ប្រាក់បញ្ញើតាមតម្រូវការ និងការវិនិយោគសាច់ប្រាក់រយៈពេលខ្លីដែលមានកាលកំណត់រយៈពេលបីខែ ឬតិចជាងនេះចាប់ពីកាលបរិច្ឆេទនៃការទិញដែលប្រឈមនឹងហានិភ័យតិចតួចនៃការផ្លាស់ប្តូរតម្លៃសមស្រប ហើយត្រូវបានប្រើប្រាស់ដោយធនាគារក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លីរបស់ខ្លួន។

សាច់ប្រាក់ និងសាច់ប្រាក់សមមូលត្រូវបានអនុវត្តតាមថ្លៃដើមបានរំលស់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ៤.៦ គណនីដើមទុន
### (១) ដើមទុន
ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាមូលធន។ ចំណាយបន្ថែម ដែលទាក់ទងដោយផ្ទាល់ក្នុងការចេញផ្សាយភាគហ៊ុនធម្មតាត្រូវបានទទួលស្គាល់ជាការកាត់កងពីមូលធន ដកផលប៉ះពាល់ពន្ធ។ ភាគហ៊ុនផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬ បំណុលដោយផ្អែកទៅលើស្ថានភាពសេដ្ឋកិច្ចនៃឧបករណ៍ហិរញ្ញវត្ថុជាក់លាក់ណាមួយ។ ការចែកចាយដល់អ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធនត្រូវបានកត់ត្រាដោយផ្ទាល់ក្នុងគណនីមូលធន។

### (២) ទុនផ្សេងៗ និងទុនបម្រុង

ទុនផ្សេងៗ និងទុនបម្រុង ត្រូវបានចាត់ថ្នាក់ជាមូលធន។ យោងតាមលិខិតលេខ ៥៣៦ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ជូនទៅនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ហើយភ្ជាប់ជាមួយចំណារពន្យល់ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មត្រូវបានផ្តល់ការយល់ព្រមតាមការស្នើសុំដើម្បីចាត់វិធានការលើឥណទាន និងបុរេប្រទានមិនដំណើរការដែលមានសមតុល្យ ១៨.២៦៩.៥៦៧ ដុល្លារអាមេរិក ត្រូវបានកាត់កងពីមូលធនដោយលុបចេញពីតារាងតុល្យការ ហើយត្រួតពិនិត្យដាច់ដោយឡែកពីគ្នា។ លទ្ធភាពស្តារបានមកវិញជាបន្តបន្ទាប់នៃឥណទាន និងបុរេប្រទានមិនមានដំណើរការទាំងនេះ និងការប្រាក់ដែលនឹងត្រូវបានទទួលស្គាល់ដោយផ្ទាល់ក្នុងគណនីទុនផ្សេងៗ និងទុនបម្រុងរបស់ធនាគារបន្ទាប់ពីទទួលបានការយល់ព្រមពីធនាគារជាតិ នៃ កម្ពុជា។

## ៤.៧ ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នានៃសំវិធានធនរវាងឱនភាពនៃឥណទាន ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសំវិធានធនតាមបទប្បញ្ញត្តិ ដោយអនុលោមតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា លេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំ លេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ស្របតាមប្រការលេខ ៧៣ គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលបានគណនាតាមប្រការ ៤៩ ដល់ប្រការ ៧១ ហើយសំវិធានធនដែលបានគណនាតាមប្រការ ៧២ និងត្រូវកត់ត្រាដូចខាងក្រោម៖

(ក) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ បានគណនាតាមប្រការ ៧២ ទាបជាងសំវិធានធនដែលបានគណនាតាមប្រការ ៤៩ ដល់ប្រការ ៧១ នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និង

(ខ) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ ៧២ ខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ ៤៩ ដល់ប្រការ ៧១ នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម CIFRSs និងផ្ទេរភាពលម្អៀងពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិនៅក្នុងគណនីមូលធន។

ទុនបម្រុងតាមបទប្បញ្ញត្តិមិនមែនជាសមាសធាតុដែលត្រូវបានរួមបញ្ចូលក្នុងការគណនាមូលធនផ្ទាល់សុទ្ធរបស់ធនាគារឡើយ។

នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ធនាគារជាតិ នៃ កម្ពុជា បានចេញផ្សាយសារាចរណែនាំថ្មីលេខ ធ៧-០២១-២៣១៤ CL ស្តីពីកាតព្វកិច្ចធ្វើចំណាត់ថ្នាក់ និងសំវិធានធន ចំពោះឥណទានរៀបចំឡើងវិញ ក្នុងគោលបំណងដកចេញរយៈពេលអនុគ្រោះសម្រាប់ឥណទានរៀបចំឡើងវិញដែលមានស្រាប់ និងបែងចែកការរៀបចំចំណាត់ថ្នាក់ និងសំវិធានធន ដោយអនុលោមទៅតាមបទប្បញ្ញត្តិបច្ចុប្បន្ន ដោយយោងតាមប្រកាសលេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ស្តីអំពីការធ្វើចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន។ ក្នុងករណីនេះរាល់ឥណទានរៀបចំឡើងវិញ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានធ្វើចំណាត់ថ្នាក់ និងសំវិធានធនឡើងវិញដោយផ្អែកទៅលើការតម្រូវនៃសារាចរណែនាំនេះ។ ចំពោះឥណទានដែលស្ថិតក្នុងរយៈពេលវាយតម្លៃ ឥណទាននោះត្រូវរក្សាចំណាត់ថ្នាក់ដដែលនៅមុនពេលដែលមានការរៀបចំលក្ខខណ្ឌនៃកិច្ចសន្យាឡើងវិញ។

បន្ទាប់ពីសិក្ខាសាលារបស់ធនាគារជាតិ នៃ កម្ពុជា ស្តីពី "ការអនុវត្តសារាចរណែនាំស្តីពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធនចំពោះឥណទានរៀបចំឡើងវិញ" ដែលបានធ្វើឡើងនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ ធនាគារជាតិនៃ កម្ពុជា បានចេញផ្សាយការជូនដំណឹងមួយនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២ ដែលអនុញ្ញាតឱ្យស្ថាប័នធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ("BFIs") ពន្យារពេលអនុវត្តសារាចរណែនាំថ្មីរហូតដល់ខែមករា ឆ្នាំ២០២២ តទៅ ទោះបីការអនុវត្តមុនត្រូវបានលើកទឹកចិត្តក៏ដោយ។ ធនាគារបានជ្រើសរើសពន្យារពេលអនុវត្តសារាចរណែនាំថ្មី ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

## ៤.៨ ប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ

ប្រាក់តម្កល់ជាមួយធនាគារផ្សេងៗត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់បន្ថែម ហើយបន្ទាប់មកត្រូវកត់ត្រាតាមថ្លៃដើមបានរំលស់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

## ៤.៩ ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ

ប្រាក់បញ្ញើតាមបទប្បញ្ញត្តិរួមមានសមតុល្យជាមួយធនាគារជាតិ នៃ កម្ពុជា ដែលត្រូវបានរក្សាទុកដើម្បីអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ហើយត្រូវបានកំណត់ដោយភាគរយដែលបានកំណត់នៃដើមទុនអប្បបរមា និងប្រាក់បញ្ញើរបស់អតិថិជន/ធនាគារផ្សេងទៀតតាមការតម្រូវរបស់ធនាគារជាតិ នៃ កម្ពុជា។

## ៤.១០ ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទាន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមបញ្ចូលឥណទាន និងបុរេប្រទាន ដែលត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់។ ឥណទាន និងបុរេប្រទាន ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់បន្ថែម ហើយបន្ទាប់មកត្រូវកត់ត្រាតាមថ្លៃដើមបានរំលស់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

## ៤.១១ ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗត្រូវបានអនុវត្តតាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ៤.១២ ទ្រព្យសម្បត្តិ និងបរិក្ខារ

### (១) ការទទួលស្គាល់ និងការវាស់វែង

សមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពតម្លៃបង្គរ។

ថ្លៃដើម រួមបញ្ចូលទាំងការចំណាយដែលទាក់ទងដោយផ្ទាល់ក្នុងការទិញទ្រព្យសកម្ម ព្រមទាំងថ្លៃដើមទាំងឡាយណាដែលទាក់ទងដោយផ្ទាល់ក្នុងការនាំយកទ្រព្យសកម្មឱ្យទៅក្នុងលក្ខខណ្ឌការងារសម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក និងចំណាយក្នុងការរុះរើ និងដកចេញនូវសមាសធាតុ និងការរៀបចំទីតាំងរបស់ទ្រព្យសកម្មឡើងវិញទៅតាមកន្លែងដែលបានកំណត់។ ចំណាយក្នុងការសាងសង់ទ្រព្យសកម្មក៏ត្រូវបានបញ្ចូលទៅក្នុងថ្លៃដើមនៃវត្ថុធាតុដើម និងកម្លាំងពលកម្មផ្ទាល់ផងដែរ។ ចំពោះទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះចំណាយប្រាក់កម្ចីត្រូវបានធ្វើជាមូលធនកម្ម ដោយអនុលោមតាមគោលនយោបាយគណនេយ្យស្តីពីចំណាយប្រាក់កម្ចី។ ថ្លៃដើមក៏រួមបញ្ចូលទាំងការផ្ទេរពីមូលធននៃចំណេញ ឬខាតណាមួយលើការការពារហានិភ័យលំហូរសាច់ប្រាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះរូបិយប័ណ្ណបរទេសទាក់ទងនឹងការទិញទ្រព្យសម្បត្តិ និងបរិក្ខារ។

កម្មវិធីកុំព្យូទ័រដែលបានទិញ ដែលមានសារៈសំខាន់ទៅនឹងមុខងាររបស់បរិក្ខារដែលពាក់ព័ន្ធត្រូវបានធ្វើមូលធនកម្មជាផ្នែកមួយនៃបរិក្ខារនោះ។

នៅពេលដែលផ្នែកសំខាន់ៗរបស់សមាសធាតុនៃទ្រព្យសម្បត្តិ និងបរិក្ខារដែលមានអាយុកាលប្រើប្រាស់ខុសៗគ្នា ទ្រព្យសម្បត្តិ និងបរិក្ខារទាំងនោះ ត្រូវបានកត់ត្រាជាសមាសធាតុដាច់ដោយឡែក (សមាសធាតុចម្បង) នៃទ្រព្យសម្បត្តិ និងបរិក្ខារ។

ចំណេញ ឬខាតពីការលក់សមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់តាមរយៈការប្រៀបធៀបសាច់ប្រាក់ទទួលបានពីការលក់ចេញជាមួយនឹងសមតុល្យយោងរបស់ទ្រព្យសម្បត្តិ និងបរិក្ខារនោះ ហើយត្រូវបានទទួលស្គាល់ជាសមតុល្យសុទ្ធក្នុងគណនី "ចំណូលផ្សេងៗ" និង "ចំណាយផ្សេងៗ" ក្នុងគណនីចំណេញ ឬខាត។

### (២) ចំណាយបន្តបន្ទាប់

ថ្លៃដើមនៃសមាសធាតុជំនួសរបស់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានទទួលស្គាល់ក្នុងសមតុល្យយោងរបស់សមាសធាតុនោះ ប្រសិនបើវាអាចកើតមាននូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតដែលបានរួមបញ្ចូលទៅក្នុងធាតុផ្សំដែលនឹងមានលំហូរទៅក្នុងធនាគារ ហើយថ្លៃដើមអាចត្រូវបានវាស់វែងដោយភាពទុកចិត្តបាន។ សមតុល្យយោងនៃសមាសធាតុជំនួសត្រូវបានឈប់ទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាត។ ចំណាយសេវាកម្មប្រចាំថ្ងៃរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាតនៅពេលដែលចំណាយទាំងនោះបានកើតឡើង។

(៣) រំលស់

រំលស់ គឺផ្អែកលើថ្លៃដើមរបស់ទ្រព្យសកម្មដកតម្លៃសំណល់របស់ទ្រព្យសកម្មនោះ។ សមាសធាតុសំខាន់ៗនៃទ្រព្យសកម្មដាច់ដោយឡែក ត្រូវបានវាយតម្លៃ ហើយប្រសិនបើសមាសធាតុនោះមានអាយុកាលប្រើប្រាស់ខុសពីអាយុកាលប្រើប្រាស់ដែលនៅសល់របស់ទ្រព្យសកម្មនោះ ហើយសមាសធាតុនោះ ត្រូវបានធ្វើរំលស់ដាច់ដោយឡែក។

រំលស់ត្រូវបានទទួលស្គាល់ចាប់តាំងពីកាលបរិច្ឆេទដែលទ្រព្យសម្បត្តិ និងបរិក្ខារដែលត្រូវបានដំឡើង និងរួចរាល់ក្នុងការប្រើប្រាស់ ឬទ្រព្យសកម្មដែលត្រូវបានសាងសង់ខាងក្នុង គឺត្រូវបានទទួលស្គាល់ចាប់តាំងពីកាលបរិច្ឆេទដែលទ្រព្យសកម្មនោះបានបំពេញ និងរួចរាល់សម្រាប់ប្រើប្រាស់។

រំលស់ ត្រូវបានទទួលស្គាល់ថាជាការចំណាយនៅក្នុងរបាយការណ៍ចំណេញ ឬខាតលើមូលដ្ឋានរំលស់សមតុល្យថយចុះ លើកលែងតែសម្រាប់អគារដែលត្រូវបានរំលស់ផ្អែកលើមូលដ្ឋានរំលស់ថេរតាមអត្រាដូចខាងក្រោម៖

| | | |
|---|---|---|
| អគារ | ៥% | មូលដ្ឋានរំលស់ថេរ |
| ការកែលម្អអគារ | ២០% | មូលដ្ឋានរំលស់សមតុល្យថយចុះ |
| យានយន្ត | ២៥% | មូលដ្ឋានរំលស់សមតុល្យថយចុះ |
| បរិក្ខារព័ត៌មានវិទ្យា | ៥០% | មូលដ្ឋានរំលស់សមតុល្យថយចុះ |
| បរិក្ខារការិយាល័យ និងគ្រឿងសង្ហារឹម | ២០% | មូលដ្ឋានរំលស់សមតុល្យថយចុះ |

ដីមិនត្រូវបានធ្វើរំលស់ទេ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃសំណល់ ត្រូវបានវាយតម្លៃឡើងវិញនាចុងការិយបរិច្ឆេទនៃរបាយការណ៍ និងត្រូវបានធ្វើការកែតម្រូវប្រសិនបើវាមានភាពចាំបាច់។

## ៤.១៣ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានថ្លៃដើមអាជ្ញាបណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃ។ អាជ្ញាបណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មដោយផ្អែកលើមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់ និងយកកម្មវិធីនោះមកប្រើប្រាស់។

ទ្រព្យសកម្មអរូបីត្រូវបានរំលស់ដោយផ្អែកលើវិធីសាស្ត្ររំលស់សមតុល្យថយចុះក្នុងអត្រា ២០% ក្នុងមួយឆ្នាំ។

ថ្លៃដើមពាក់ព័ន្ធនឹងការអភិវឌ្ឍ ឬថែទាំកម្មវិធីកុំព្យូទ័រ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង។

ទ្រព្យសកម្មកំពុងដំណើរការ តំណាងឱ្យការទូទាត់សម្រាប់ការដំឡើងកម្មវិធីកុំព្យូទ័រនិងប្រព័ន្ធកុំព្យូទ័រ។ ទ្រព្យសកម្មកំពុងដំណើរការ ត្រូវបានចាប់ផ្តើម ធ្វើការរំលស់នៅពេលដែលទ្រព្យសកម្មទាំងនោះរួចរាល់ក្នុងការដាក់ឱ្យប្រើប្រាស់។

## ៤.១៤ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របដកថ្លៃដើមប្រតិបត្តិការដោយផ្ទាល់បន្ថែម និងបានវាស់វែងជាបន្តបន្ទាប់តាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## ៤.១៥ បំណុលបន្ទាប់បន្សំ

បំណុលបន្ទាប់បន្សំត្រូវបានចាត់ទុកជាបំណុលហិរញ្ញវត្ថុ នៅពេលដែលមានកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុទៅឱ្យអង្គភាពផ្សេងៗ ឬដើម្បីផ្លាស់ប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយអង្គភាពមួយផ្សេងទៀតនៅក្រោមលក្ខខណ្ឌដែលអាចមិនអំណោយផលដល់អង្គភាព បើមិនដូច្នេះទេ វាត្រូវបានចាត់ទុកជាមូលធន។ បំណុលបន្ទាប់បន្សំដែលត្រូវបានអនុម័តដោយធនាគារជាតិ នៃ កម្ពុជា ត្រូវបានរួមបញ្ចូលជាសមាសធាតុលំដាប់ទី២ នៅក្នុងការគណនាមូលធនផ្ទាល់សុទ្ធរបស់ធនាគារស្របតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃ កម្ពុជា។ បំណុលបន្ទាប់បន្សំត្រូវបានកំណត់តាមថ្លៃដើមបានរំលស់។

## ៤.១៦ ទ្រព្យសម្បត្តិបានរឹបអូស

ទ្រព្យសម្បត្តិបានរឹបអូសរួមមានទ្រព្យសម្បត្តិចលនវត្ថុ និងអចលនវត្ថុដែលត្រូវបានកំណត់តាមថ្លៃដើម ដកការខាតបង់ឱនភាពបង្គរ ប្រសិនបើមាន។

## ៤.១៧ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលដែលធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ហើយវាអាចទៅរួចដែលថាលំហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវបានទាមទារដើម្បីធ្វើការទូទាត់កាតព្វកិច្ច។ ប្រសិនបើផលប៉ះពាល់មានភាពជាសារវន្ត នោះសំវិធានធនត្រូវបានកំណត់ដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក ក្នុងអត្រាពន្ធមុន ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលា និងនៅពេលដែលមានភាពសមស្របដែលហានិភ័យជាក់លាក់បញ្ជាក់ក្នុងបំណុល។ ការមិនធ្វើអប្បហារ ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុ។

## ៤.១៨ ការប្រាក់

### អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ និងខាតដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ 'អត្រាការប្រាក់ប្រសិទ្ធភាព' គឺជាអត្រាអប្បហារតម្លៃជាក់លាក់ដែលប៉ាន់ស្មានក្នុងការទូទាត់សាច់ប្រាក់នាពេលអនាគត ឬទូទាត់វិក្កយបត្រតាមរយៈអាយុកាលដែលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុទៅនឹង៖

- សមតុល្យយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- ថ្លៃដើមបានរំលស់លើបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីឱនភាពឥណទានរបស់ទ្រព្យសកម្មដែលបានទិញ ឬប្រភពដើម ហើយធនាគារធ្វើការប៉ាន់ស្មាន លើលំហូរសាច់ប្រាក់នាពេលអនាគត ដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមែន ECL នោះទេ។ ចំពោះឱនភាពឥណទានរបស់ទ្រព្យសកម្មដែលបានទិញ ឬប្រភពដើម អត្រាការប្រាក់ប្រសិទ្ធភាពកែតម្រូវឥណទាន ត្រូវបានគណនាដោយប្រើប្រាស់លំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មានរួមទាំងការខាតបង់ឥណទានដែលបានរំពឹងទុកផងដែរ។

ការគណនាអត្រាការប្រាក់ដែលមានប្រសិទ្ធភាពរួមមានថ្លៃដើមប្រតិបត្តិការ និងកម្រៃសេវា និងនៅពេលដែលបានបង់ ឬបានទទួល ដែលជាផ្នែកសំខាន់នៃអត្រាការប្រាក់ប្រសិទ្ធភាព។ថ្លៃដើមប្រតិបត្តិការរួមមានចំណាយបន្ថែមដែលត្រូវបានបែងចែកដោយផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ។

### ថ្លៃដើមបានរំលស់ និងសមតុល្យយោងដុល

'ថ្លៃដើមបានរំលស់' របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាសមតុល្យដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនៅពេលទទួលស្គាល់ដំបូងដកការទូទាត់ប្រាក់ដើមបូក ឬដករំលស់បង្គរ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព នៃភាពខុសគ្នារវាងសមតុល្យដំបូង និងសមតុល្យតាមកាលបរិច្ឆេទផុតកំណត់សង និងសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ បានធ្វើការកែតម្រូវលើសំវិធានធននៃការខាតបង់ឥណទានដែលបានរំពឹងទុក។

'សមតុល្យយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ' គឺជាថ្លៃដើមបានរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុមុនពេលធ្វើការកែតម្រូវលើសំវិធានធនខាតបង់ឥណទានដែលបានរំពឹងទុក។

**ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់**
អត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនាលើការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ ក្នុងការគណនាចំណូល និងចំណាយ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានអនុវត្តទៅលើសមតុល្យយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មនោះមិនមានឱនភាពឥណទាន) ឬថ្លៃដើមបានរំលស់លើបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានកែប្រែដែលជាលទ្ធផលនៃការប៉ាន់ស្មានឡើងវិញតាមកាលកំណត់នៃលំហូរសាច់ប្រាក់នៃឧបករណ៍អត្រាអណ្តែត ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលទីផ្សារអត្រាការប្រាក់។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវបានកែប្រែផងដែរ សម្រាប់ការកែតម្រូវលើការការពារហានិភ័យនៃតម្លៃសមស្របនាកាលបរិច្ឆេទនៃការធ្វើរំលស់លើការចាប់ផ្តើមការការពារហានិភ័យដែលកែតម្រូវនេះ។

ទោះយ៉ាងណាក៏ដោយ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានឱនភាពឥណទានជាបន្តបន្ទាប់ទៅនឹងការទទួលស្គាល់ដំបូង ចំណូលការប្រាក់ ត្រូវបានគណនាដោយអនុវត្តអត្រាការប្រាក់ប្រសិទ្ធភាពតាមថ្លៃដើមបានរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មទាំងនោះ លែងមានឱនភាពឥណទាន នោះការគណនាចំណូលការប្រាក់នឹងត្រឡប់ទៅមូលដ្ឋានដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការទទួលស្គាល់ដំបូងនូវឱនភាពឥណទាន ចំណូលការប្រាក់ត្រូវបានគណនាដោយអនុវត្តតាមអត្រាការប្រាក់ប្រសិទ្ធភាពនៃការកែតម្រូវឥណទានទៅលើថ្លៃដើមបានរំលស់របស់ទ្រព្យសកម្ម។ ការគណនាចំណូលការប្រាក់ មិនត្រឡប់ទៅមូលដ្ឋានសរុបទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មមានភាពប្រសើរឡើងក៏ដោយ។

**ការបង្ហាញ**
ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ និងខាត និងចំណូលលម្អិតផ្សេងៗ រួមមានការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលធ្វើការវាស់វែងតាមថ្លៃដើមបានរំលស់។

ចំណាយការប្រាក់ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ និងខាត និងចំណូលកម្រិតផ្សេងៗ រួមមានបំណុលហិរញ្ញវត្ថុដែលធ្វើការវាស់វែងតាមថ្លៃដើមបានរំលស់។

## ៤.១៩ កម្រៃសេវា និងកម្រៃជើងសា
ចំណូល និងចំណាយលើកម្រៃសេវា និងកម្រៃជើងសាដែលជាផ្នែកសំខាន់ៗនៃអត្រាការប្រាក់ប្រសិទ្ធភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដែលត្រូវបានរាប់បញ្ចូលក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃសេវា និងកម្រៃជើងសាផ្សេងៗ - រួមមានគណនីកម្រៃសេវាដែលត្រូវបានទទួលស្គាល់ជាសេវាកម្មពាក់ព័ន្ធដែលត្រូវបានបំពេញ។

កិច្ចសន្យាជាមួយអតិថិជនដែលជាលទ្ធផលក្នុងការទទួលស្គាល់ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អាចជាផ្នែកខ្លះនៃវិសាលភាពរបស់ CIFRS ៩ និងផ្នែកខ្លះនៃវិសាលភាពរបស់ CIFRS ១៥។ ប្រសិនបើក្នុងករណីនេះ ធនាគារអនុវត្ត CIFRS ៩ ដំបូងដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យាដែលស្ថិតក្នុងវិសាលភាពរបស់ CIFRS ៩ និងបន្ទាប់មកបានអនុវត្តតាម CIFRS ១៥ លើតម្លៃសំណល់។

## ៤.២០ ឱនភាពតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ
សមតុល្យយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ធនាគារ (ក្រៅពីទ្រព្យសកម្មពន្ធពន្យារ) ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃឬទេ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង នោះការប៉ាន់ស្មានលើសមតុល្យដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។ ចំពោះទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ឬមិនទាន់អាចប្រើប្រាស់បាន សមតុល្យដែលអាចប្រមូលមកវិញបានត្រូវធ្វើការប៉ាន់ស្មានជារៀងរាល់ឆ្នាំក្នុងពេលតែមួយ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើសមតុល្យយោងរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ (CGU) លើសពីការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាន។

សម្រាប់ការធ្វើតេស្តលើឱនភាពតម្លៃ ទ្រព្យសកម្មត្រូវបានដាក់ជាក្រុមរួមគ្នាទៅជាក្រុមតូចបំផុតនៃទ្រព្យសកម្មដែលបង្កើតលំហូរសាច់ប្រាក់ពីការប្រើប្រាស់បន្ត ដែលភាគច្រើនមិនអាស្រ័យលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មផ្សេងទៀត ឬ CGUs។

សមតុល្យដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃក្នុងការប្រើប្រាស់ និងតម្លៃសមស្រប ដកថ្លៃដើមដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃក្នុងការប្រើប្រាស់ ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារទៅនឹងតម្លៃបច្ចុប្បន្ន ដោយប្រើអប្បហារអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ស្មានតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់។

សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពតម្លៃនៃទ្រព្យសកម្មដែលមិនអាចធ្វើតេស្តដាច់ដោយឡែក ត្រូវបានដាក់ជាក្រុមរួមគ្នាទៅជាក្រុមតូចបំផុតនៃ ទ្រព្យសកម្ម ដែលបង្កើតលំហូរសាច់ប្រាក់ពីការប្រើប្រាស់បន្ត ហើយភាគច្រើនស្ថិតនៅក្រៅលំហូរចូលសាច់ប្រាក់នៃទ្រព្យសកម្មផ្សេងទៀត ឬCGUs។

ការខាតបង់ឱនភាពតម្លៃត្រូវបានទទួលស្គាល់គណនីចំណេញ និងខាត។ ការខាតបង់ឱនភាពតម្លៃ បានទទួលស្គាល់លើ CGUs ដែលត្រូវបានបែងចែកដំបូងដើម្បីកាត់បន្ថយសមតុល្យយោងនៃមូលនិធិពាណិជ្ជកម្មដែលបានបែងចែកទៅ CGU (ក្រុមនៃ CGUs) និងបន្ទាប់មកកាត់បន្ថយសមតុល្យយោងរបស់ទ្រព្យសកម្មផ្សេងទៀតនៅក្នុង CGUs (ក្រុមរបស់ CGUs) លើមូលដ្ឋានអនុបាត។

ការខាតបង់ឱនភាពតម្លៃដែលបានទទួលស្គាល់ក្នុងអំឡុងពេលមុនៗ ត្រូវបានធ្វើការវាយតម្លៃនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ សម្រាប់សូចនាករណាមួយដែលបង្ហាញថាការខាតបង់ត្រូវបានថយចុះ ឬលែងមានទៀតឡើយ។ ការខាតបង់ឱនភាពតម្លៃត្រូវបានកត់ត្រាបញ្ច្រាសប្រសិនបើមានការផ្លាស់ប្តូរការប៉ាន់ស្មានដែលបានប្រើប្រាស់ដើម្បីកំណត់សមតុល្យដែលអាចប្រមូលបានមកវិញ។ ការខាតបង់ឱនភាពតម្លៃត្រូវបានកត់ត្រាបញ្ច្រាសទៅនឹងទំហំដែលសមតុល្យយោងរបស់ទ្រព្យសកម្ម មិនលើសពីសមតុល្យយោងដែលបានកំណត់ រំលស់ទ្រព្យសកម្មរូបីសុទ្ធ ឬរំលស់នៃទ្រព្យសកម្មអរូបីសុទ្ធ ប្រសិនបើមិនមានឱនភាពតម្លៃណាមួយត្រូវបានទទួលស្គាល់។

## ៤.២១ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលរួមមានពន្ធបច្ចុប្បន្ន និងពន្ធពន្យារ។ វាត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ និងខាត លើកលែងតែសមាសធាតុ ដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬនៅក្នុងចំណូលលម្អិតផ្សេងៗ។

ធនាគារបានកំណត់ថាការប្រាក់ និងការពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណូល រួមទាំងការកំណត់ពន្ធមិនប្រាកដប្រជា គឺមិនបានបំពេញនូវនិយមន័យនៃពន្ធលើប្រាក់ចំណូលទេ ហេតុដូចនេះត្រូវបានកត់ត្រាគណនីទាំងនេះក្រោម CIAS ៣៧ សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ និងបានទទួលស្គាល់ការចំណាយដែលពាក់ព័ន្ធទាំងនេះនៅក្នុងគណនី 'ការចំណាយផ្សេងៗ'។

### (១) ពន្ធបច្ចុប្បន្ន

ពន្ធបច្ចុប្បន្នរួមមានការរំពឹងទុកលើពន្ធដែលត្រូវបង់ ឬត្រូវទទួលលើប្រាក់ចំណូលជាប់ពន្ធសម្រាប់រយៈពេលដែលប្រើប្រាស់អត្រាពន្ធដែលត្រូវបានអនុម័ត ឬត្រូវបានអនុម័តសំខាន់ៗនៅកាលបរិច្ឆេទនៃរបាយការណ៍ និងការកែតម្រូវពន្ធដែលត្រូវបង់ក្នុងការិយបរិច្ឆេទមុន។

### (២) ពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់ចំពោះភាពខុសគ្នាបណ្តោះអាសន្នរវាងសមតុល្យយោងនៃទ្រព្យសកម្ម និងបំណុល សម្រាប់គោលបំណងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសមតុល្យដែលបានប្រើប្រាស់សម្រាប់គោលបំណងពន្ធ។

ទ្រព្យសកម្មពន្ធពន្យារត្រូវបានទទួលស្គាល់ចំពោះការខាតបង់ពន្ធដែលមិនបានប្រើ និងភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបានដើម្បីពង្រីកវិសាលភាពដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើបានបើប្រៀបធៀបនឹងប្រាក់ចំណេញដែលអាចប្រើប្រាស់បាន។ ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានពិនិត្យក្នុងកាលបរិច្ឆទនៃរបាយការណ៍នីមួយៗ និងបានកាត់បន្ថយក្នុងកម្រិតដែលវាអាចនឹងមិនអាចទទួលបាននូវអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធ។ ការកាត់បន្ថយបែបនេះ ត្រូវបានកត់ត្រាបញ្ច្រាស នៅពេលដែលប្រូបាប៊ីលីតេនៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានភាពប្រសើរឡើង។

ពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថានឹងត្រូវបានអនុវត្តចំពោះភាពខុសគ្នាបណ្តោះអាសន្ន នៅពេលដែលធ្វើការកត់ត្រាបញ្ច្រាសដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬត្រូវបានអនុម័តសំខាន់ៗនាកាលបរិច្ឆេទនៃរបាយការណ៍។

ការវាស់វែងពន្ធពន្យារឆ្លុះបញ្ចាំងពីផលវិបាកពន្ធដែលនឹងអនុវត្តតាមលក្ខណៈដែលធនាគាររំពឹងនាកាលបរិច្ឆេទនៃរបាយការណ៍ ដើម្បីប្រមូលមកវិញ ឬទូទាត់លើសមតុល្យយោងរបស់ទ្រព្យសកម្ម និងបំណុល។ ទ្រព្យសកម្ម និងបំណុលពន្ធពន្យារ ត្រូវបានកាត់កងលុះត្រាតែលក្ខណៈវិនិច្ឆ័យជាក់លាក់ត្រូវបានបំពេញ។

## ៤.២២ បំណុលយថាហេតុ

ក្នុងករណីដែលមិនតម្រូវឱ្យមានការហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬសមតុល្យដែលមិនអាចប៉ាន់ស្មានបានដោយជឿទុកចិត្ត នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ ហើយវាត្រូវបានបង្ហាញថាជាបំណុលយថាភាព លើកលែងតែប្រូបាប៊ីលីតេនៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ដែលអត្ថិភាពនៃកាតព្វកិច្ច នឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ត្រូវបានបង្ហាញថាជាបំណុលយថាភាពដែលអាចកើតមានឡើង លុះត្រាតែប្រូបាប៊ីលីតេនៃការហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។

## ៤.២៣ ទ្រព្យសកម្មយថាហេតុ

ក្នុងករណីដែលមិនមានលទ្ធភាពហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬសមតុល្យដែលមិនអាចប៉ាន់ស្មានបានដោយជឿទុកចិត្ត នោះទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឡើយ ហើយវាត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាហេតុ លើកលែងតែប្រូបាប៊ីលីតេនៃលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ចគឺស្ទើរតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ប៉ុន្តែអត្ថិភាពនៃទ្រព្យសកម្មនឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ក៏ត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាហេតុដែលអាចកើតមានឡើងលុះត្រាតែប្រូបាប៊ីលីតេនៃការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។

## ៤.២៤ ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ គឺជាបុគ្គល ឬអង្គភាពដែលមានទំនាក់ទំនងជាមួយធនាគារ។ ប្រតិបត្តិការភាគីពាក់ព័ន្ធ គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងធនាគារ និងភាគីពាក់ព័ន្ធរបស់ខ្លួនទោះបីជាបានគិតថ្លៃ ឬមិនបានគិតថ្លៃ។

(១). បុគ្គល ឬមនុស្សដែលជិតស្និទ្ធជាមួយបុគ្គលនៃគ្រួសារនោះ គឺមានការពាក់ព័ន្ធជាមួយធនាគារ ប្រសិនបើបុគ្គលនោះ៖

- ក មានសិទ្ធិគ្រប់គ្រង ឬចូលរួមក្នុងការគ្រប់គ្រងលើធនាគារ
- ខ មានឥទ្ធិពលខ្លាំងលើធនាគារ ឬ
- គ គឺជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗរបស់ធនាគារ។

(២). អង្គភាពដែលចាត់ចូលជាភាគីពាក់ព័ន្ធរបស់ធនាគារ ប្រសិនបើស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ក ធនាគារ គឺជាសមាជិកនៃសម្ព័ន្ធតែមួយ
- ខ អង្គភាពមួយដែលជាការចូលរួម ឬការបណ្តាក់ទុនរួមគ្នានៃអង្គភាពផ្សេងទៀត
- គ អង្គភាពទាំងពីរធ្វើការបណ្តាក់ទុនរួមលើភាគីទីបីដូចគ្នា
- ឃ អង្គភាពមួយ គឺជាភាគហ៊ុនរួមនៃអង្គភាពភាគីទីបី និងអង្គភាពផ្សេងទៀត គឺជាអង្គភាពរួមបញ្ចូលគ្នានៃភាគីទីបី
- ង អង្គភាព គឺជាគម្រោងអត្ថប្រយោជន៍ក្រោយការងារសម្រាប់អត្ថប្រយោជន៍របស់និយោជិតធនាគារ
- ច អង្គភាពត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយបុគ្គលដែលបានបញ្ជាក់នៅក្នុងចំណុច (១) ខាងលើ
- ឆ បុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុងចំណុច (១).ក ខាងលើមានឥទ្ធិពលគួរឱ្យកត់សម្គាល់លើអង្គភាព ឬជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗ ដែលកំពុងកាន់កាប់ជាធនាគារ ឬអង្គភាព
- ជ អង្គភាព ឬសមាជិកនៃសម្ព័ន្ធ ដែលជាផ្នែកមួយផ្តល់នូវសេវាកម្មគ្រប់គ្រងសំខាន់ៗដល់ធនាគារ។

## ៥. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ធនាគារបានធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យពាក់ព័ន្ធទៅនឹងប្រតិបត្តិការនាពេលអនាគតដែលអាចនឹងមិនស្មើជាមួយនឹងលទ្ធផលជាក់ស្តែង។ ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យ ដែលអាចធ្វើឱ្យមានផលប៉ះពាល់ជាសារវន្តទៅលើការទទួលស្គាល់បច្ចុប្បន្ន និងការវាស់វែងលើទ្រព្យសកម្ម បំណុល ចំណូល និងចំណាយត្រូវបានសង្ខេបដូចខាងក្រោម៖

### ក. ការប៉ាន់ស្មានគណនេយ្យ និងការសន្មតសំខាន់ៗ

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ដែលអាចធ្វើឱ្យមានការកែតម្រូវលើសមតុល្យយោងនៃទ្រព្យសកម្ម និងបំណុលត្រូវបានរួមបញ្ចូលក្នុងកំណត់សម្គាល់ដូចខាងក្រោម៖

- កំណត់សម្គាល់លេខ ៤.៤(៦)៖ ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុដែលធាតុចូលមិនអាចអង្កេតបាន។
- កំណត់សម្គាល់លេខ ៤.៤ (៧)៖ ឱនភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ធាតុចូលទៅក្នុងគំរូនៃការវាស់វែងលើការខាតបង់ឥណទានដែលបានរំពឹងទុក រួមទាំងការបញ្ចូលព័ត៌មានយោងទៅមុខ។
- កំណត់សម្គាល់លេខ ៤.៤ (៧)៖ ឱនភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ ការសន្មត់សំខាន់ៗ ដែលបានប្រើក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលអាចប្រមូលមកវិញបាន។

### ខ. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានផលប៉ះពាល់ជាសារវន្ត លើសមតុល្យដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលនៅក្នុងកំណត់សម្គាល់ដូចខាងក្រោម៖

- កំណត់សម្គាល់លេខ ៤.៤ (២)៖ ការចាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃគំរូអាជីវកម្មដែលទ្រព្យសកម្មទាំងនោះត្រូវបានកាន់កាប់ និងវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ (“SPPI”) លើសមតុល្យប្រាក់ដើមដែលនៅសល់។
- កំណត់សម្គាល់លេខ ៤.៤ (៧)៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្ត្រសម្រាប់បញ្ចូលព័ត៌មានយោងទៅមុខទៅក្នុងការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន ("ECL") និងការជ្រើសរើស និងអនុម័តលើគំរូដែលបានប្រើដើម្បីវាស់វែងលើការខាតបង់ឥណទានដែលបានរំពឹងទុក។
- កំណត់សម្គាល់លេខ ៣១.ខ (៧)៖ គុណភាពឥណទាននៃឥណទាន និងបុរេប្រទានផ្តល់ជូនអតិថិជនដុល ការដាក់បញ្ចូលព័ត៌មានយោងទៅមុខ។

## ៦. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ក្នុងដៃត្រូវបានវិភាគបន្ថែមដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| សាច់ប្រាក់ក្នុងដៃ | **២.២៥៥.៩៣៨** | **៩.២៨៧.៦៩៧** | ៣.០៨៥.២៦៧ | ១២.៥៦៩.៣៨០ | ៨០៧.៧៨៦ | ៣.២៦៧.៤៩៤ |
| សមតុល្យជាមួយធនាគារផ្សេងៗ | **៤.៣១០.៨០៦** | **១៧.៧៤៧.៥៨៩** | ៣.៧៣១.១០៤ | ១៥.២០០.៥១៨ | ២៧.៣៣៧.១៦៦ | ១១០.៥៧៨.៨៣៥ |
| សមតុល្យជាមួយធនាគារជាតិ នៃកម្ពុជា | **៩០៤.៩២០** | **៣.៧២៥.៥៥៦** | ៣៥១.៥៦៨ | ១.៤៣២.២៨៨ | ២០.៧១០.០៤២ | ៨៣.៧៧២.១២០ |
| | **៧.៤៧១.៦៦៤** | **៣០.៧៦០.៨៤២** | ៧.១៦៧.៩៣៩ | ២៩.២០២.១៨៦ | ៤៨.៨៥៤.៩៩៤ | ១៩៧.៦១៨.៤៤៩ |
| ដកសំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃ | **(៣៧.៣៧២)** | **(១៥៣.៨៦២)** | (៣០.៥៨៥) | (១២៤.៦០៦) | (២៦៤.២២៥) | (១.០៦៨.៧៨៨) |
| | **៧.៤៣៤.២៩២** | **៣០.៦០៦.៩៨០** | ៧.១៣៧.៣៥៤ | ២៩.០៧៧.៥៨០ | ៤៨.៥៩០.៧៦៩ | ១៩៦.៥៤៩.៦៦១ |

សមតុល្យជាមួយធនាគារផ្សេងៗ និងសមតុល្យជាមួយធនាគារជាតិ នៃ កម្ពុជា គឺជាគណនីចរន្ត និងគណនីសន្សំ និងមិនទទួលបានការប្រាក់ឡើយ។

បម្រែបម្រួលនៃសំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃ មានដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| នាថ្ងៃទី១ ខែមករា | **៣០.៥៨៥** | **១២៤.៦០៦** | ២៦៤.២២៥ | ១.០៦៨.៧៨៩ | ៤៧.០១១ | ១៩១.៥៧០ |
| សំវិធានធន/(ការកត់ត្រាបញ្ច្រាស) ក្នុងការិយបរិច្ឆេទ | **៦.៧៨៧** | **២៧.៧៣៨** | (២៣៣.៦៤០) | (៩៥០.៤៤៨) | ២១៧.២១៤ | ៨៨៥.៥៨១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **១.៥១៨** | - | ៦.២៦៥ | - | (៨.៣៦៣) |
| នាថ្ងៃទី៣១ ខែធ្នូ | **៣៧.៣៧២** | **១៥៣.៨៦២** | ៣០.៥៨៥ | ១២៤.៦០៦ | ២៦៤.២២៥ | ១.០៦៨.៧៨៨ |

## ៧. ប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ធនាគារផ្សេងៗ | **២៧៩.៩៥៦** | **១.១៥២.៥៧៩** | ៣២០.០០០ | ១.៣០៣.៦៨០ | - | - |
| ដកសំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ | **(៥.៤៦១)** | **(២២.៤៨៣)** | (៣.១៧៣) | (១២.៩២៧) | - | - |
| | **២៧៤.៤៩៥** | **១.១៣០.០៩៦** | ៣១៦.៨២៧ | ១.២៩០.៧៥៣ | - | - |

ប្រាក់តម្កល់នេះតំណាងឱ្យសមតុល្យដែលបានដាក់កំហិតឱ្យរក្សាទុកនៅក្នុងធនាគារក្នុងស្រុក និងមិនទទួលបានការប្រាក់នោះទេ។

បម្រែបម្រួលនៃសំវិធានធនសម្រាប់ការខាតបង់ឱនភាពមានដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| នាថ្ងៃទី១ ខែមករា | **៣.១៧៣** | **១២.៩២៧** | - | - | - | - |
| សំវិធានធនក្នុងការិយបរិច្ឆេទ | **២.២៨៨** | **៩.៣៥១** | ៣.១៧៣ | ១២.៩០៨ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **២០៥** | - | ១៩ | - | - |
| នាថ្ងៃទី៣១ ខែធ្នូ | **៥.៤៦១** | **២២.៤៨៣** | ៣.១៧៣ | ១២.៩២៧ | - | - |

## ៨. ប្រាក់តម្កល់តាមបទប្បញ្ញត្តិ

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ដើមទុនតម្កល់តាមបទប្បញ្ញត្តិ | **១២.៩៤០.៨៣២** | **៥៣.២៧៧.៤០៤** | ៨.៩១៩.៧៦១ | ៣៦.៣៣៩.១០៦ | ៨.៩៧៥.៣៧៧ | ៣៦.៣០៥.៤០០ |
| ប្រាក់បម្រុងកាតព្វកិច្ច លើប្រាក់បញ្ញើអតិថិជន | **៩១៧.៨០៤** | **៣.៧៧៨.៦០០** | ៨៧៨.៥៤៧ | ៣.៥៧៩.២០១ | ៤២៦.៧៤៩ | ១.៧២៦.២០០ |
| | **១៣.៨៥៨.៦៣៦** | **៥៧.០៥៦.០០៤** | ៩.៧៩៨.៣០៨ | ៣៩.៩១៨.៣០៧ | ៩.៤០២.១២៦ | ៣៨.០៣១.៦០០ |

### ក. ប្រាក់បញ្ញើដើមទុនតាមបទប្បញ្ញត្តិ

ស្ថិតក្រោមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជាលេខ ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ធនាគារតម្រូវឱ្យរក្សាទុកប្រាក់តម្កល់ធានា ១០% នៃដើមទុនដែលបានបង់។ សមតុល្យខាងលើតំណាងឱ្យ ១០% នៃដើមទុនដែលបានបង់បូកនឹងដើមទុនផ្សេងៗលើតណទានដើមដែលមិនដំណើរការ ដកសមតុល្យដែលអាចប្រមូលបានវិញនៅក្នុងអំឡុងការិយបរិច្ឆេទ (សូមមើលកំណត់សម្គាល់ ២១ (ក))។ ប្រាក់តម្កល់នេះ អាចដកយកវិញបាននៅពេលដែលធនាគារស្ម័គ្រចិត្តបញ្ចប់អាជីវកម្មរបស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារបានឡើយ។ ប្រាក់តម្កល់ធានាដើមទុន មានអត្រាការប្រាក់ចាប់ពី ០,០៤% ទៅ ៣% (ឆ្នាំ២០២១៖ ០,០៤% ទៅ ៣%) ក្នុងមួយឆ្នាំ។

### ខ. ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើអតិថិជន

អនុលោមតាមប្រកាសលេខ ធ៧-០២០-២៣០ របស់ធនាគារជាតិ នៃ កម្ពុជា ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុតម្រូវឱ្យរក្សាប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវបានគណនាក្នុងអត្រា ៧% សម្រាប់រូបិយប័ណ្ណខ្មែររៀល និងរូបិយប័ណ្ណផ្សេងៗ នៃចំនួនសមតុល្យជាមធ្យមប្រចាំថ្ងៃសរុបនៃប្រាក់បញ្ញើពីអតិថិជន និងប្រាក់កម្ចីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅធនាគារជាតិ នៃ កម្ពុជា។

### គ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)

| | **ឆ្នាំ២០២២** | ឆ្នាំ២០២១ |
|---|---|---|
| ដើមទុនតម្កល់តាមបទប្បញ្ញត្តិ | **០,០៤%-៣%** | ០,០៤%-៣% |
| ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើពីអតិថិជន | **មិនមាន** | មិនមាន |

## ៩. ឥណទាន និងបុរេប្រទានផ្តល់ជូនអតិថិជន - សុទ្ធ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ឥណទាន និងបុរេប្រទានរយៈពេលវែង | **២៧៤.៣០១.០០១** | **១.១២៩.២៩៧.២២១** | ២០២.៣៤៦.៧២១ | ៨២៤.៣៦០.៥៤១ | ១៧១.០០១.៥៥៨ | ៦៩១.៧០១.៣០២ |
| ឥណទាន និងបុរេប្រទានរយៈពេលខ្លី | **៩៣.៦២៥.៨៧០** | **៣៨៥.៤៥៧.៧០៩** | ៨៣.៦៥៥.៩៣៧ | ៣៤០.៨១៤.២៨៧ | ៧១.៦២៨.៧៩៩ | ២៨៩.៧៣៨.៤៩២ |
| ឥណទានផ្តល់ជូនបុគ្គលិក | **១៦.៨១៦.៩៩៨** | **៦៩.២៣៥.៥៨២** | ១៦.៤១៥.៤៦៤ | ៦៦.៨៧៦.៦០០ | ៣.២៣៧.៩០៦ | ១៣.០៩៧.៣៣០ |
| **ឥណទាន និងបុរេប្រទានដុល** | **៣៨៤.៧៤៣.៨៦៩** | **១.៥៨៣.៩៩០.៥១២** | ៣០២.៤១៨.១២២ | ១.២៣២.០៥១.៤២៨ | ២៤៥.៨៦៨.២៦៣ | ៩៩៤.៥៣៧.១២៤ |
| ការប្រាក់បង្គរដែលទទួលបាន | **៣.៤៩៩.៥១៦** | **១៤.៣៨៦.៩២២** | ៣.១១៣.៧៨៦ | ១២.៦៨៥.៥៦៩ | ៣.០៧៩.៨៨៤ | ១២.៤៥៨.១៣០ |
| ចំណូលដែលមិនទាន់ទទួលបាន | **(១.៧៩២.៤៨៨)** | **(៧.៣៧៩.៦៧២)** | (១.០០៤.៥៥០) | (៤.០៩២.៥៣៧) | (៨៧២.២០៩) | (៣.៥២៨.០៨៥) |
| | **៣៨៦.៤៥៥.៨៩៨** | **១.៥៩០.៩៩៧.៧៦២** | ៣០៤.៥២៧.៣៥៨ | ១.២៤០.៦៤៤.៤៦០ | ២៤៨.០៧៥.៩៣៨ | ១.០០៣.៤៦៧.១៦៩ |
| ដកសំវិធានធនសម្រាប់ការខាតបង់ ឱនភាពនៃតម្លៃ | **(២២.៦៦៩.៦៧៩)** | **(៩៣.៣៣១.០៦៨)** | (២៥.២១៤.៤២០) | (១០២.៧២៣.៥៥១) | (១៥.១៧០.៣២៩) | (៦១.៣៦៣.៩៨១) |
| **ឥណទាន និងបុរេប្រទានផ្តល់ជូនដល់ អតិថិជន - សុទ្ធ** | **៣៦៣.៧៧៦.២១៩** | **១.៤៩៧.៦៦៦.៦៩៤** | ២៧៩.៣១២.៩៣៨ | ១.១៣៧.៩២០.៩០៩ | ២៣២.៩០៥.៦០៩ | ៩៤២.១០៣.១៨៨ |

បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ មានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| នាថ្ងៃទី១ ខែមករា | **២៥.២១៤.៤២០** | **១០២.៧២៣.៥៥១** | ១៥.១៧០.៣២៩ | ៦១.៣៦៣.៩៨១ | ៤.២០៤.៧០៨ | ១៧.១៣៤.១៨៥ |
| សំវិធានធនក្នុងការិយបរិច្ឆេទ | **(២.៥៤៤.៧៤០)** | **(១០.៤០០.៣៥២)** | ១០.០៤៤.០៩១ | ៤០.៨៥៩.៣៦២ | ១០.៩៦៥.៦២១ | ៤៤.៧០៦.៨៣៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **១.០០៧.៨៦៩** | - | ៥០០.២០៨ | - | (៤៧៧.០៤១) |
| នាថ្ងៃទី៣១ ខែធ្នូ | **២២.៦៦៩.៦៧៩** | **៩៣.៣៣១.០៦៨** | ២៥.២១៤.៤២០ | ១០២.៧២៣.៥៥១ | ១៥.១៧០.៣២៩ | ៦១.៣៦៣.៩៨១ |

សមតុល្យឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុលតាមកាលបរិច្ឆេទផុតកំណត់សង ត្រូវបានវិភាគដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **តាមកាលកំណត់៖** | | | | | | |
| > ១ ទៅ ៣ ខែ | **១៧.៩៣៦.៦៣១** | **៧៣.៨៤៥.១១០** | ១៥.៨៩៩.២៩១ | ៦៤.៧៧៣.៧១២ | ១៥.៨៦៥.៤៣៣ | ៦៤.១៧៥.៦៧៦ |
| > ៣ ទៅ ១២ ខែ | **៨៣.៧៥៦.៨៤៣** | **៣៤៤.៨២៦.៩២៣** | ២.៥១៤.៨៧៧ | ១០.២៤៥.៦០៩ | ២.៩៣៦.៥៩៧ | ១១.៨៧៨.៥៣៥ |
| > ១ ទៅ ៣ ឆ្នាំ | **៤៦.១៦៤.៣០៩** | **១៩០.០៥៨.៤៦០** | ៧៧.៤៤៤.០៦៩ | ៣១៥.៥០៧.១៣៧ | ៨១.៨៦០.៥០៩ | ៣៣១.១២៥.៧៥៩ |
| > ៣ ទៅ ៥ ឆ្នាំ | **៦៩.៥៦៦.៨៩៦** | **២៨៦.៤០៦.៩១១** | ៥៨.៧៩១.៣៨១ | ២៣៩.៥១៦.០៨៦ | ៤៨.១៣៧.១៥១ | ១៩៤.៧១៤.៧៧៦ |
| លើសពី ៥ ឆ្នាំ | **១៦៧.៣១៩.១៩០** | **៦៨៨.៨៥៣.១០៨** | ១៤៧.៧៦៨.៥០៤ | ៦០២.០០៨.៨៨៤ | ៩៧.០៦៨.៥៧៣ | ៣៩២.៦៤២.៣៧៨ |
| | **៣៨៤.៧៤៣.៨៦៩** | **១.៥៨៣.៩៩០.៥១២** | ៣០២.៤១៨.១២២ | ១.២៣២.០៥១.៤២៨ | ២៤៥.៨៦៨.២៦៣ | ៩៩៤.៥៣៧.១២៤ |

សម្រាប់ការវិភាគបន្ថែមលើសមតុល្យឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល សូមមើលកំណត់សម្គាល់លេខ ៣១(ខ)។

## ១០. ទ្រព្យសម្បត្តិបានរឹបអូស

ទ្រព្យសម្បត្តិបានរឹបអូសរួមមានទ្រព្យសម្បត្តិចលនវត្ថុ និងអចលនវត្ថុ ដែលទទួលបានតាមរយៈការរឹបអូសទ្រព្យបញ្ចាំពីឥណទាន និងបុរេប្រទាន ដែលផ្តល់ជូនអតិថិជននៃការខកខានទូទាត់សង ដែលបានផ្ទេរទៅធនាគារជាផ្នែកនៃការទូទាត់បំណុល។

ទ្រព្យសកម្មទាំងនេះមិនត្រូវបានរក្សាទុកក្នុងគោលបំណងធ្វើប្រតិបត្តិការទេ ហើយត្រូវបានលក់ចេញដើម្បីទូទាត់ជាមួយសមតុល្យដែលនៅសល់ ក្នុងអំឡុងពេលដែលមានការអនុញ្ញាតត្រឹមដប់ពីរខែជាអតិបរមា តាមសេចក្តីណែនាំប្រកាសលេខ ធ៧-០១-១៨៦ ដែលបានចេញផ្សាយដោយ ធនាគារជាតិ នៃ កម្ពុជា។

| | ដី | អគារ | បរិក្ខារ | សរុប | |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **ថ្លៃដើម** | | | | | |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | **២.៨៥២.៤១៣** | **៨៨៥.៨២០** | **៦៨០.៣៨៦** | **៤.៤១៨.៦១៩** | **១៨.០០១.៤៥៤** |
| **ទិញបន្ថែម** | **៣០៥.៩៨៧** | **៤៩៧.៦៨៩** | **-** | **៨០៣.៦៧៦** | **៣.២៨៤.៦២៣** |
| **លម្អៀងពីការប្តូររូបិយប័ណ្ណ** | **-** | **-** | **-** | **-** | **២១៤.១១១** |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៣.១៥៨.៤០០** | **១.៣៨៣.៥០៩** | **៦៨០.៣៨៦** | **៥.២២២.២៩៥** | **២១.៥០០.១៨៨** |
| **ដក សំវិធានធនលើឱនភាពនៃតម្លៃ** | | | | | |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | **-** | **១៣២.៨៧៣** | **៥៣៧.៥១២** | **៦៧០.៣៨៥** | **២.៧៣១.១៤៩** |
| **ការខាតបង់ឱនភាពនៃតម្លៃក្នុងអំឡុងការិយបរិច្ឆេទ** | **-** | **៦៩.១៧៥** | **១៧០.០៩៧** | **២៣៩.២៧២** | **៩៧៧.៩០៥** |
| **លម្អៀងពីការប្តូររូបិយប័ណ្ណ** | **-** | **-** | **-** | **-** | **៣៦.០០៣** |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **-** | **២០២.០៤៨** | **៧០៧.៦០៩** | **៩០៩.៦៥៧** | **៣.៧៤៥.០៥៧** |
| **សមតុល្យយោងនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៣.១៥៨.៤០០** | **១.១៨១.៤៦១** | **២៧.២២៣** | **៤.៣១២.៦៣៨** | **១៧.៧៥៥.១៣១** |
| ថ្លៃដើម | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ២.៧៨៦.១៥០ | ៨៨៥.៨២០ | ៦៨០.៣៨៦ | ៤.៣៥២.៣៥៦ | ១៧.៦០៥.២៨០ |
| ទិញបន្ថែម | ៦៦.២៦៣ | - | - | ៦៦.២៦៣ | ២៦៩.៥៥៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | ១២៦.៦១៦ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ២.៨៥២.៤១៣ | ៨៨៥.៨២០ | ៦៨០.៣៨៦ | ៤.៤១៨.៦១៩ | ១៨.០០១.៤៥៤ |
| ដក សំវិធានធនលើឱនភាពនៃតម្លៃ | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | - | ៨៨.៥៨២ | ៤៨៩.៨៨៧ | ៥៧៨.៤៦៩ | ២.៣៣៩.៩០៧ |
| ការខាតបង់ឱនភាពនៃតម្លៃក្នុងអំឡុងការិយបរិច្ឆេទ | - | ៤៤.២៩១ | ៤៧.៦២៥ | ៩១.៩១៦ | ៣៧៣.៩១៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | ១៧.៣២៨ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | - | ១៣២.៨៧៣ | ៥៣៧.៥១២ | ៦៧០.៣៨៥ | ២.៧៣១.១៤៩ |
| សមតុល្យយោងនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ២.៨៥២.៤១៣ | ៧៥២.៩៤៧ | ១៤២.៨៧៤ | ៣.៧៤៨.២៣៤ | ១៥.២៧០.៣០៥ |

## ១០. ទ្រព្យសម្បត្តិបានរឹបអូស (ត)

| | ដី<br>ដុល្លារអាមេរិក | អគារ<br>ដុល្លារអាមេរិក | បរិក្ខារ<br>ដុល្លារអាមេរិក | ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ២.៧៨៦.១៥០ | ៨៨៥.៨២០ | ៦៨០.៣៨៦ | ៤.៣៥២.៣៥៦ | ១៧.៧៣៥.៨៥១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (១៣០.៥៧១) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ២.៧៨៦.១៥០ | ៨៨៥.៨២០ | ៦៨០.៣៨៦ | ៤.៣៥២.៣៥៦ | ១៧.៦០៥.២៨០ |
| **ដក សំវិធានធនលើឱនភាពនៃតម្លៃ** | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | - | ៤៤.២៩១ | ៤២៦.៣៨៧ | ៤៧០.៦៧៨ | ១.៩១៨.០១២ |
| ការខាតបង់ឱនភាពនៃតម្លៃក្នុងអំឡុងការិយបរិច្ឆេទ | - | ៤៤.២៩១ | ៦៣.៥០០ | ១០៧.៧៩១ | ៤៣៩.៤៦៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (១៧.៥៦៩) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | - | ៨៨.៥៨២ | ៤៨៩.៨៨៧ | ៥៧៨.៤៦៩ | ២.៣៣៩.៩០៧ |
| សមតុល្យយោងនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ២.៧៨៦.១៥០ | ៧៩៧.២៣៨ | ១៩០.៤៩៩ | ៣.៧៧៣.៨៨៧ | ១៥.២៦៥.៣៧៣ |

## ១១. ទ្រព្យសកម្មផ្សេងៗ

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល<br>(កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) |
| ការទូទាត់បុរេប្រទានទៅអ្នកផ្គត់ផ្គង់ | **១.៥០០.០៧០** | **៦.១៧៥.៧៩០** | ២១០.០០២ | ៨៥៥.៥៤៨ | ៩៤.៥៥១ | ៣៨២.៤៥៩ |
| ការបង់ធានារ៉ាប់រងជាមុន | **៥៧.០៥១** | **២៣៤.៨៧៨** | ១២១.២៣៦ | ៤៩៣.៩១៥ | ៤២.៧៨៥ | ១៧៣.០៦៥ |
| ការវិនិយោគក្នុងការបណ្តាក់ទុនរួមគ្នា (*) | **៣៨៥.០០០** | **១.៥៨៥.០៤៥** | ៣៤០.០០០ | ១.៣៨៥.១៦០ | ៣៤០.០០០ | ១.៣៧៥.៣០០ |
| ផ្សេងៗ | **២៧៤.១៨៥** | **១.១២៨.៨២០** | ២១៨.២៤២ | ៨៨៩.១១៨ | ១៤៣.៧៥៤ | ៥៨១.៤៨៥ |
| | **២.២១៦.៣០៦** | **៩.១២៤.៥៣៣** | ៨៨៩.៤៨០ | ៣.៦២៣.៧៤១ | ៦២១.០៩០ | ២.៥១២.៣០៩ |
| ដក សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ | **(៣៤៣.៥៩៥)** | **(១.៤១៤.៥៨២)** | (២៥២.៥៦០) | (១.០២៨.៩២៩) | (១៥១.៨០៦) | (៦១៤.០៥៥) |
| | **១.៨៧២.៧១១** | **៧.៧០៩.៩៥១** | ៦៣៦.៩២០ | ២.៥៩៤.៨១២ | ៤៦៩.២៨៤ | ១.៨៩៨.២៥៤ |

(*) ការវិនិយោគនេះតំណាងឱ្យការវិនិយោគក្នុងការបណ្តាក់ទុនរួមគ្នាជាមួយ C.J Agro Business Co.. Ltd ដែលមានគោលបំណងបង្កើតការផ្គត់ផ្គង់ទីផ្សារបន្លែប្រកបដោយសុវត្ថិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ មានដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល<br>(កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) |
| នាថ្ងៃទី១ ខែមករា | **២៥២.៥៦០** | **១.០២៨.៩២៩** | ១៥១.៨០៥ | ៦១៤.០៥១ | - | - |
| សំវិធានធនក្នុងការិយបរិច្ឆេទ | **៩១.០៣៥** | **៣៧២.០៦០** | ១០០.៧៥៥ | ៤០៩.៨៧១ | ១៥១.៨០៦ | ៦១៨.៩០៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **១៣.៥៩៣** | - | ៥.០០៧ | - | (៤.៨៥៤) |
| នាថ្ងៃទី៣១ ខែធ្នូ | **៣៤៣.៥៩៥** | **១.៤១៤.៥៨២** | ២៥២.៥៦០ | ១.០២៨.៩២៩ | ១៥១.៨០៦ | ៦១៤.០៥៥ |

## ១២. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដី<br>ដុល្លារអាមេរិក | អគារ<br>ដុល្លារអាមេរិក | ការកែលម្អអគារ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារព័ត៌មានវិទ្យា<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ និងគ្រឿងសង្ហារឹម<br>ដុល្លារអាមេរិក | ការសាងសង់កំពុងដំណើរការ<br>ដុល្លារអាមេរិក | ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|
| សមតុល្យយោងដុល | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៤.៦៤៤.៥៣១ | ៣២៩.៣៤៤ | ២២២.៤៣៦ | ១.៧៣៨.១៣៨ | ១.៦៦៤.៦០៩ | ៤៦៩.២៨៧ | ១.៨៤៧.៩១៦ | ១០.៩១៦.២៦១ | ៤៤.៤៧២.៨៤៧ |
| ទិញបន្ថែម | ១៦០.៥១៩ | - | - | ២០០.២៣៥ | ៦៥៧.៧៤៦ | ៤០២.២៣៤ | ៤.៩៦១.២៤៥ | ៦.៣៨១.៩៧៩ | ២៦.០៨៣.១៤៨ |
| លក់ចេញ | - | - | (១១.៨៤៨) | (២.០១០) | (១៦៣.៥៣៨) | (៦៦.៨៦៨) | - | (២៤៤.២៦៤) | (៩៩៨.៣០៧) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ៦៥៣.៥៣១ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៤.៨០៥.០៥០ | ៣២៩.៣៤៤ | ២១០.៥៨៨ | ១.៩៣៦.៣៦៣ | ២.១៥៨.៨១៧ | ៨០៤.៦៥៣ | ៦.៨០៩.១៦១ | ១៧.០៥៣.៩៧៦ | ៧០.២១១.២១៩ |
| | | | | | | | | | |
| រំលស់បង្គរ | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | ២១០.៦១៩ | ១៤៨.៦០៩ | ១.០៣៧.០៦២ | ៥៣៨.១៩៣ | ៣១០.០៨០ | - | ២.២៤៤.៥៦៣ | ៩.១៤៤.៣៤៩ |
| រំលស់ | - | ១៦.៤៦៨ | ២៦.៤៨៣ | ២០៧.៨៩៤ | ៦៣១.៦១៧ | ១៦០.៦៧៩ | - | ១.០៤៣.១៤១ | ៤.២៦៣.៣១៧ |
| លក់ចេញ | - | - | (១១.៨៤៨) | (២.០១០) | (១៦៣.៥៣៨) | (៦៦.៨៦៨) | - | (២៤៤.២៦៤) | (៩៩៨.៣០៧) |
| ការធ្វើចំណាត់ថ្នាក់ឡើងវិញ | - | - | ១៨.៨០០ | (១៨.៨០០) | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ១២០.៤៨៣ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | - | ២២៧.០៨៧ | ១៨២.០៤៤ | ១.២២៤.១៤៦ | ១.០០៦.២៧២ | ៤០៣.៨៩១ | - | ៣.០៤៣.៤៤០ | ១២.៥២៩.៨៤២ |
| សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៤.៨០៥.០៥០ | ១០២.២៥៧ | ២៨.៥៤៤ | ៧១២.២១៧ | ១.១៥២.៥៤៥ | ៤០០.៧៦២ | ៦.៨០៩.១៦១ | ១៤.០១០.៥៣៦ | ៥៧.៦៨១.៣៧៧ |

## ១២. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| | ដី<br>ដុល្លារអាមេរិក | អគារ<br>ដុល្លារអាមេរិក | ការកែលម្អអគារ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារព័ត៌មានវិទ្យា<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ និងគ្រឿងសង្ហារឹម<br>ដុល្លារអាមេរិក | ការសាងសង់កំពុងដំណើរការ<br>ដុល្លារអាមេរិក | ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|
| សមតុល្យយោងដុល | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៣.០២៦.៦៧១ | ៣២៩.៣៤៤ | ២២១.៩៩១ | ១.៤៦៧.៩៣៩ | ៤៥៦.៥៩១ | ៣៨៦.៣៥១ | - | ៥.៨៨៨.៨៨៧ | ២៣.៨២០.៥៤៨ |
| ទិញបន្ថែម | ១.៦១៧.៨៦០ | | ៤៤៥ | ២៧០.១៩៩ | ១.២០៨.០១៨ | ៨២.៩៣៦ | ១.៨៤៧.៩១៦ | ៥.០២៧.៣៧៤ | ២០.៤៥១.៣៥៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២០០.៩៤២ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៤.៦៤៤.៥៣១ | ៣២៩.៣៤៤ | ២២២.៤៣៦ | ១.៧៣៨.១៣៨ | ១.៦៦៤.៦០៩ | ៤៦៩.២៨៧ | ១.៨៤៧.៩១៦ | ១០.៩១៦.២៦១ | ៤៤.៤៧២.៨៤៧ |
| | | | | | | | | | |
| រំលស់បង្គរ | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | - | ១៩៤.០៤៩ | ១២២.៣២១ | ៨៦៥.៦៤៨ | ៣៥០.៨២៥ | ២៥០.៨៦៦ | - | ១.៧៨៣.៧០៩ | ៧.២១៥.១០៣ |
| រំលស់ | - | ១៦.៥៧០ | ២៦.២៨៨ | ១៧១.៤១៤ | ១៨៧.៣៦៨ | ៥៩.២១៤ | - | ៤៦០.៨៥៤ | ១.៨៧៤.៧៥៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ៥៤.៤៩២ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | - | ២១០.៦១៩ | ១៤៨.៦០៩ | ១.០៣៧.០៦២ | ៥៣៨.១៩៣ | ៣១០.០៨០ | - | ២.២៤៤.៥៦៣ | ៩.១៤៤.៣៤៩ |
| សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៤.៦៤៤.៥៣១ | ១១៨.៧២៥ | ៧៣.៨២៧ | ៧០១.០៧៦ | ១.១២៦.៤១៦ | ១៥៩.២០៧ | ១.៨៤៧.៩១៦ | ៨.៦៧១.៦៩៨ | ៣៥.៣២៨.៤៩៨ |

## ១២. ទ្រព្យសម្បត្តិ និងបរិក្ខារ-សុទ្ធ (ត)

| | ដី<br>ដុល្លារអាមេរិក | អគារ<br>ដុល្លារអាមេរិក | ការកែលម្អអគារ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារព័ត៌មានវិទ្យា<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ និងគ្រឿងសង្ហារឹម<br>ដុល្លារអាមេរិក | ការសាងសង់កំពុងដំណើរការ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|
| សមតុល្យយោងដុល | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ២.០០៦.៦៧១ | ៣២៩.៣៨៤ | ១៧៧.២២២ | ១.០៧០.៧២៦ | ៣៧៩.៧៨២ | ៣២២.២៣៨ | - | ៤.២៨៥.៩៨៣ | ១៧.៤៦៥.៣៨១ |
| ទិញបន្ថែម | ១.០២០.០០០ | - | ៤៤.៧៦៩ | ៤៥៥.៣៦៣ | ៧៦.៨០៩ | ៦៤.១១៣ | - | ១.៦៦១.០៥៤ | ៦.៧៧២.១១៧ |
| លុបចោល | - | - | - | (៥៨.១៥០) | - | - | - | (៥៨.១៥០) | (២៣៧.០៧៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (១៧៩.៨៧២) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៣.០២៦.៦៧១ | ៣២៩.៣៨៤ | ២២១.៩៩១ | ១.៤៦៧.៩៣៩ | ៤៥៦.៥៩១ | ៣៨៦.៣៥១ | - | ៥.៨៨៨.៨៨៧ | ២៣.៨២០.៥៤៨ |
| វិលស់បង្គរ | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | - | ១៧៧.៤៩១ | ៩៤.៦៣៧ | ៧៣៩.៤៥០ | ២៩១.៨៦៥ | ១៩៨.៨៧៥ | - | ១.៥០២.៣១៨ | ៦.១២១.៩៤៧ |
| វិលស់ | - | ១៦.៥៥៨ | ២៧.៦៨៤ | ១៨៤.៣៤៨ | ៥៨.៩៦០ | ៥១.៩៩១ | - | ៣៣៩.៥៤១ | ១.៣៨៤.៣០៩ |
| លុបចោល | - | - | - | (៥៨.១៥០) | - | - | - | (៥៨.១៥០) | (២៣៧.០៧៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (៥៤.០៧៥) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | - | ១៩៤.០៤៩ | ១២២.៣២១ | ៨៦៥.៦៤៨ | ៣៥០.៨២៥ | ២៥០.៨៦៦ | - | ១.៧៨៣.៧០៩ | ៧.២១៥.១០៣ |
| សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៣.០២៦.៦៧១ | ១៣៥.២៩៥ | ៩៩.៦៧០ | ៦០២.២៩១ | ១០៥.៧៦៦ | ១៣៥.៤៨៥ | - | ៤.១០៥.១៧៨ | ១៦.៦០៥.៤៤៥ |

## ១៣. ទ្រព្យសកម្មអរូបី

| | កម្មវិធីកុំព្យូទ័រ ដុល្លារអាមេរិក | ទ្រព្យសកម្មកំពុងដំណើរការសាងសង់ ដុល្លារអាមេរិក | ដុល្លារអាមេរិក | សរុប ពាន់រៀល |
|---|---|---|---|---|
| **ថ្លៃដើម** | | | | |
| **សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | **២៣១.៥២៧** | **៩២៤.០០០** | **១.១៥៥.៥២៧** | **៤.៧០៧.៦១៧** |
| **ទិញបន្ថែម** | **៩១២.៧៣៨** | **-** | **៩១២.៧៣៨** | **៣.៧៣០.៣៦០** |
| **លុបចោល** | **(១១១.៧៦០)** | **-** | **(១១១.៧៦០)** | **(៤៥៦.៧៦៣)** |
| **លម្អៀងពីការប្តូររូបិយប័ណ្ណ** | **-** | **-** | **-** | **៧៣.៧១៧** |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១.០៣២.៥០៥** | **៩២៤.០០០** | **១.៩៥៦.៥០៥** | **៨.០៥៤.៩៣១** |
| **រំលស់បង្គរ** | | | | |
| **សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | **២០៣.២៧៣** | **-** | **២០៣.២៧៣** | **៨២៨.១៣៤** |
| **រំលស់** | **៧៦.០២១** | **-** | **៧៦.០២១** | **៣១០.៦៩១** |
| **លុបចោល** | **(១១១.៧៦០)** | **-** | **(១១១.៧៦០)** | **(៤៥៦.៧៦៣)** |
| **លម្អៀងពីការប្តូររូបិយប័ណ្ណ** | **-** | **-** | **-** | **៧.៦៧០** |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១៦៧.៥៣៤** | **-** | **១៦៧.៥៣៤** | **៦៨៩.៧៣៧** |
| **សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៨៦៤.៩៧១** | **៩២៤.០០០** | **១.៧៨៨.៩៧១** | **៧.៣៦៥.១៩៤** |
| ថ្លៃដើម | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ ២០២១ | ១៧២.៩០៤ | ៩៨២.៦២៣ | ១.១៥៥.៥២៧ | ៤.៦៧៤.១០៧ |
| ផ្ទេរ | ៥៨.៦២៣ | (៥៨.៦២៣) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ៣៣.៥១០ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ២៣១.៥២៧ | ៩២៤.០០០ | ១.១៥៥.៥២៧ | ៤.៧០៧.៦១៧ |
| រំលស់បង្គរ | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ១៧១.៨៨១ | - | ១៧១.៨៨១ | ៦៩៥.២៥៩ |
| រំលស់ | ៣១.៣៩២ | - | ៣១.៣៩២ | ១២៧.៧០៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ៥.១៧២ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ២០៣.២៧៣ | - | ២០៣.២៧៣ | ៨២៨.១៣៤ |
| សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ២៨.២៥៤ | ៩២៤.០០០ | ៩៥២.២៥៤ | ៣.៨៧៩.៤៨៣ |

## ១៣. ទ្រព្យសកម្មអរូបី (ត)

| | កម្មវិធីកុំព្យូទ័រ | ទ្រព្យសកម្មកំពុងដំណើរការសាងសង់ | | សរុប |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **ថ្លៃដើម** | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ ២០២០ | ១៧២.៩០៤ | ២៥៣.៧៧០ | ៤២៦.៦៧៤ | ១.៧៣៨.៦៩៧ |
| ទិញបន្ថែម | - | ៧២៨.៨៥៣ | ៧២៨.៨៥៣ | ២.៩៧១.៥៣៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (៣៦.១២៤) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ១៧២.៩០៤ | ៩៨២.៦២៣ | ១.១៥៥.៥២៧ | ៤.៦៧៤.១០៧ |
| **រំលស់បង្គរ** | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ១៧០.១០១ | - | ១៧០.១០១ | ៦៩៣.១៦២ |
| រំលស់ | ១.៧៨០ | - | ១.៧៨០ | ៧.២៥៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (៥.១៦០) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ១៧១.៨៨១ | - | ១៧១.៨៨១ | ៦៩៥.២៥៩ |
| សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ១.០២៣ | ៩៨២.៦២៣ | ៩៨៣.៦៤៦ | ៣.៩៧៨.៨៤៨ |

## ១៤. ប្រាក់បញ្ញើពីអតិថិជន

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ប្រាក់បញ្ញើតាមតម្រូវការ | **៣.៥២៥.៩៧៥** | **១៤.៥១៦.៤៣៩** | ២.០៥៥.៨៩៧ | ៨.៣៧៥.៧២៤ | ២.១៤៤.៣៦០ | ៨.៦៧៣.៩៣៦ |
| គណនីសន្សំ | **២.៥៥០.៤៦៣** | **១០.៥០០.២៥៦** | ២.០២០.៩៤១ | ៨.២៣៣.៣១៤ | ២.៣៧០.២០៥ | ៩.៥៨៧.៤៧៩ |
| ប្រាក់បញ្ញើមានកាលកំណត់ | **១.៩៦១.៦៥៣** | **៨.០៧៦.១២៦** | ១.៦៧៦.៨១៩ | ៦.៨៣១.៣៦១ | ៧៨៦.៥២១ | ៣.១៨១.៤៧៨ |
| | **៨.០៣៨.០៩១** | **៣៣.០៩២.៨២១** | ៥.៧៥៣.៦៥៧ | ២៣.៤៤០.៣៩៩ | ៥.៣០១.០៨៦ | ២១.៤៤២.៨៩៣ |

### ក. តាមកាលកំណត់៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **តាមកាលកំណត់៖** | | | | | | |
| អំឡុងពេល ១ខែ | **៦.១៣៤.១៦៨** | **២៥.២៥៤.៣៧១** | ៤.០៧៦.៨៥៩ | ១៦.៦០៩.១២៤ | ៤.៥១៤.៥៨៥ | ១៨.២៦១.៤៩៧ |
| > ១ ទៅ ៣ខែ | **១១៥.៩៩៤** | **៤៧៧.៥៤៦** | ៦៨.៩៤៧ | ២៨០.៨៩០ | ៤៨៨.៦២៩ | ១.៩៧៦.៥០៤ |
| > ៣ ទៅ ៦ខែ | **៥០.៩៩៧** | **២០៩.៩៥៤** | - | - | - | - |
| > ៦ ទៅ ១២ខែ | **៧៣៥.៥៣២** | **៣.០២៨.១៨៤** | ៥៦៧.១៨២ | ២.៣១០.៦៩៩ | ២៩៧.៨៧២ | ១.២០៤.៨៩២ |
| > ១ ឆ្នាំ ទៅ ៣ឆ្នាំ | **១.០០១.៤០០** | **៤.១២២.៧៦៦** | ១.០៤០.៦៦៩ | ៤.២៣៩.៦៨៦ | - | - |
| | **៨.០៣៨.០៩១** | **៣៣.០៩២.៨២១** | ៥.៧៥៣.៦៥៧ | ២៣.៤៤០.៣៩៩ | ៥.៣០១.០៨៦ | ២១.៤៤២.៨៩៣ |

## ១៤. ប្រាក់បញ្ញើពីអតិថិជន (ត)

### ខ. តាមប្រភេទអតិថិជន៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| សហគ្រាស | ៧៧៨.៦៧៩ | ៣.២០៥.៨២០ | ២.០៧៩.២៦៥ | ៨.៤៧០.៩២៦ | ២.២៤៥.៤១៤ | ៩.០៨២.៧០០ |
| ឯកត្តជន | ៧.២៥៩.៤១២ | ២៩.៨៨៧.០០១ | ៣.៦៧៤.៣៩២ | ១៤.៩៦៩.៤៧៣ | ៣.០៥៥.៦៧២ | ១២.៣៦០.១៩៣ |
| | ៨.០៣៨.០៩១ | ៣៣.០៩២.៨២១ | ៥.៧៥៣.៦៥៧ | ២៣.៤៤០.៣៩៩ | ៥.៣០១.០៨៦ | ២១.៤៤២.៨៩៣ |

### គ. តាមនិវាសនដ្ឋាន៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| និវាសជន | ៨.០៣០.៧៨៦ | ៣៣.០៦២.៧៤៨ | ៥.៧៤០.៨៩៤ | ២៣.៣៨៨.៤០២ | ៥.២៩៩.៤២២ | ២១.៤៣៦.១៦២ |
| អនិវាសជន | ៧.៣០៥ | ៣០.០៧៣ | ១២.៧៦៣ | ៥១.៩៩៧ | ១.៦៦៤ | ៦.៧៣១ |
| | ៨.០៣៨.០៩១ | ៣៣.០៩២.៨២១ | ៥.៧៥៣.៦៥៧ | ២៣.៤៤០.៣៩៩ | ៥.៣០១.០៨៦ | ២១.៤៤២.៨៩៣ |

### ឃ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖

| | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|
| ប្រាក់បញ្ញើតាមតម្រូវការ | មិនមាន | មិនមាន | មិនមាន |
| គណនីសន្សំ | ១,០០% - ១,៥០% | ១,០០% - ១,៥០% | ១,០០% - ១,៥០% |
| ប្រាក់បញ្ញើមានកាលកំណត់ | ៣,០០% - ៦,០០% | ៣,០០% - ៦,០០% | ៣,០០% - ៦,០០% |

## ១៥. ប្រាក់បញ្ញើពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ប្រាក់បញ្ញើតាមតម្រូវការ | ៥.៣៦១ | ២២.០៦៩ | ១.៩៦៥ | ៨.០០៥ | ៣.៩៨៥ | ១៦.១១៩ |
| គណនីសន្សំ | ៦៤៧ | ២.៦៦៦ | ៦៦២ | ២.៦៩៧ | ៦៧៦ | ២.៧៣៥ |
| | ៦.០០៨ | ២៤.៧៣៥ | ២.៦២៧ | ១០.៧០២ | ៤.៦៦១ | ១៨.៨៥៤ |

### ក. តាមកាលកំណត់៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| អំឡុងពេល ១ខែ | ៦.០០៨ | ២៤.៧៣៥ | ២.៦២៧ | ១០.៧០២ | ៤.៦៦១ | ១៨.៨៥៤ |

## ១៥. ប្រាក់បញ្ញើពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ (ត)

### ខ. តាមនិវាសនដ្ឋាន៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| អំឡុងពេល ១ខែ | **៦.០០៨** | **២៤.៧៣៥** | ២.៦២៧ | ១០.៧០២ | ៤.៦៦១ | ១៨.៨៥៤ |

### គ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖

| | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|
| ប្រាក់បញ្ញើតាមតម្រូវការ | **មិនមាន** | មិនមាន | មិនមាន |
| គណនីសន្សំ | **១,០០% - ១,៥០%** | ១,០០% - ១,៥០% | ១,០០% - ១,៥០% |

## ១៦. ប្រាក់កម្ចី

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| រាជរដ្ឋាភិបាលកម្ពុជា- មូលនិធិពិសេស | **២២២.០៨៧.០៥៣** | **៩១៤.៣៣២.៣៩៧** | ១៥៣.១២៩.៨៤៨ | ៦២៣.៨៥១.០០១ | ១៥៤.០១២.៦០៨ | ៦២២.៩៨០.៩៩៩ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - ASDF | **១.២០៥.៨៣៨** | **៤.៩៦៤.៤៣៥** | ១.២០៥.៨៣៨ | ៤.៩១២.៥៨៤ | ៣៨.១៤៣.៣៣៨ | ១៥៤.២៨៩.៨០៣ |
| ភ្នាក់ងារ Française de Développement (“AFD”) | **២៤៨.៤៦១** | **១.០២២.៩១៤** | ២៤៨.៤៦១ | ១.០១២.២៣០ | ២៤៨.៤៦១ | ១.០០៥.០២៥ |
| មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍផ្នែកសិកម្ម ("IFAD") | **៣.៣០៨.៥៤៧** | **១៣.៦២១.២៨៨** | ២.០០៧.៤៣៧ | ៨.១៧៨.២៩៨ | ១.៩៥៩.០១១ | ៧.៩២៤.១៩៩ |
| មូលនិធិប្រាក់កម្ចីពីគន្ធបុប្ផា | **៩.៧៥០.៩៤៩** | **៤០.១៤៤.៦៥៧** | - | - | - | - |
| | **២៣៦.៦០០.៨៤៨** | **៩៧៤.០៨៥.៦៩១** | ១៥៦.៥៩១.៥៨៤ | ៦៣៧.៩៥៤.១១៣ | ១៩៤.៣៦៣.៤១៨ | ៧៨៦.២០០.០២៦ |

ប្រាក់កម្ចីពីភាគហ៊ុនិកគឺមិនមានទ្រព្យធានា មានការប្រាក់ក្នុងអត្រា ៩,៦% ក្នុងមួយឆ្នាំ ហើយអាចសងវិញបានតាមកាលកំណត់ចាប់ពី៤ ទៅ១២ខែ។

បម្រែបម្រួលនៃប្រាក់កម្ចី មានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| នាថ្ងៃទី១ ខែមករា | **១៥៦.៥៩១.៥៨៤** | **៦៣៧.៩៥៤.១១៣** | ១៩៤.៣៦៣.៤១៨ | ៧៨៦.២០០.០២៦ | ១១០.៤៨៥.៨៥១ | ៤៥០.២២៩.៨៤៣ |
| សាច់ប្រាក់បានពីប្រាក់កម្ចី | **៨២.៣៤៣.៧៧៥** | **៣៣៩.០០៩.៣២២** | ៣៣.៨៣៨ | ១៣៧.៦៥៣ | ៨៣.៩០០.២៧៩ | ៣៤២.០៦១.៤៣៧ |
| ការទូទាត់សងប្រាក់កម្ចី | **(១.២០៥.៨៣៩)** | **(៤.៩៦៤.៤៣៩)** | - | - | (១.១០៨.៣៤៧) | (៤.៥១៨.៧៣០) |
| ផ្ទេរពីប្រាក់កម្ចី - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ - ASDF ទៅ ដើមទុនផ្សេងៗ (*) | **(១.០៨៤.៧២៧)** | **(៤.៤៦៥.៨២១)** | (៣៦.៩៣៧.៥០០) | (១៥០.២៦១.៧៥០) | - | - |
| ចំណាយការប្រាក់ | **៧៣.០៥៩** | **៣០០.៧៨៤** | ៣០.៥៧៥ | ១២៤.៣៧៩ | ៥១៥.៧៦៣ | ២.១០២.៧៦៦ |
| ការប្រាក់បានបង់ | **(៣៦.៨១៣)** | **(១៥១.៥៥៩)** | (១៥.៩៨៧) | (៦៥.០៣៥) | (៣៦៧.៧៨៣) | (១.៤៩៩.៤៥១) |
| (ចំណេញ)/ខាតពីការប្តូររូបិយប័ណ្ណ | **(៨០.១៩១)** | **(៣៣០.១៤៨)** | (៨៨២.៧៦០) | (៣.៥៩១.០៦៨) | ៩៣៧.៦៥៥ | ៣.៨២២.៨១៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **៦.៧៣៣.៤៣៩** | - | ៥.៤០៩.៩០៨ | - | (៥.៩៩៨.៦៥៨) |
| នាថ្ងៃទី៣១ ខែធ្នូ | **២៣៦.៦០០.៨៤៨** | **៩៧៤.០៨៥.៦៩១** | ១៥៦.៥៩១.៥៨៤ | ៦៣៧.៩៥៤.១១៣ | ១៩៤.៣៦៣.៤១៨ | ៧៨៦.២០០.០២៦ |

(*) ភាគហ៊ុនិកបានសម្រេចចិត្តផ្ទេរពីប្រាក់កម្ចី - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - ASDF ចំនួន ១.០៨៤.៧២៧ ដុល្លារអាមេរិក (ឆ្នាំ២០២១៖ ៣៦.៩៣៧.៥០០ ដុល្លារអាមេរិក) ទៅដើមទុនផ្សេងៗ។ (មើលកំណត់សម្គាល់លេខ ២១ (៣) សម្រាប់ព័ត៌មានលម្អិត)។

## ១៦. ប្រាក់កម្ចី (ត)

